**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**Royal University of Law and Economics**

**សារណាបញ្ចប់ការសិក្សា**

# សុំកូនអន្តរប្រទេស

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **ហ៊ុយ សុខលីន**

សាស្ត្រាចារ្យណែនាំ

លោក **កេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៥ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦

ឆ្នាំសរសេរសារណា ២០២០

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
**Université Royale de Droit et des Sciences Économiques**
**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# សុំកូនអន្តរប្រទេស

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ **ហ៊ុយ សុខលីន**

សាស្ត្រាចារ្យណែនាំ
លោក **កេត សុជាតិ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២៥ (អាហារូបករណ៍)

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្ដីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ហ៊ុយ សុខលីន** ជានិស្សិតបញ្ចប់ថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រឆ្នាំទី៤ ជំនាន់ទី២៥ (អាហារូបករណ៍) នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៦-២០២០។

ខ្ញុំបាទសូមអនុញ្ញាតសម្ដែងនូវការគោរពដឹងគុណដោយស្មោះអស់ពីដួងចិត្តចំពោះ លោកឪពុក **ស៊ាង ហ៊ុយ** និង អ្នកម្ដាយ **លាង សុគន្ធ** ដែលជាអ្នកបង្កើត គុណបង្កើតជីវិតរបស់លោកទាំងទ្វេ និងការចិញ្ចឹមបីបាច់ថែរក្សា ទំនុកបម្រុង ការទូន្មានប្រៀនប្រដៅ អប់រំ ស្រឡាញ់ ការពារ និងផ្ដល់នូវភាពកក់ក្ដៅចំពោះកូន ចាប់តាំងពីបើកភ្នែកឃើញពន្លឺព្រះអាទិត្យ។ គួរស្ញប់ស្ញែងរកអ្វីប្រៀបផ្ទឹមពុំបាន គឺព្រហ្មវិហារធម៌ និងសេចក្ដីមេត្តា ករុណា អាណិតអាសូរ ការយកចិត្តទុកដាក់ ការលះបង់ ការពុះពារ ការខិតខំប្រឹងប្រែង ជម្នះគ្រប់ឧបសគ្គ ដើម្បីឱ្យកូន សម្រេចបានជោគជ័យ សមតាមបំណងប្រាថ្នាក្នុងការសិក្សា។ រាល់ការលំបាក ញើសឈាមដែលលោកបានខិតខំប្រឹងប្រែងរក ឥតមានជាប់ជំពាក់នឹងឧបាយមុខ ការភ្ញាល់ភ្នាន់ អំពើទុច្ចរិត ខុសច្បាប់ សរបង្ហាញពីតម្លៃអប់រំដែលពុំអាចកាត់ថ្លៃបានថា "បើទោះបីយើងកើតមកក្រ តែឥតក្រគំនិត បើទោះបីយើងក្រ ក៏ឥតទុច្ចរិត បើទោះបីយើងក្រ ក៏ឥតលោភលន់" ដែលជាហេតុសុញបញ្ញា ប្រព្រឹត្តខុសក្បួនតម្រា។

ខ្ញុំបាទសូមថ្លែងអំណរអរគុណយ៉ាងអនេកចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានបង្ហាត់បង្រៀន ផ្ដល់នូវចំណេះដឹងរាប់ចាប់តាំងពីថ្នាក់មូលដ្ឋាន ដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រ។ ក្នុងវិថីនៃការសិក្សានេះ ការបង្ហាញផ្លូវរបស់លោកសាស្ត្រាចារ្យ **កេត សុជាតិ** ដែលបានដឹកនាំ និងផ្ដល់នូវដំបូលន្មានល្អៗក្នុងគ្រាកន្លងមកសម្រាប់កិច្ចការស្រាវជ្រាវចងក្រងសារណានេះ ចំពោះរូបខ្ញុំបាទ ហើយក៏សូមអំណរអរគុណដល់ការចំណាយពេលវេលាដ៏មានតម្លៃ សម្រាប់កែលម្អកិច្ចស្រាវជ្រាវនេះ ដើម្បីឱ្យកាន់តែប្រសើរ។

មុននឹងបញ្ចប់ ខ្ញុំបាទសូមបួងសួង និងប្រសិទ្ធិពរជ័យដល់**លោកអ្នកមានគុណទាំងទ្វេ ឯកឧត្តមសាកលវិទ្យាល័យធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ និងបុគ្គលិកគ្រប់ជាន់ថ្នាក់ទាំងអស់** ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីអាកខានឡើយ។

# អារម្ភកថា

សារណាមួយនេះ ជាលទ្ធផលដែលបង្ហាញពីការខិតខំប្រឹងប្រែង ស្រាវជ្រាវ រៀនសូត្រក្នុងក្របខណ្ឌបរិញ្ញាបត្របួនឆ្នាំនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចមកនេះ។ ក្នុងចំណោមសិស្សនិស្សិតដែលមានឆន្ទៈសិក្សាស្រាវជ្រាវផ្អែកលើមុខវិជ្ជាដែលខ្លួនពេញចិត្ត ខ្លួនខ្ញុំបាទក៏ដូច្នេះដែរ គឺមានទំនោរលើប្រធានបទដែលផ្សាភ្ជាប់លើកិច្ចខិតខំប្រឹងប្រែងលើវិស័យកុមារ ក្នុងក្របខណ្ឌទំនាក់ទំនងផ្អែកឯកជននេះ បានបោះជំហានទៅរកប្រធានបទមួយ "**សុំកូនអន្តរប្រទេស**" ដែលជាផ្នែកមួយនៃនីតិអន្តរជាតិឯកជន។

ជាចំណាប់អារម្មណ៍លើប្រធានបទនេះ គឺលើកឡើងពីមូលហេតុ គោលបំណង គោលការណ៍សំខាន់ៗ លក្ខខណ្ឌ និងនីតិវិធីសម្រាប់ការបង្កើតសុំកូនអន្តរប្រទេសមួយដែលធានាថា មានភាពត្រឹមត្រូវ និយ័តភាពគតិយុត្ត និងដំណោះស្រាយមួយយ៉ាងពិតប្រាកដចំពោះកុមារដែលជាកូនសុំ។ លើសពីនេះ ការយកចិត្តទុកដាក់រវាងរដ្ឋ និងរដ្ឋលើទំនាក់ទំនងសុំកូនដែលធានាដល់ ការការពារសិទ្ធិ និងឧត្តមប្រយោជន៍ពិតប្រាកដដល់កុមារដែលកំពុងទាមទារជំនួយពីអ្នករាល់គ្នា។

ជារួមមក ខ្ញុំមានចេតនាបង្ហាញជាទូទៅអំពីកុមារដែលកំពុងស្វែងរកជំនួយពីសប្បុរសជន ដើម្បីបំផុសចំណាប់អារម្មណ៍របស់សាធារណជនឱ្យមានសប្បុរសធម៌ជួយសង្គ្រោះកុមារដែលកំពុងតែប្រឈមមុខនឹងភាពគ្រោះថ្នាក់អោយបានប្រសើរឡើង។

ដោយឡែកកិច្ចការមួយនេះ ក៏អាចកើតមានកំហុសឆ្គងដែលមានដោយអចេតនា ដោយប្រការណាមួយ។ ហេតុនេះ ខ្ញុំបាទរីករាយទទួលយកមតិយោបល់ដែលរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ សាស្ត្រាចារ្យ រៀមច្បង និងមិត្តនិស្សិតអ្នកអានទាំងអស់ ដើម្បីឱ្យកិច្ចការនេះទទួលបានលទ្ធផលកាន់តែប្រសើរ និងសមបំណងថែមទៀត។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........ ១

១. លំនាំនៃការស្រាវជ្រាវ ........ ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

៣. គោលបំណងនៃការស្រាវជ្រាវ ........ ២

៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ២

៥. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ២

**ជំពូកទី១**

**ទស្សនៈទានទូទៅនៃសុំកូនអន្តរប្រទេស**

**ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការសុំកូនអន្តរប្រទេស** ........ ៣

**កថាភាគទី១ ៖ គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស** ........ ៤

**កថាភាគទី២ ៖ គោលបំណងនៃការបង្កើតសុំកូនអន្តរប្រទេស** ........ ៥

**កថាភាគទី៣ ៖ ដំណើរការវិវត្តនៃនីតិសុំកូនអន្តរប្រទេស** ........ ៧

**កថាភាគទី៤ ៖ លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស** ........ ៨

១. និយមន័យសុំកូនអន្តរប្រទេស ........ ៨

២. លក្ខខណ្ឌគ្រឹះសម្រាប់សុំកូនអន្តរប្រទេស ........ ៩

២.១. កូនសុំ ........ ៩

២.២. ការយល់ព្រមលើសុំកូន ........ ១២

២.២.១. គោលការណ៍នៃការយល់ព្រមលើកូនសុំ ........ ១២

២.២.២. ការបញ្ជាប់ការយល់ព្រមលើសុំកូន ........ ១៣

២.២.៣. ការដកហូតអំណាចមេបា ........ ១៤

២.៣. អ្នកសុំ ........ ១៤

៣. សុំកូនអន្តរប្រទេសដោយយសាច់ញាតិ ........ ១៥

៣.១. លក្ខខណ្ឌចំពោះកូនសុំ ..... ១៥
៣.២. លក្ខខណ្ឌចំពោះអ្នកសុំ ..... ១៧
៣.៣. បែបបទនៃការស្នើសុំ ..... ១៧
**ផ្នែកទី២ ៖ អាជ្ញាធរមានសមត្ថកិច្ចក្នុងការសុំកូនអន្តរប្រទេស** ..... ១៩
**កថាភាគទី១ ៖ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស** ..... ១៩
១. ភារកិច្ចរបស់អាជ្ញាធររដ្ឋបាលកណ្តាលសុំកូនអន្តរប្រទេស ..... ១៩
២. គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស ..... ២១
**កថាភាគទី២ ៖ រដ្ឋបាលសុំកូនអន្តរប្រទេស** ..... ២១
១. សមាសភាព ..... ២២
២. តួនាទីភារកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ..... ២២
**កថាភាគទី៣ ៖ ទីភ្នាក់ងារសុំកូនអន្តរប្រទេស** ..... ២៤
១. លក្ខណសម្បត្តិរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ..... ២៤
២. ការដាក់ពាក្យសុំធ្វើប្រតិបត្តិការជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ..... ២៥
៣. អាជ្ញាធរផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារសុំកូនអន្តរប្រទេស ..... ២៦
៤. ទោសប្បញ្ញត្តិ ..... ២៧
៤.១. ការពិន័យអន្តរការណ៍ ..... ២៧
៤.២. ទោសដាក់ពន្ធនាគារ ..... ២៩

## ជំពូកទី២

## នីតិវិធីនៃការបង្កើតសុំកូនអន្តរប្រទេស

**ផ្នែកទី១ ៖ នីតិវិធីរដ្ឋបាល** ..... ៣១
**កថាភាគទី១ ៖ ការដាក់ពាក្យ** ..... ៣១
**កថាភាគទី២ ៖ ការពិនិត្យពាក្យសុំ** ..... ៣៣
**កថាភាគទី៣ ៖ ការសម្រេចលើពាក្យសុំ** ..... ៣៣
**ផ្នែកទី២ ៖ នីតិវិធីតុលាការ** ..... ៣៥
**កថាភាគទី១ ៖ សមត្ថកិច្ចផ្តាច់មុខ** ..... ៣៦

កថាភាគទី២ ៖ ការពិនិត្យតស្តុតាង ............ ៣៦
កថាភាគទី៣ ៖ ដីកាសម្រេច ............ ៣៧
កថាភាគទី៤ ៖ សោហ៊ុយលើការសុំកូន ............ ៣៨
ផ្នែកទី៣ ៖ កុមារក្រោយពេលទៅដល់ប្រទេសសុំ ............ ៣៩

## ជំពូកទី៣

## ផលវិជ្ជមាន និងអវិជ្ជមាននៃសុំកូនអន្តរប្រទេស

ផ្នែកទី១ ៖ ផលប្រយោជន៍នៃការសុំកូនអន្តរប្រទេស ............ ៤១
កថាភាគទី១ ៖ ចំពោះឪពុក និងម្តាយបង្កើត ............ ៤២
កថាភាគទី២ ៖ ផលប្រយោជន៍ចំពោះកូនសុំ ............ ៤៣
កថាភាគទី៣ ៖ ផលប្រយោជន៍ចំពោះអ្នកសុំ ............ ៤៤
ផ្នែកទី២ ៖ គុណវិបត្តិនៃសុំកូនអន្តរប្រទេស ............ ៤៥
កថាភាគទី១ ៖ គុណវិបត្តិចំពោះឪពុក និង/ឬ ម្តាយបង្កើត ............ ៤៥
កថាភាគទី២ ៖ គុណវិបត្តិចំពោះកូនសុំ ............ ៤៦
កថាភាគទី៣ ៖ គុណវិបត្តិចំពោះអ្នកសុំ ............ ៤៦
ផ្នែកទី៣ ៖ អានុភាពនៃការសុំកូនអន្តរប្រទេស ............ ៤៧
សេចក្តីសន្និដ្ឋាន ............ ៤៨
អនុសាសន៍ ............ ៤៩
ឯកសារយោង
ឧបសម្ព័ន្ធ

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

ក្នុងទំនាក់ទំនងឯកជន គឺជាទំនាក់ទំនងដែលមានមូលហេតុគតិយុត្តច្បាស់លាស់ រវាងបុគ្គលម្នាក់ទៅបុគ្គលម្នាក់។ តែទំនាក់ទំនងនេះ បង្កើតឡើងកាន់តែមានភាពស្មុគស្មាញថែមទៀត ប្រសិនបើត្រូវបានផ្សារភ្ជាប់រវាងរដ្ឋមួយ និងរដ្ឋមួយទៀតនោះ។ ក្នុងក្របខណ្ឌនៃនីតិអន្តរជាតិឯកជន ត្រូវបានស្រាយទំនាក់ទំនងរវាងសមាជិករបស់រដ្ឋមួយទៅរដ្ឋមួយ តាមរយៈការគូសបន្ទាត់ច្បាប់ឱ្យត្រូវគ្នា។ ក្នុងទំហំដ៏ធំនៃទំនាក់ទំនងផ្នែកអន្តរជាតិឯកជននេះ គឺមានទំនាក់ទំនងជាច្រើន ក៏ប៉ុន្តែអត្ថបទនេះ នឹងលើកយកតែទំនាក់ទំនងនៃការសុំកូនអន្តរប្រទេសមកស្រាវជ្រាវ ពីព្រោះវាជាប់ពាក់ព័ន្ធជាអន្តរជាតិដែលតម្រូវឱ្យមានការគោរពតាមបទដ្ឋានគតិយុត្តរវាងប្រទេសសុំ និងប្រទេសទទួល ដែលផ្សារភ្ជាប់នូវរបបទំនាក់ទំនងគតិយុត្តពីរផ្សេងគ្នា។ ម៉្យាងទៀត ដោយផ្តើមចេញពីការគោរពសិទ្ធិមនុស្សជាសកល ព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ន និងទទួលស្គាល់បទដ្ឋានគតិយុត្ត លិខិតូបករណ៍អន្តរជាតិជាច្រើន ដើម្បីធានានូវការគោរពសិទ្ធិនេះឱ្យកាន់តែប្រសើរ រហូតដល់មានការស្ថាបនាបទដ្ឋានច្បាប់ក្នុងស្រុក ឱ្យកាន់តែគ្រប់គ្រាន់ ច្បាស់លាស់ ជាពិសេសសម្រាប់កុមារដូចមានច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ លក្ខណៈពិសេសនៃប្រធានបទ រួមមានការការពារសិទ្ធិជាមូលដ្ឋាន និងឧត្តមប្រយោជន៍នៃកុមារ ដែលធានាដោយបទដ្ឋានជាតិ និងអន្តរជាតិផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាការពិត ការលើកឡើងនូវទំនាក់ទំនងនៃការសុំកូនអន្តរប្រទេសមកសិក្សាក្នុងពេលបច្ចុប្បន្ននេះ ហាក់បីដូចជាមិនទាន់មានភាពសកម្មនៅឡើយ ក៏ព្រោះថាការសុំកូនអន្តរប្រទេស គឺមិននិយមក្នុងការបង្កើតនោះទេ។ ក៏ប៉ុន្តែ ដើម្បីស្រាយចម្ងល់ថា "នៅពេលដែលកុមារដែលជាជនងាយរងគ្រោះ ឬជាជនទន់ខ្សោយ ដែលអាចជួបប្រទះនូវភាពគ្រោះថ្នាក់ មិនថា ការបោះបង់ចោល ភាពកំព្រាគ្មានការមើលថែរក្សា គ្មានការផ្គត់ផ្គង់ដោយសារស្ថានភាពសេដ្ឋកិច្ចគ្រួសារ ឬដោយមូលហេតុផ្សេងៗទៀត តើរដ្ឋនឹងធ្វើការចាត់ចែងពួកគេយ៉ាងណា ដើម្បីធានាថាទទួលបាន សិទ្ធិរស់រានមានជីវិតជាប់ពីកំណើត និងសិទ្ធិជាមូលដ្ឋានផ្សេងៗសម្រាប់កុមារ? តើពួកគេត្រូវទទួលបានការថែទាំយ៉ាងដូចម្តេច? តើពួកគេអាចទទួលបានគ្រួសារអចិន្ត្រៃយ៍មួយយ៉ាងដូចម្តេច? តើវិធានទាំងនោះត្រូវប្រព្រឹត្តទៅតាមនីតិវិធីបែបណា?"។

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការស្រាវជ្រាវ គឺជាការសិក្សាទៅលើក្របខណ្ឌគតិយុត្តពិសេស (ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស) បទដ្ឋានបន្ទាប់បន្សំ (អនុក្រឹត្យ ប្រកាស សេចក្តីណែនាំនានាពាក់ព័ន្ធនឹងការបង្កើតស្មុំកូនអន្តរប្រទេស) ហើយពិសេសជាងនេះ គឺចងក្រងឯកសារសម្រាប់ជាប្រយោជន៍ដល់ការសិក្សាស្រាវជ្រាវលើប្រធានបទ "**ស្មុំកូនអន្តរប្រទេស**" នេះដល់មហាជន សិស្សនិស្សិត ដើម្បីធានាពីនិយ័តភាពក្នុងការស្មុំកូនអន្តរប្រទេសឱ្យបានត្រឹមត្រូវតាមច្បាប់ និងបទដ្ឋានគតិយុត្តនានា ក្នុងពេលបច្ចុប្បន្ន និងពេលអនាគត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

នៅក្នុងក្របខណ្ឌនៃការសិក្សាលើទំនាក់ទំនងអនីតិជន ក៏ដូចជាការមើលថែ ការការពារ ការស្វែងរកគ្រួសារជាអចិន្ត្រៃយ៍មួយសម្រាប់កុមារដែលជាជនរងគ្រោះនោះ គឺមានភាពស្មុគស្មាញ ហើយមានលំហូរនីតិវិធីវែងឆ្ងាយ ជាហេតុនាំឱ្យពិបាកក្នុងការលើកមកសិក្សាទាំងស្រុង។ ក្នុងមុខងារនេះ ស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្ត ចាប់ផ្តើមពីការបង្រួបបង្រួមគ្រួសាររបស់កុមារដែលបានបែកបាក់គ្នាក្នុងគ្រួសារ រហូតដល់ការប្តូរយន្តការសម្រាប់ស្វែងរកគ្រួសារអចិន្ត្រៃយ៍សម្រាប់កុមារតាមរយៈការថែទាំជំនួស ដូចជាការដាក់ផ្ញើនៅជាមួយសាច់ញាតិគ្រួសារធម៌ សហគមន៍ និងក្នុងមណ្ឌលកុមារ។ ផ្ទុយទៅវិញ បើយន្តការដែលបានរៀបរាប់ខាងលើមិនបានទទួលជោគជ័យទេ ការប្រើប្រាស់យន្តការចុងក្រោយ គឺការពិនិត្យមើលលើលក្ខណសម្បត្តិរបស់កុមារសម្រាប់ការបង្កើតស្មុំកូននឹងត្រូវចាប់ផ្តើម។ អាស្រ័យហេតុនេះ ការស្មុំកូនក្នុងស្រុកនឹងត្រូវមានអាទិភាព មុនការពិចារណាលើលក្ខខណ្ឌសម្រាប់ស្មុំកូនអន្តរប្រទេសក្រោយពីការស្មុំកូនក្នុងស្រុកមិនអាចធ្វើទៅបាន។ ជារួមប្រធានបទនេះ គឺធ្វើការស្រាវជ្រាវតែក្នុងទំហំនៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសដោយផ្ទាល់ ចំពោះលំហូរនៃការបង្កើតស្មុំកូនអន្តរប្រទេស និងបទដ្ឋានគតិយុត្តដែលមានមកសិក្សា។ លើសពីនេះ កាសិក្សាលើប្រធានបទនេះ គឺផ្សារភ្ជាប់លើការយកចិត្តទុកដាក់លើកុមារជាពិសេស លក្ខខណ្ឌនៃការបង្កើត អ្នកទទួលបន្ទុកក្នុងការបង្កើតអាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងនីតិវិធីពិសេសសម្រាប់ការបង្កើតស្មុំកូនអន្តរប្រទេសនេះ។

## ខ. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីងាយស្រួលដល់ការសិក្សាលើប្រធានបទស្តីពី "**ស្មុំកូនអន្តរប្រទេស**" គប្បីជ្រាបពីឆ្អឹងខ្នងនៃការស្រាវជ្រាវនេះ ដូចខាងក្រោម ៖

**ជំពូកទី១ ទស្សនៈទានទូទៅនៃស្មុំកូនអន្តរប្រទេស**

**ជំពូកទី២ នីតិវិធីនៃការបង្កើតស្មុំកូនអន្តរប្រទេស**

**ជំពូកទី៣ ផលវិជ្ជមាន និងអវិជ្ជមាននៃស្មុំកូនអន្តរប្រទេស**

# ជំពូកទី១

# ទស្សនៈទានទូទៅនៃស្មុំក្លួន

# អន្តរប្រទេស

# ជំពូកទី១

# ទស្សនៈទានទូទៅនៃស្មុំកូនអន្តរប្រទេស

ជាទូទៅ ស្មុំកូនអន្តរប្រទេសត្រូវប្រកាន់ភ្ជាប់នូវខ្លឹមសារជាសារជាតុរួមមាន **គោលការណ៍ទូទៅនៃស្មុំកូនអន្តរប្រទេស (កថាភាគទី១)** ដើម្បីសម្រេចតាម**គោលបំណងនៃការបង្កើតស្មុំកូនអន្តរប្រទេស (កថាភាគទី២)** ដោយយកចិត្តទុកដាក់ជាពិសេសលើឧត្តមប្រយោជន៍របស់កុមារ (កូនសុំ) ជាអាទិ៍ ហើយពិសេសត្រូវធានាពីទម្រង់ដ៏ត្រឹមត្រូវនៃការបង្កើត ដែលត្រូវគោរពតាមនីតិវិធីនៃស្មុំកូនអន្តរប្រទេសជាដាច់ខាត។ ម្យ៉ាងវិញទៀតការបង្កើតស្មុំកូនអន្តរប្រទេសត្រូវភ្ជាប់នូវ**ការវិវត្តន៍នៃនីតិស្មុំកូនអន្តរប្រទេស (កថាភាគទី៣)** ជាដំណាក់កាលៗ ដើម្បីឈានដល់ការស្វែងយល់លើ**លក្ខខណ្ឌសម្រាប់ស្មុំកូនអន្តរប្រទេស (កថាភាគទី៤)** ឱ្យមានលក្ខណៈសមស្របច្បាស់លាស់ ក្នុងការបង្កើតដែលនាំឱ្យកុមារដែលជាកម្មវត្ថុនៃការស្មុំកូនអន្តរប្រទេស ពិតជាទទួលបានគ្រួសារអចិន្ត្រៃយ៍មួយ ដោយគ្មានការបំពារពាន ការកេងប្រវ័ញ្ចលើកុមារ។ លើសពីនេះទៀត បង្ហាញពី**អាជ្ញាធរមានសមត្ថកិច្ចលើប្រតិបត្តិការបង្កើតស្មុំកូនអន្តរប្រទេស (ផ្នែកទី២)** នេះ ក្នុងអត្ថបទនេះ។

## ផ្នែកទី១ ៖ សញ្ញាណទូទៅនៃការស្មុំកូនអន្តរប្រទេស

ជាចេតនា ការបង្កើតឱ្យមានរបបនៃការស្មុំកូនអន្តរប្រទេស គឺមានវត្ថុបំណងគោរពនូវគោលការណ៍សិទ្ធិមនុស្ស ពិសេសលើសិទ្ធិជាមូលដ្ឋានដែលគ្មាននរណាម្នាក់ត្រូវបានដកហូត ឬត្រូវបានរំលោភបំពានឡើយ។[1] ជាការកត់សម្គាល់ការបង្កើតរបបនេះឡើងមក គឺចង់បង្កនូវភាពងាយស្រួល ទទួលបានភាពស្របច្បាប់ក្នុងការស្មុំទារកកំព្រា ឬកុមារកំព្រា ឬកុមារដែលរងគ្រោះទៅចិញ្ចឹមជាកូននៅបរទេសជាអចិន្ត្រៃយ៍ ហើយមានភាពស្របច្បាប់លើគ្រប់ភាគីដែលបានចូលរួមបង្កើតជាអាទិ៍ ទាំងឪពុកម្តាយបង្កើត ទាំងអ្នកសុំ ហើយជាពិសេសទៀត គឺបានសិក្សាពីឧត្តមប្រយោជន៍របស់កុមារ ក្នុងរបបនៃការស្មុំកូនអន្តរប្រទេសមួយនេះ។ លើសពីនេះ ការសិក្សាលើស្ថានភាពពិតប្រាកដពីលក្ខខណ្ឌសារជាតុ ដែលបានកំណត់យ៉ាងប្រត្យក្សពីសិទ្ធិ និងកាតព្វកិច្ចនីមួយៗរបស់ភាគីចូលរួមមិនថា ឪពុកម្តាយបង្កើត ឬ អ្នកសុំ ឬកូនសុំ និងទម្រង់បែបបទនៃនីតិវិធីស្មុំកូនអន្តរប្រទេស។

ជាគោលការណ៍ ការបង្កើតបាននូវរបបស្មុំកូនអន្តរប្រទេសនេះគឺដាច់ខាត ត្រូវតែគោរពទៅតាមគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ ដើម្បីឱ្យការស្មុំកូនអន្តរប្រទេសបង្កើតឡើងនូវអានុភាពតាមផ្លូវច្បាប់ ដោយធានាបាននូវឧត្តមប្រយោជន៍របស់កុមារដែលត្រូវស្មុំយកទៅចិញ្ចឹម រីឯការចិញ្ចឹមបីបាច់ត្រូវតែមានភាពល្អប្រសើរជំនួសស្ថានភាពចាស់។ ដើម្បីកាន់ងាយយល់ពីខ្លឹមសាររបស់ប្រធានបទ គឺគប្បីស្វែងយល់ពី**គោលការណ៍**

[1] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុម័ត និងប្រកាសដោយសេចក្តីសម្រេចចិត្តនៃមហាសន្និបាតអង្គការសហប្រជាជាតិលេខ ២១៧ A(III) ថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨

**ទូទៅនៃសុំកូនអន្តរប្រទេស (កថាខណ្ឌទី១) ដំណើរការវិវត្តន៍នៃនីតិសុំកូនអន្តរប្រទេស (កថាខណ្ឌទី២) និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស (កថាខណ្ឌទី៣)។**

### កថាភាគទី១ ៖ គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

ភាពចាំបាច់នៃការបង្កើតនូវសុំកូនអន្តរប្រទេស គឺត្រូវតែគោរពជាដាច់ខាត់នូវគោលការណ៍មូលដ្ឋាន ដែលជាសសរគ្រឹះនៃរបបសុំកូនអន្តរប្រទេស បើមិនដូច្នោះទេ ទោះបីមានការដំណើរការសុំកូនរហូតដល់ចប់បរិបូណ៌ក៏ឥតន័យ គឺពិតជាមិនបានបង្ហាញថា ការធានាដល់ឧត្តមប្រយោជន៍របស់កុមារ ថាពិតជាកើតមាននោះទេពិសេស គឺប្រឈមមុខនឹងការបរាជ័យ ឬការបញ្ឈប់ការសុំកូនអន្តរប្រទេសជាក់ជាមិនខាន។ ហេតុនេះ ច្បាប់ស្ដីពីសុំកូនអន្តរប្រទេស បានចែងពីគោលការណ៍ទូទៅក្នុងប្បញ្ញត្តិនៃមាត្រា ៥ ដូចតទៅ ៖

១– កុមារត្រូវចំរើនការធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល មានសេចក្ដីស្រឡាញ់ និងការយោគល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និងយ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្ដល់ក្នុងការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមារ រស់នៅក្នុងគ្រួសារកំណើត និងក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២– សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាជាសុំកូនពេញលេញ ដែលបង្កើតទំនាក់ទំនងរវាងអ្នកសុំ និងកូនសុំអចិន្ត្រៃយ៍ដែលអាចផ្ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹមនោះ។

៣– កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈសង្គម ធនធាន ពិការភាព ឬស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬរបស់ឪពុកម្ដាយ ឬរបស់ឪពុក ឬរបស់ម្ដាយ ឬរបស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

៤– រាល់សេចក្ដីសម្រេច និងសកម្មភាពទាក់ទននឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ។

៥– តុលាការ និងអាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថា នៅកំពុងដំណើរនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចដឹងខុសត្រូវបានពិគ្រោះយោបល់ និងពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាពនានាដែលកើតចេញពីសុំកូននេះ ដោយគិតគូរដល់សេចក្ដីប្រាថ្នា និងមតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ។

៦– ហាមធ្វើអាជីវកម្ម ឬធ្វើសកម្មភាពយកកំរៃពីសុំកូនអន្តរប្រទេស។ អាជីវកម្ម ឬសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន ៖

➢ អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬឪពុក ឬម្តាយឱ្យបោះបង់ទារកដែលកើតមកហើយ ឬដែលនឹងកើត ដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស។

➢ អំពីប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្រីម្នាក់យល់ព្រមពពោះ ដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ។

៧– អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេសត្រូវធានាថា ដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និងត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និងការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស។ មានតែប្រាក់ចំនេញ សោហ៊ុយ និង វិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់[2]។

## កថាភាគទី២ ៖ គោលបំណងនៃការបង្កើតសុំកូនអន្តរប្រទេស

គោលបំណងនៃការបង្កើតសុំកូនអន្តរប្រទេស គឺធានាការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពិចារណាអំពីស្ថានភាពរបស់កុមារ (បុគ្គលិកលក្ខណៈរបស់កុមារ ដូចជា ភាពរីកចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ សុភមង្គល សេចក្តីស្រឡាញ់ និងកិត្តិយស)។ ជាអាទិភាព រដ្ឋត្រូវចាត់វិធានការសមស្របដើម្បីឱ្យកុមារស្ថិតក្នុងការបីបាច់ថែរក្សាពីសំណាក់គ្រួសារកំណើតរបស់កុមារ ក៏ប៉ុន្តែករណីដែលចាំបាច់ ទារក ឬកុមារដែលត្រូវការនូវការថែទាំពិសេស ឬកុមារដែលត្រូវបោះបង់ចោល ឬកុមារដែលស្ថិតនៅក្រោមការថែទាំជំនួស មិនអាចទទួលបានការស្វែងរកគ្រួសារអចិន្ត្រៃយ៍នោះទេ (ក្រោយពីការបង្កើតសុំកូនក្នុងស្រុកមិនទទួលបានជោគជ័យ) ដើម្បីការពារ និងផ្តល់នូវឧត្តមប្រយោជន៍របស់កុមារ រដ្ឋដែលមានទំនាក់ទំនងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស អាចទទួលស្គាល់ ឬបង្កើតប្រតិបត្តិការសុំកូនអន្តរប្រទេសបាន។ ស្របគ្នានេះ ដើម្បីការពារសិទ្ធិជាមូលដ្ឋានរបស់កុមារដែលបានបង្កើតសុំកូនក្រោមការបង្ខិតបង្ខំ ឬការលក់ ឬការជួញដូរដោយផ្ទុយច្បាប់។[3]

អនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាត្រង់មាត្រា ៤៨ បានចែងថា រដ្ឋធានាការពារសិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ...។

[2] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា ៥

[3] *បុព្វហេតុ* អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស អនុម័តនាថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៣

អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ មាត្រា ២១ បានចែងថា រដ្ឋជាភាគីទទួលស្គាល់ និងឬអនុញ្ញាតនូវប្រព័ន្ធសុំកូនចិញ្ចឹម ត្រូវធានាថា ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ គឺជាមូលដ្ឋានចំបងនៅក្នុងបញ្ហានេះ។

ដោយផ្អែកតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា សម្រាប់នីតិកាលទី៣នៃរដ្ឋសភាបានចែងជាអាទិ៍ថា រាជរដ្ឋាភិបាលប្តូរផ្តាច់ដាក់ចេញនូវវិធានការគ្រប់បែបយ៉ាង ដើម្បីទប់ស្កាត់អំពើគាបសង្កត់ អំពើពេស្យាចារលើកុមារ ការជួញដូរកុមារ ការពង្រឹងការអនុវត្តន៍ច្បាប់ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។[4]

ដោយអនុលោមស្តីពីអនុសញ្ញាទីក្រុងឡាអេបានបង្កើតនូវគោលបំណងដូចខាងក្រោម៖

- បង្កើតមធ្យោបាយការពារដើម្បីធានាថា ការសុំកូនអន្តរប្រទេស ធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារ និងដោយសេចក្តីគោរពចំពោះសិទ្ធិជាមូលដ្ឋានរបស់កុមារដូចបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ។
- បង្កើតប្រព័ន្ធសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាភាគីដើម្បីធានាថា មធ្យោបាយការពារទាំងនោះត្រូវបានគោរពហើយតាមរយៈប្រព័ន្ធនោះទប់ស្កាត់ការចាប់ពង្រាត់ការលក់ ឬការជួញដូរកុមារ។
- ធានាឱ្យមានការទទួលស្គាល់នៅក្នុងរដ្ឋភាគី សុំកូនត្រូវប្រព្រឹត្តទៅស្របតាមអនុសញ្ញានេះ។
- អនុសញ្ញានេះ ត្រូវអនុវត្តនៅក្នុងករណីកុមារម្នាក់មានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋជាភាគីមួយ (រដ្ឋដើម) ត្រូវបានកំពុង ឬនឹងត្រូវបានយករដ្ឋជាភាគីមួយទៀត (រដ្ឋទទួល) ក្រោយពីការសម្រេចសុំកូនដោយសហព័ទ្ធ ឬដោយជនម្នាក់ដែលមានទីលំនៅទៀងទាត់នៅក្នុងរដ្ឋទទួលប្រព្រឹត្តទៅនៅក្នុងរដ្ឋដើម ឬក្នុងគោលបំណងសុំកូន ការសម្រេច សុំកូនធ្វើឡើងនៅក្នុងរដ្ឋទទួលក្តី ឬរដ្ឋដើមក្តី។[5]

ស្របគ្នានេះ ផ្អែកតាមអត្ថបទច្បាប់ស្តីពីសុំកូនអន្តរប្រទេសរបស់កម្ពុជាបានបញ្ញត្តិទុកផងដែរថា ការបង្កើតសុំកូនអន្តរប្រទេសគឺ ធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស។[6]

ក្រោមក្របនៃប្រធានបទស្តីពីសុំកូនអន្តរប្រទេសនេះ នាំឱ្យទាញបានជាមូលហេតុនៃសុំកូនអន្តរប្រទេសដូចខាងក្រោម ៖

[4] សេចក្តីថ្លែងហេតុនៃ សេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេស, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ២៧ កញ្ញា ២០០៥

[5] បុព្វហេតុ អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស អនុម័តនាថ្ងៃទី២៩ ខែឧសភា ឆ្នាំ១៩៩៣

[6] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា ២

១–មូលហេតុដែលកើតចេញពីបុគ្គលដែលមានឋានៈខ្ពស់ (អ្នកសុំ)

- ការបន្តមត៌ក ៖ បុគ្គលដែលមានឋានៈខ្ពស់ ជាបុគ្គលដែលមានទ្រព្យសម្បត្តិ បារម្ភពីការស្នងមត៌ករបស់ខ្លួន និងចង់ស្វែងរកអ្នកទទួលបន្ត។
- គ្មានកូន ឬកូនមិនសមបំណង ៖ បុគ្គលដែលគ្មានកូនសូម្បីម្នាក់ អាចស្នើសុំ ឬបុគ្គលដែលមានកូនរួចហើយ តែកូននោះ មិនសមបំណង ករណីភេទជាអាទិ៍។

២–មូលហេតុដែលកើតចេញពីបុគ្គលដែលមានឋានៈទាប (អ្នកផ្តល់ការយល់ព្រម)

- កន្លែងខ្វះជីវភាព ៖ បុគ្គលដែលមានឋានៈទាប ច្រើនជួបប្រទះបញ្ហាជីវភាព ក្នុងការមើលថែទាំកុមារ ឬបញ្ហាផ្សេងៗទៀត ជាកត្តាជំរុញឱ្យផ្តល់ការយល់ព្រម។
- មនោសញ្ចេតនា ៖ ការយល់ព្រមដោយពិចារណាលើឧត្តមប្រយោជន៍របស់កុមារ។

**កថាភាគទី៣ ៖ ដំណើរការវិវត្តនៃនីតិសុំកូនអន្តរប្រទេស**

ការសុំទារកកំព្រា ឬកុមារកំព្រានៅកម្ពុជាបានអនុវត្តចាប់ពីឆ្នាំ១៩៨៧ តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ ៧៩ សសរ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៨៧។ អ្នកស្នើសុំកុមារកម្ពុជា ពេលនោះភាគច្រើនជាបុគ្គលិករបស់អង្គការអន្តរជាតិ ឬអង្គការមិនមែនរដ្ឋាភិបាល ដែលបំពេញបេសកកម្មនៅកម្ពុជាដោយចិត្តអាណិតស្រឡាញ់ទារក ឬកុមារកំព្រាកម្ពុជា ហើយពេលត្រឡប់ទៅវិញគេបានសុំទារក និងកុមារំព្រាយកទៅចិញ្ចឹម ដោយអនុវត្តតាមនីតិវិធីជាធរមាន។

នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៨ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ត្រូវបានរដ្ឋសភាកម្ពុជាអនុម័ត និងដាក់ឱ្យប្រើប្រាស់។ រដ្ឋាភិបាលបានចេញសេចក្តីណែនាំលេខ ៥៤៩ សជណ ផក ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៩១ ស្តីពីនីតិវិធីការងារសុំកូនចិញ្ចឹម តាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ។

ចាប់ពីឆ្នាំ១៩៩១-២០០០ ការងារសុំកូនចិញ្ចឹមពីកម្ពុជា ត្រូវបានចាប់អារម្មណ៍កាន់តែខ្លាំងឡើងៗ ពីពលរដ្ឋនៃប្រទេសនានាមួយចំនួនរួមមាន អាមេរិក បារាំង កាណាដា អូស្ត្រាលី អាល្លឺម៉ង់ អ៊ីតាលី...។ល។ រដ្ឋាភិបាលបានពង្រឹងនីតិវិធីសុំកូន ហើយចាប់ពីឆ្នាំ១៩៨៩ ដល់២០០៥ កុមារកំព្រាសរុប ២៦៣៣នាក់ ក្នុងនោះកុមារី ចំនួន ១៤៥៧នាក់ ត្រូវបានសុំយកទៅចិញ្ចឹមនៅប្រទេស។ ដើម្បីពង្រឹងបន្ថែមនីតិវិធីសុំកូនអន្តរប្រទេស រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យលេខ ២៩ អនុក្របក ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០១ ប្រគល់ភារកិច្ចឱ្យក្រសួងមានសមត្ថកិច្ចមួយចំនួន រួមមាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងទីស្តីការគណៈរដ្ឋមន្ត្រីអនុវត្តនីតិវិធី និងបែបបទសុំកូនអន្តរប្រទេស។

ប៉ុន្តែ ផ្អែកតាមបទដ្ឋានអង្គការសហប្រជាជាតិ និងអនុសញ្ញាក្រុងឡាអេ តម្រូវឱ្យមានច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ដោយរង់ចាំច្បាប់នេះ និងដោយមានព័ត៌មានស្តីការជួញដូរកុមារ រួមនឹងសកម្មភាពខុសច្បាប់របស់ទីភ្នាក់ងារបរទេសមួយចំនួននៅប្រទេសខ្លះ បានធ្វើឱ្យប្រទេសមួយចំនួនព្យួរដំណើរការសុំកូនអន្តរប្រទេសជាមួយកម្ពុជាដោយឯកតោភាគី។ ទន្ទឹមនឹងនេះ នៅមានប្រទេសជាច្រើនកំពុងបន្តការសុំកូនពីកម្ពុជា ដូច្នេះយើងមិនបានបិទទ្វារចំពោះប្រទេសណាមួយឡើយ ហើយស្វាគមន៍ចំពោះកិច្ចសហការលើការងារសុំកូនអន្តរប្រទេសជាមួយប្រទេសទាំងអស់។ ច្បាប់នេះមិនតម្រូវចិត្តប្រទេសណាមួយទេ តែនេះជាតម្រូវការចាំបាច់នៃនីតិវិធីសុំកូនអន្តរប្រទេស និងដើម្បីឧត្តមប្រយោជន៍នៃកុមារកម្ពុជា[7]។

## កថាភាគទី៤៖ លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស

មុននឹងឈានដល់ការលើកឡើងពីលក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេសនេះ គប្បីស្វែងយល់ពីខ្លឹមសារនៃសុំកូនអន្តរប្រទេសជាមុនសិន ៖

### ១. និយមន័យសុំកូនអន្តរប្រទេស

សុំកូន គឺជាកិច្ចសន្យា ដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថា ឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ហើយម្នាក់ទៀតហៅថា កូនចិញ្ចឹមឱ្យមានចំណងនឹងគ្នា ដូចជាបុត្តភាពមានខាន់ស្លា។[8]

សុំកូនអន្តរប្រទេស គឺជាការសុំទារក ឬកុមារកំព្រាសញ្ជាតិកម្ពុជា មានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយប្តីប្រពន្ធ ដែលរស់នៅក្នុងប្រទេសផ្សេងទៀត ដើម្បីកាត់យកទៅចិញ្ចឹមជាកូន ហើយនិងទទួលស្គាល់ដោយច្បាប់របស់ប្រទេសនោះ។ សុំកូនអន្តរប្រទេសអាចអនុញ្ញាតបានបន្ទាប់ពីអាជ្ញាធរកម្ពុជា បានប្រឹងប្រែងឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើតវិញ ឬក៏រកលក្ខណៈសម្បត្តិសុំកូនក្នុងស្រុកជាមុនរួចហើយ។ សុំកូនអន្តរប្រទេសត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីសុំកូនអន្តរប្រទេស។[9]

ការសុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបាន លុះត្រាតែជាការសុំកូនអន្តរប្រទេសពេញលេញ ដែលបានបង្កើតឡើងនូវទំនាក់ទំនងរវាងអ្នកសុំ និងកូនសុំជាអចិន្ត្រៃយ៍ និងដែលបានផ្តល់ដល់កូននោះនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះដែរ។ ការបង្កើតឡើងនូវទំនាក់ទំនងខាងលើនេះ អាចធ្វើទៅបានចំពោះតែកុមារដែលមានសញ្ជាតិខ្មែរ និងជនបរទេសតែប៉ុណ្ណោះ។[10]

---

[7] សេចក្តីថ្លែងហេតុនៃសេចក្តីព្រាងច្បាប់សុំកូន អន្តរប្រទេសរបស់ក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, កញ្ញា ២០០៥

[8] ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ, ២៧ កក្កដា ១៩៩៨

[9] លោក ខន សុខេង, សៀវភៅ ស្តីពី *ការសុំកូន,* (ភ្នំពេញ៖ ចំណារ, ២០២០), ទំព័រទី៤១

[10] គេហទំព័រចំណេះដឹងផ្នែកច្បាប់( legal Knowledge), *លក្ខខណ្ឌនៃការបង្កើតសុំកូនអន្តរប្រទេស (នីតិបេតិកភណ្ឌ និងគ្រួសារ),* https://knowledgelegalkrn.blogspot.com/2017/04/blog-post_52.html(ថតចម្លងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០)

ចំពោះជនបរទេស ដែលមានបំណងសុំកុមារកម្ពុជាទៅចិញ្ចឹម គឺត្រូវបំពេញតាមលក្ខខណ្ឌដោយឡែក (ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស)[11]។

### ២. លក្ខខណ្ឌគ្រឹះសម្រាប់ស្មុំកូនអន្តរប្រទេស

ការបង្កើតស្មុំកូនអន្តរប្រទេសមួយបាន លុះត្រាតែបានបំពេញនូវលក្ខខណ្ឌ ដែលច្បាប់បានកំណត់គ្រប់គ្រាន់ ត្រឹមត្រូវតាមច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស។ ប្រការនេះ គួរស្វែងយល់លើលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីស្មុំកូនអន្តរប្រទេសជាចម្បង ដោយចាប់ផ្តើមពីលក្ខខណ្ឌរបស់ **កូនសុំ (២.១) ការយល់ព្រមលើស្មុំកូន (២.២)** ក្នុងករណីដែលកូនសុំនោះមានអ្នកមានអំណាចមេបា ឬអាណាព្យាបាល និង**អ្នកសុំ (២.៣)**។

#### ២.១. កូនសុំ

កុមារដែលជាកម្មវត្ថុនៃការស្មុំកូនអន្តរប្រទេស ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ដូចខាងក្រោម ៖

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

២- កុមារអាយុក្រោម ៨ (ប្រាំបី)ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែក្នុងករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ។ ក្នុងករណីមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី)ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះ រួមជាមួយនឹងបងប្អូនបង្កើត ដែលមានអាយុក្រោម ១៨ឆ្នាំ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

៤- កុមារទាំងនោះស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬកុមារដែលស្ថិតនៅក្រោមអំណាចមេបា ដែលមានស្ថានភាពលំបាកបំផុត។[12]

៥- កុមារទាំងអស់នោះត្រូវបានប្រកាសថា អាចសុំជាកូនចិញ្ចឹមបានដោយអនុលោមតាមមាត្រា ១៣ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស "ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឱ្យអស់ពីលទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈស្មុំកូនក្នុងស្រុកនៅក្នុង

[11] លោកមេធាវី ឡាន ស៊ីនិត និងកញ្ញា សារី លីដា, *ការស្មុំកូន,* http://freshnewsasia.com/index.php/en/localnews/99195-2018-09-16-04-46-39.html (ចតចម្លងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០)

[12] ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ យោងតាមមាត្រា ១២ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ឆ្នាំ២០០៩

ប្រទេសកម្ពុជា មុននឹងពិនិត្យរកលក្ខណសម្បត្តិសុំកូនអន្តរប្រទេស ដោយត្រូវបញ្ចូលឈ្មោះទៅក្នុងបញ្ជីស្ដីពីកុមារដែលកំណត់ថាមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស”។

ថ្វីបើមានការលើកឡើងនូវលក្ខខណ្ឌចម្បងសម្រាប់ការបង្កើតសុំកូនអន្តរប្រទេសចំពោះកុមារជាទូទៅ ក៏នូវមានលក្ខខណ្ឌដោយឡែកផងដែរ សម្រាប់កុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារដែលមានតម្រូវការពិសេស។

❖ **លក្ខខណ្ឌដោយឡែកសម្រាប់កុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារដែលមានតម្រូវការពិសេស**[13] **៖**

១. កុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. កុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលពាក្យសុំកូន។

៣. កុមារដែល ៖

ក. កំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ

ខ. កំពុងរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

គ. កំពុងស្ថិតក្រោមការថែទាំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបា ដែលត្រូវការជំនួយដោយសារមានស្ថានភាពលំបាក និងស្ថានភាពប្រឈមនឹងគ្រោះថ្នាក់[14]។

❖ **ករណីកុមារដែលត្រូវបោះបង់ចោល ឬកុមារកំព្រា**

ករណីកុមារត្រូវបានរកឃើញ និងបញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានកុមារកំព្រាត្រូវជូនដំណឹងនៅមន្ទីរទទួល

---

[13] ១. កុមារដែលត្រូវការនូវការថែទាំពិសេស សំដៅដល់កុមារ ពិការផ្នែកកាយសម្បទាធ្ងន់ធ្ងរ និងពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ។
២. កុមារមានតម្រូវការពិសេស សំដៅដល់៖
ក. កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ មានវិបត្តិផ្លូវអារម្មណ៍ និងវិបត្តិអាកប្បកិរិយា ឬ
ខ. កុមារដែលមានអាយុក្រោម ១៨ ឆ្នាំ និងមានបងប្អូនបង្កើតយ៉ាងតិចម្នាក់ដែលមានអាយុក្រោម ៨ ឆ្នាំ។

[14] ប្រកាសលេខ១៣៩ ស.អ.យ. ស្ដីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស, ប្រការ៦ និង៧

បន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌលយ៉ាងយូរបំផុតរយៈពេល ៧ថ្ងៃគិតពីពេលដែលកុមារមកដល់មណ្ឌល។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្តីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាមុននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈទៅតាមលទ្ធភាព។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន។[15]

បន្ទាប់ពីផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត ត្រូវធ្វើរបាយការណ៍ ស្តីពីការខិតខំប្រឹងប្រែងស្រាវជ្រាវនេះ ហើយត្រូវធ្វើសារមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញរហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត គឺអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន។[16]

អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គឺត្រូវអនុលោមតាមបញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនក្នុងក្រមរដ្ឋប្បវេណី ៖

១. អ្នកដែលអនុវត្តអំណាចមេបាចុងក្រោយបង្អស់ចំពោះអនីតិជន អាចកំណត់អ្នកអាណាព្យាបាលសម្រាប់អនីតិជនបាន តាមមតកសាសន៍។

២. តុលាការអាចត្រូវជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជន តាមការទាមទាររបស់ញាតិក្នុង ៤ ថ្នាក់ របស់អនីតិជន មេឃុំ ឬចៅសង្កាត់នៃលំនៅឋានរបស់អនីតិជន នាយកមជ្ឈមណ្ឌលសាធារណៈសម្រាប់សុខុមាលភាពកុមារ ឬតំណាងអយ្យការបាន បើសិនករណីខាងលើមិនអាចធ្វើបាន។[17]

[15] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា ១១

[16] អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ។

### ២.២. ការយល់ព្រមលើសុំកូន

#### ២.២.១. គោលការណ៍នៃការយល់ព្រមលើកូនសុំ

ការយល់ព្រមលើសុំកូន គឺសំដៅទៅលើការផ្តល់នូវការយល់ព្រមដោយផ្ទាល់ទៅលើការសុំកូន ការបង្ហាញឆន្ទៈជាធាតុអត្តនោម័តដែលអ្នកមានសិទ្ធិត្រូវធ្វើការបង្ហាញការយល់ព្រមនេះ ដើម្បីឱ្យដំណើរការសុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបាន ដោយមានភាពត្រឹមត្រូវស្របតាមច្បាប់។ គួរបញ្ជាក់ផងដែរថា មិនគ្រប់សំណុំរឿងសុំកូនអន្តរប្រទេសគឺសុទ្ធតែមានការយល់ព្រមទេ តែចំពោះការយល់ព្រមដែលត្រូវការជាចាំបាច់ត្រូវតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារទៅតាមករណីដូចខាងក្រោម ៖

ក-ក្នុងករណីមានចំណងបុត្តភាពជាមួយឪពុក និងម្តាយការយល់ព្រមត្រូវផ្តល់ដោយឪពុក និងម្តាយរបស់កុមារ។

ខ-ក្នុងករណីដែលឪពុក ឬម្តាយណាមួយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតពីអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុកម្តាយ ឬម្តាយតែម្ខាង ដែលមានអំណាចមេបាជាការគ្រប់គ្រាន់។

គ-ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបាយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ។[18]

ចំពោះការយល់ព្រមនេះ គឺជាការយល់ព្រមដែលធ្វើឡើងដោយសេរី និងច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយឡើយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬការសន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬផលប្រយោជន៍ណាមួយឡើយ និងដោយបានដឹងច្បាស់អំពីវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះការសុំកូនអន្តរប្រទេស។[19] ម៉្យាងវិញទៀត ចំពោះការយល់ព្រមនេះ ត្រូវធ្វើឡើងជាទម្រង់ជាលាយលក្ខណ៍អក្សរចំពោះមុខ មេឃុំ ឬចៅសង្កាត់ផងដែរ។

ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិនមុននឹងផ្តល់ការយល់ព្រម។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវប្រាប់យ៉ាងច្បាស់លាស់ដល់អ្នក ដែលត្រូវផ្តល់ការយល់ព្រមការបញ្ចប់នូវបុត្តភាពព្រមទាំងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន

[17] ក្រមរដ្ឋប្បវេណី, នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧, មាត្រា ១០៦៨

[18] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា ១៤

[19] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា១៥

និងត្រូវប្រាប់ពីបែបបទ និងរយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ភ្នាក់ងារសង្គមកិច្ចត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការសម្ភាសរបស់ខ្លួនជាមួយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

ទោះបីក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងលើទីលំនៅរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ។

មេឃុំ ឬចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាការយល់ព្រមដែលគោរពទៅតាមឆន្ទៈដោយសេរី និងច្បាស់លាស់ដែលបានកំណត់ខាងលើ។

មេឃុំ ឬចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការយល់ព្រមនេះ ហើយបានពិនិត្យថាភ្នាក់ងារសង្គមកិច្ច មានសង្គមកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងបានប្រាប់យ៉ាងត្រឹមត្រូវអំពីអនុភាពនៃការយល់ព្រមនេះ។[20]

ដើម្បីអនុញ្ញាតឱ្យអ្នកមានសិទ្ធិយល់ព្រមលើការបង្កើតសុំកូនអន្តរប្រទេស ក៏ដូចជាឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអ្នកមានអំណាចមេបាមានកាតព្វកិច្ច គឺត្រូវធ្វើការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ចជាមុន តាមទម្រង់ជាលាយលក្ខណ៍អក្សរក្នុងកំណត់ហេតុ ដើម្បីយល់កាន់តែច្បាស់លើផលវិបាក និងការបញ្ចប់នូវបុត្តភាពតាមអានុភាពនៃសុំកូនអន្តរប្រទេសនេះ។

### ២.២.២. ការបញ្ឈប់ការយល់ព្រមលើសុំកូន

ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារអាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មានសេចក្តីសម្រេចរបស់តុលាការស្តីអំពីសុំកូន ជាស្ថាពរ។ ការបញ្ឈប់ការយល់ព្រមឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់នៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន។ មេឃុំ ឬចៅសង្កាត់ខាងលំនៅឋានរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកលើវិស័យសង្គមកិច្ចរាជធានី-ខេត្ត ប្រធានមណ្ឌល

[20] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា ១៦

កុមារកំព្រា ដែលពាក់ព័ន្ធនឹងត្រូវប្រគល់កំណត់ហេតុចម្លង ដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះទៅឱ្យឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ។[21]

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ហាញឆន្ទៈដែលមានវិការៈឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលការយល់ព្រមរបស់ខ្លួន រហូតដល់មុនដីកាសម្រេចរបស់តុលាការលើសុំកូនចូលជាស្ថាពរ។[22]

### ២.២.៣. ការដកហូតអំណាចមេបា

ករណីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចប្តឹងឱ្យតុលាការប្រកាសការដកហូតអំណាចមេបាពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យប៉ះពាល់ផលប្រយោជន៍របស់កុមារ ឬបណ្តាលឱ្យប៉ះពាល់ដល់សុខភាព ឬសីលធម៌របស់កុមារ។ ពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធ ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន។

### ២.៣. អ្នកសុំ

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌដូចតទៅ៖

១- អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុ ៣០ (សាមសិប) ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច ២២ (ម្ភៃពីរ) ឆ្នាំ និងយ៉ាងច្រើនបំផុត ៤៥ (សែសិបប្រាំ) ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន។

២- ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណី សុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យបានក្នុងស្ថានភាពដូចតទៅ ៖

ក- អ្នកសុំមានដើមកំណើតជាជនជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ- អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត។

គ- អ្នកសុំអាចសុំកុមារដែលត្រូវការថែទាំពិសេស ឬស្ថានភាពផ្សេងទៀតដែលបម្រើឧត្តមប្រយោជន៍របស់កុមារ។

---

[21] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា១៧

[22] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២០

៣- ក្នុងករណីអ្នកសុំមានប្តី ឬប្រពន្ធការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំបង្កើតនៃសហព័ទ្ធម្ខាងទៀត។

៤- ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និងច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និងអនុញ្ញាតនូវបុត្តភាពនៃស្មុំកូនពេញលេញ។

៥- ប្រទេសនៃសញ្ជាតិ ឬប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។

៦- អ្នកសុំត្រូវមានលក្ខណសម្បត្តិ និងលក្ខខណ្ឌជាសារវន្តស្មុំកូនស្របទៅតាមច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍។

៧- អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬត្រូវកំពុងបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមាយាទ ឬការប្រព្រឹត្តបទឧក្រិដ្ឋកម្ម ឬមជ្ឈឹមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ។

៨- អ្នកសុំត្រូវតែអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និងការគាំទ្រយ៉ាងចាំបាច់ដល់កូនសុំ។

៩- អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបានលុះត្រាតែអ្នកសុំកូនគ្មានកូន ឬមានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំកូនអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតច្រើនទើបអ្នកសុំអាចសុំបានលើសពីមួយ ឬច្រើននាក់បាន។[23]

### ៣. ស្មុំកូនអន្តរប្រទេសដោយសាច់ញាតិ

ការស្មុំកូនអន្តរប្រទេសដោយសាច់ញាត់ ត្រូវបានបែងចែក**លក្ខខណ្ឌចំពោះកូនសុំ (៣.១)** ពិសេសជាការសុំយកកុមារដែលទូទៅដែលមិនមានជាប់ទំនាក់ទំនងញាតិជាមួយ**អ្នកសុំ (៣.២)** ផ្សារភ្ជាប់ននឹង**បែបបទនៃការស្នើសុំ(៣.៣)** ផ្សេងផងដែរ ហើយលក្ខខណ្ឌទាំងនោះ ដូចមានខាងក្រោម ៖

#### ៣.១. លក្ខខណ្ឌចំពោះកូនសុំ

ក. កុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ. កុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលពាក្យសុំកូន ហើយដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា[24]។

គ. កុមារមានស្ថានភាព ៖

---

[23] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា ២១

[24] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា ១០

–ត្រូវការជំនួយអាស្រ័យដោយស្ថានភាពលំបាក ឬស្ថានភាពប្រឈមគ្រោះថ្នាក់

–កំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀតដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

–កំពុងស្ថិននៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬស្ថិតនៅក្រោមអំណាចមេបាលំបាក។

ឃ.១. កុមារជាចៅ ចៅទួត ក្មួយ របស់អ្នកសុំ ឬ

ឃ.២. កុមារជាកូន ចៅ ចៅទួត ក្មួយ របស់សហព័ទ្ធរបស់ខ្លួន។

ក្នុងករណីកុមារដែលបានបំពេញលក្ខខណ្ឌទាំងអស់ខាងលើនៃប្រការនេះ ហើយមានបងប្អូនបង្កើតច្រើននាក់ ដែលមានអាយុក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ កុមារនោះ និងបងប្អូនបង្កើតអាចត្រូវបានពិចារណាឱ្យសុំយកទៅចិញ្ចឹមជាមួយគ្នា។[25]

➢ សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារជាកូនសុំអន្តរប្រទេសដោយសាច់ញាតិត្រូវមានដូចខាងក្រោម ៖

១. ប្រវត្តិរូបសង្ខេប (មានបិទរូបថត ៤ ស.ម x ៦ ស.ម ថតថ្មីមិនលើសពីរយៈពេលបីខែមុនប្រើប្រាស់)។

២. សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើតរបស់កុមារ និងសំបុត្របញ្ជាក់កំណើតរបស់អ្នកអាណាព្យាបាល ឬ ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយបង្កើតរបស់កុមារ។

៣. លិខិតបញ្ជាក់សុខភាព ចេញដោយវេជ្ជបណ្ឌិតមានសមត្ថកិច្ចធ្វើការក្នុងមន្ទីរពេទ្យរដ្ឋ ឬ គ្លីនិកឯកជនផ្សេងទៀតដែលរដ្ឋទទួលស្គាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. ឯកសារ ឬ ភស្តុតាងបញ្ជាក់អំពីអ្នកសុំត្រូវជាប់សាច់ញាតិជាមួយកុមារដែលអាចយកជាផ្លូវការដូចជាសៀវភៅគ្រួសារ ឬដីកា ឬសាលក្រមតុលាការ ឬឯកសារពាក់ព័ន្ធផ្សេងទៀតរបស់អ្នកសុំដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ឬប្រទេសដើមរបស់កុមារ។

៥. លិខិតយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវអនុវត្តតាមខ្លឹមសារក្នុងជំពូកទី៤ (លក្ខខណ្ឌសម្រាប់សុំកូន) ផ្នែកទី២ (ការយល់ព្រមលើសុំកូន) នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។[26]

[25] ប្រកាសលេខ១៣៨ ស.អ.យ. ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ, ២៣ មករា ២០១៤, ប្រការ៦ ទំព័រទី២ និងទី៣

[26] ប្រកាសលេខ១៣៨ ស.អ.យ. ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ, ២៣ មករា ២០១៤, ប្រការ៧ ទំព័រទី៣

**៣.២. លក្ខខណ្ឌចំពោះអ្នកសុំ**

អ្នកសុំដែលអាចអនុញ្ញាតឱ្យសុំកុមារជាសាច់ញាតិរបស់ខ្លួនយកទៅចិញ្ចឹមជាកូនបាន ត្រូវមានលក្ខខណ្ឌដូចតទៅៈ

១. អនុវត្តតាមខ្លឹមសារជំពូកទី៤ (លក្ខខណ្ឌសម្រាប់សុំកូន) ផ្នែកទី៣ (អ្នកសុំ) មាត្រា២១ (ចំណុច១-២ (ក-ខ)-៣-៤-៥-៦-៧-៨ និង៩) នៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស។

២. អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរសុំកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន។

ករណីកំពុងដំណើរការសុំកូន ប្រសិនបើសហព័ទ្ធដែលមានសញ្ជាតិខ្មែរដែលជាអនាគតឪពុក ឬ ម្ដាយចិញ្ចឹមបានស្លាប់ ឬ ស្ថិតនៅក្នុងភាពមិនអាចបង្ហាញឆន្ទៈបាន រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសួរបញ្ជាក់ទៅអ្នកសុំជាប្ដី ឬ ប្រពន្ធដែលជាអនាគតឪពុក ឬ ម្ដាយចិញ្ចឹមអំពីដំណើរការសុំកូនអន្តរប្រទេសត្រូវផ្អាក ឬបន្ត ហើយមានការយល់ព្រមពីកុមារដែលត្រូវសុំនោះផង (ក្នុងករណីកុមារអាចសម្ដែងឆន្ទៈបាន) ដោយត្រូវមានការឯកភាពពីអាជ្ញាធរនៃប្រទេសទាំងពីរ និងត្រូវគិតពីឧត្តមប្រយោជន៍របស់កុមារ។[27]

**៣.៣. បែបបទនៃការស្នើសុំ**

សំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នកសុំកូនអន្តរប្រទេសដោយសាច់ញាតិ មានដូចខាងក្រោម ៖

១– ពាក្យសុំកូន[28]។

២– លិខិតអនុញ្ញាតឱ្យសុំកូនចិញ្ចឹមចេញដោយអាជ្ញាធរកណ្ដាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំ ដោយមានបញ្ជាក់ថាកូនសុំត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសរបស់អ្នកសុំ។

---

[27] ប្រកាសលេខ១៣៨ ស.អ.យ. ស្ដីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ, ២៣ មករា ២០១៤, ប្រការ៨ ទំព័រទី៤

[28] ពាក្យសុំ ត្រូវសរសេរគ្រង់ទៅអាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយអ្នកសុំត្រូវបង្ហាញពីឆន្ទៈសុំកុមារ និងផ្ដល់ព័ត៌មានពេញលេញអំពីអត្តសញ្ញាណ អាសយដ្ឋានរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលកុមារដែលត្រូវសុំ។

សំណុំឯកសារទាំងអស់ត្រូវធ្វើជាប្រាំច្បាប់ដោយរក្សាទុកនៅៈ

– អាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំចំនួន ០១ច្បាប់
– ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់អ្នកសុំប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ច្បាប់
– ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ច្បាប់
– អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ច្បាប់ រួមទាំងការបកប្រែជាភាសាខ្មែរ
– ពាក្យសុំច្បាប់ដើម និងសំណុំឯកសារ ចំនួន ០១ច្បាប់បញ្ជូនទៅតុលាការរួមទាំងការបកប្រែជាភាសាខ្មែរ។

៣–របាយការណ៍ស្តីពីស្ថានភាពគ្រួសារដែលធ្វើដោយភ្នាក់ងារជំនាញ និងមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់អ្នកសុំ។

៤– សេចក្តីចម្លងសំបុត្រកំណើត ឬលិខិតបញ្ជាក់កំណើត។

៥– សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍។

៦– លិខិតបញ្ជាក់សុខភាពរបស់អ្នកសុំ។

៧–របាយការណ៍អំពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច។

៨– ភស្តុតាងដែលបញ្ជាក់ថាអ្នកសុំបានទទួលព័ត៌មានគ្រប់គ្រាន់ និងបានទទួលការប្រឹក្សាយោបល់។

៩– លិខិតបញ្ជាក់ថាគ្មានទោសចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសកំណើត ឬកន្លែងដែលអ្នកសុំរស់នៅចុងក្រោយ ឬលិខិតថ្កោលទោសចេញដោយតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចហើយនៅមានសុពលភាពប្រើប្រាស់។

១០– លិខិតបញ្ជាក់កិរិយាមាយាទ នៅកន្លែងប្រកបការងារ និងនៅក្នុងសង្គមរស់នៅរបស់អ្នកសុំចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

១១– លិខិតបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់អ្នកសុំចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

១២– កិច្ចសន្យាគោរពសិទ្ធិជាកូន ផ្តល់ការសិក្សា ព្រមទាំងសិទ្ធិផ្តល់កេរមរតកដូចកូនបង្កើតខ្លួន។

១៣– កិច្ចសន្យាស្តីពីការផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការវិវឌ្ឍរបស់កូនសុំមករដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំរៀងរាល់ ០៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ០៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ០១ (មួយ) ឆ្នាំម្តង រហូតដល់កូនសុំមានអាយុ១៨ (ដប់ប្រាំបី) ឆ្នាំ។

ឯកសារទាំងអស់ខាងលើ ត្រូវមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ឬ ប្រទេសរបស់អ្នកសុំកំពុងរស់នៅ។

ឯកសារទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬភាសាបារាំងដោយមានការបញ្ជាក់ត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច។

១៤– រូបថតរបស់អ្នកសុំ (ទំហំ៦ ស.ម x ៨ ស.ម) យកក្នុងអំឡុងពេលបីខែចុងក្រោយ។

១៥– ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់អ្នកសុំ។

១៦– រូបថតអ្នកសុំចំនួន ១០ សន្លឹក និងលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំជាមួយការពិពណ៌នា។[29]

## ផ្នែកទី២ ៖ អាជ្ញាធរមានសមត្ថកិច្ចក្នុងការសុំកូនអន្តរប្រទេស

ការប្រព្រឹត្តទៅនៃការសុំកូនអន្តរប្រទេសនេះ គឺតម្រូវជាចាំបាច់ តាមលក្ខខណ្ឌគតិយុត្តក្នុងការប្រតិបត្តិការ គឺត្រូវមានការចូលរួម ការប្រឹក្សាយោបល់ ការណែនាំពីសំណាក់អង្គភាពជំនាញដែលមានសមត្ថកិច្ចដែលបានទទួលនីតិសម្បទាតាមអំណាចដែលច្បាប់បានប្រគល់ឱ្យជាអាទិ៍ **អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស (កថាភាគទី១) រដ្ឋបាលសុំកូនអន្តរប្រទេស (កថាភាគទី២)** និង**ទីភ្នាក់ងារសុំកូនអន្តរប្រទេស (កថាភាគទី៣)**។

### កថាភាគទី១ ៖ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាស្របតាមមាត្រា ៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស[30]។

#### ១. ភារកិច្ចរបស់អាជ្ញាធររដ្ឋបាលកណ្តាលសុំកូនអន្តរប្រទេស

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចតទៅ ៖

១– រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ជា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស។

២– ធ្វើកិច្ចសហប្រតិបត្តិការ និងសម្របសម្រួលលើការប្រាស្រ័យទាក់ទងទៅនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយ ក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៣– ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្របឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៤– រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

[29] ប្រកាសលេខ១៣៨ ស.អ.យ. ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ, ២៣ មករា ២០១៤, ប្រការ៩ ទំព័រទី ៤ និងទី៥ នៃ

[30] ប្រកាសលេខ១៩៤ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា, ០៥ វិច្ឆិកា ២០១៣, ប្រការ ២

៥– ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។

៦– ធ្វើអធិការកិច្ចលើការងារទាំងឡាយដែលពាក់ព័ន្ធជាមួយសុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

៧– ចាត់វិធានការដ៏សមស្រប ដើម្បីប្រមូល រក្សាការពារ និងផ្លាស់ប្តូរព័ត៌មានអំពីស្ថានភាពរបស់កុមារ និងរក្សាទុកព័ត៌មានទាក់ទងនឹងប្រភពកំណើតរបស់កុមារ អត្តសញ្ញាណរបស់កុមារឪពុកម្តាយកុមារ និងប្រវត្តិសុខភាពកុមារ។

៨– រក្សា និងផ្តល់ស្ថិតិទាក់ទងនឹងសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសដល់ប្រទេសនានាតាមសំណើ។

៩– ទទួលប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាពីអ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

១០– ទទួលខុសត្រូវក្នុងការកត់ត្រា តាមដានប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើរបស់គណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌នៅរតនាគារជាតិ។

១១– ធ្វើរបាយការណ៍ស្តីពីស្ថានភាពប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ចូលក្នុងគណនីប្រាក់បញ្ញើនៅរតនាគាជាតិជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌។

១២– ពិនិត្យ ផ្តល់អនុសាសន៍ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសនីមួយៗទៅតុលាការ។

១៣– បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមតាមច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។[31]

[31] ប្រកាសលេខ១៩៤ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា, ០៥ វិច្ឆិកា ២០១៣, ប្រការ ៣

**២. គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស**

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានសមាសភាពដូចខាងក្រោម[32]៖

១– ឯកឧត្តម **វង សូត** រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ប្រធាន

២– ឯកឧត្តម **នឹម ថូត** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អនុប្រធាន

៣– ឯកឧត្តម **ឆាយ វណ្ណា** អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាសមាជិក

៤– ឯកឧត្តម **សំហេង បុរស** អគ្គនាយកនៃអគ្គនាយកកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ សមាជិក

៥– លោក **ម៉ែន សុចិត្រ** នាយកខុទ្ទកាល័យរដ្ឋមន្ត្រី សមាជិក

៦– អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ សមាជិក

៧– អ្នកជំនាញការជាតិលើវិស័យសុខុមាលភាពកុមារ សមាជិក

៨– លោក **អ៊ុំ សុផាន់ណារ៉ា** ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ សមាជិក

៩– លោក **វឿន រិទ្ធីរ័ត្ន** ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស អគ្គលេខាធិការ

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមាននីតិវិធីធ្វើការដូចជា បើកសម័យប្រជុំដើម្បីពិនិត្យឱ្យយោបល់លើករណីសុំកូននីមួយៗ និងពិនិត្យផ្តល់យោបល់ក្នុងការរៀបចំត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ជា និងនីតិវិធីទាំងឡាយទាក់ទងនឹងសុំកូនអន្តរប្រទេស និងអនុវត្តភារកិច្ចខាងលើ។

ការប្រជុំ និងការសម្រេចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាល សុំកូនអន្តរប្រទេសអាចយកបាន លុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច ៥0 ភាគរយ បូក១ (៥០%+១) នៃសមាជិកគណៈកម្មាធិការទាំងអស់។ ការប្រជុំត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន អាចប្រគល់សិទ្ធិឱ្យអនុប្រធានដឹកនាំជំនួស។ ការសម្រេចរបស់អង្គប្រជុំ ត្រូវអនុម័តដោយសំឡេងភាគច្រើននៃសមាជិក អង្គប្រជុំករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។[33]

**កថាភាគទី២ ៖ រដ្ឋបាលសុំកូនអន្តរប្រទេស**

រដ្ឋបាលសុំកូនអន្តរប្រទេស ជាសេនាធិការឱ្យអាជ្ញាធររដ្ឋបាលកណ្តាលសុំកូនអន្តរប្រទេស ដែលមានតួនាទីយ៉ាងសំខាន់ក្នុងកិច្ចនីតិវិធីសុំកូនអន្តរប្រទេសដូចមានចែងក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ហើយ

[32] ប្រកាសលេខ១៩៩ ស.អ.យ. ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស, ០៦ វិច្ឆិកា ២០១៣, ប្រការ ១

[33] ប្រកាសលេខ១៩៤ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា, ០៥ វិច្ឆិកា ២០១៣, ប្រការ៨

ពិសេសសេចក្តីលម្អិតលើមុខងារ តួនាទីក្នុងប្រកាសស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស លេខ១២៣០ ស.អ.យ. ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៤។ យ៉ាងណាមិញរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបានរៀបចំជាអង្គការលេខដូចមានចែងដាក់លាក់ក្នុងប្រកាសខាងលើ ហេតុនេះ គប្បីស្វែងយល់ពី**សមភាព** (១) និង **តួនាទីនៃរដ្ឋបាលសុំកូនអន្តរប្រទេស**(២)។

**១. សមាសភាព**

រដ្ឋបាលសុំកូនអន្តរប្រទេសដឹកនាំដោយប្រធានមួយរូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។[34]

រដ្ឋបាលសុំកូនអន្តរប្រទេសមានរចនាសម្ព័ន្ធដូចខាងក្រោម៖

១–ការិយាល័យ រដ្ឋបាល និងហិរញ្ញវត្ថុ

២–ការិយាល័យ គ្រប់គ្រងទិន្នន័យ និងតម្កល់ឯកសារ

៣–ការិយាល័យ អនុវត្តនីតិវិធីសុំកូនអន្តរប្រទេស

៤– ការិយាល័យ អភិវឌ្ឍ គ្រប់គ្រងទីភ្នាក់ងារ និងអធិការកិច្ច

៥– ការិយាល័យ សហប្រតិបត្តិការអន្តរជាតិ

ប្រធានការិយាល័យនីមួយៗមានឋានៈស្មើប្រធានការិយាល័យថ្នាក់ក្រសួង។[35]

**២. តួនាទីភារកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស**

រដ្ឋបាលសុំកូនអន្តរប្រទេស សរសេរកាត់ថា រ.ស.អ. ជាភាសាអង់គ្លេស Inter-Country Adoption Administration (I.C.A.A)។

រដ្ឋបាលសុំកូនអន្តរប្រទេសមានភារកិច្ចដូចខាងក្រោម៖

១– រៀបចំ ថែរក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីសម្ងាត់ និងសំណុំឯកសាររបស់កុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស។

២– ធ្វើការប៉ាន់ប្រមាណស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុតសម្រាប់កុមារ និងធានាថាកុមារទាំងនោះទទួលបានការចិញ្ចឹមថែទាំតាមតម្រូវការ។

---

[34] ប្រកាសលេខ១២៣០ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស, ៣០ មេសា ២០១៤, ប្រការ៣

[35] ប្រកាសលេខ១២៣០ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស, ៣០ មេសា ២០១៤, ប្រការ៤

៣– ធ្វើការផ្ទៀងផ្ទាត់អំពីការខិតខំប្រឹងប្រែង ដោយអស់ពីលទ្ធភាពក្នុងដំណោះស្រាយនៅក្នុងប្រទេសតាមរយៈការថែទាំជាអចិន្ត្រៃយ៍នៅតាមគ្រួសារ ឬជាមួយអ្នកអាណាព្យាបាលមុនដាក់សំណើរការសុំកូនអន្តរប្រទេស។

៤– ទទួលពិនិត្យ និងចាត់ការពាក្យសុំកូនអន្តរប្រទេស និងឯកសារពាក់ព័ន្ធផ្សេងៗទៀតរបស់ អ្នកសុំ។

៥– ផ្គូផ្គងកុមារដែលមានលក្ខណសម្បត្តិសមស្របសុំកូនអន្តរប្រទេស ជាមួយអ្នកសុំដែលអាចបំពេញតម្រូវការដ៏ល្អបំផុតរបស់កុមារ ស្របតាមគោលការណ៍នៃឧត្តមប្រយោជន៍របស់កុមារ ហើយលើកយោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ពិនិត្យសម្រេច។

៦– ជូនដំណឹងអំពីនីតិវិធីសុំកូន និងការវិវត្តនៃករណីសុំកូនទៅអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួល ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតពីប្រទេសទទួល។

៧– រៀបចំពិធីប្រគល់កុមារឱ្យទៅអ្នកសុំ និងរៀបចំឯកសារដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ។

៨– ផ្តល់ ឬសម្របសម្រួលការផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំ និងគ្រួសារបង្កើតតាមការចាំបាច់។

៩– ផ្តល់យោបល់ជូនគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសទាក់ទងនឹងការអនុញ្ញាត ឬដកហូតការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលធ្វើសហប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

១០– អនុវត្តគោលការណ៍ណែនាំគណៈកម្មាធិការអាជ្ញាធរកណ្តាល ដើម្បីធ្វើអធិការកិច្ចលើកិច្ចសុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ បំភិតបំភ័យ ឬជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

១១– លើកសំណើសុំការសម្រេចពីគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីចាត់វិធានការព្រមាន ដាក់កំហិត ឬផាកពិន័យចំពោះបុគ្គល ឬអង្គភាពដែលប្រព្រឹត្តល្មើសនឹងច្បាប់ ស្តីពីសុំកូនអន្តរប្រទេសព្រមទាំងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមានផ្សេងៗទៀត។

១២– ពិនិត្យឯកសារទាក់ទងនឹងសុំកូនអន្តរប្រទេស និងផ្តល់យោបល់សមស្របជូនប្រធានគណៈកម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងជារដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ដើម្បីសម្រេច។

១៣– រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុរាល់ការប្រជុំរបស់គណៈកម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

១៤– គ្រប់គ្រងថវិកាចំណូលរបស់រដ្ឋបាលសុំកូនអន្តរប្រទេស រៀបចំធ្វើផែនការចំណាយ និងធ្វើរបាយការណ៍ហិរញ្ញវត្ថុស្តីពី ភាពដែលប្រព្រឹត្តល្មើសនឹងច្បាប់ស្ថានភាពប្រើប្រាស់ថវិកាជារៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

១៥– រៀបចំផែនការ កម្មវិធី និងសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រី ធ្វើការងារសុំកូនអន្តរប្រទេស និងអ្នកពាក់ព័ន្ធផ្សេងទៀត។

១៦– ចាត់វិធានការសមស្របក្នុងការប្រមូល ថែរក្សា និងផ្លាស់ប្តូរព័ត៌មានស្តីពីស្ថានភាពកុមារព័ត៌មានដើមកំណើតកុមារ អត្តសញ្ញាណឪពុកម្តាយ និងប្រវត្តិសុខភាពកុមារ។

១៧– បំពេញភារកិច្ចចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗទៀត តាមការប្រគល់ភារកិច្ចរបស់គណៈកម្មាធិការ អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។[36]

## កថាភាគទី៣ ៖ ទីភ្នាក់ងារសុំកូនអន្តរប្រទេស

ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដើរតួយ៉ាងសំខាន់ក្នុងការប្រតិបត្តិកិច្ចនីតិវិធីសុំកូនអន្តរប្រទេស ដើម្បីដំណើរនៃការសុំកូនអន្តរប្រទេសឱ្យបានជោគជ័យ ជាអន្តរការីដែលទទួលបាននីតិសម្បទាដោយច្បាប់ និងមានសកម្មភាពស្របច្បាប់ក្នុងការបង្កើតសុំកូនអន្តរប្រទេស។ ហេតុនេះ**លក្ខណសម្បត្តិរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស** (១) ត្រូវតែកំណត់ជាក់លាក់តាមលិខិតបទដ្ឋានរបស់ប្រទេសកម្ពុជា។ លើសពីនេះទៀត ទីភ្នាក់ងារដែលបំព្រហ្មទណ្ឌករណីបានប្រព្រឹត្ត**បទល្មើសព្រហ្មទណ្ឌ** (៤) ត្រូវបង្ហាញតាមអត្ថបទនេះ។

### ១. លក្ខណសម្បត្តិរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

ដើម្បីទទួលបានការអនុញ្ញាតប្រតិបត្តិការសុំកូនអន្តរប្រទេសនៅកម្ពុជា ទីភ្នាក់ងារនេះត្រូវមានលក្ខណសម្បត្តិដូចជា ការបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ។ ស្របគ្នានេះ ទីភ្នាក់ងារសុំកូនអន្តរប្រទេស មានទិសដៅមិនស្វែងរកផលចំណេញ និងបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃ

[36] ប្រកាសលេខ១២៣០ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស, ៣០ មេសា ២០១៤, ប្រការ២

ទីភ្នាក់ងារ។ ម៉្យាងវិញទៀត ទីភ្នាក់ងារត្រូវមានអ្នកដឹកនាំ និងមានបុគ្គលិក ដែលមានសមត្ថភាពប្រកបដោយគុណធម៌ និងសីលធម៌ដែលបញ្ជាក់ដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសរបស់ប្រទេសទីភ្នាក់ងារ ដែលបានទទួលការបណ្តុះបណ្តាលអំពីច្បាប់ស្តីពី សុំកូនអន្តរប្រទេសរបស់ព្រះរាជាណាចក្រកម្ពុជា លិខិតបទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងការសុំកូនអន្តរប្រទេស រៀបចំដោយអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងមានបទពិសោធន៍ធ្វើការងារក្នុងវិស័យសុំកូនអន្តរប្រទេស។[37] មួយអន្លើទៀតនោះ គឺត្រូវឆ្លើយតបនឹងលក្ខខណ្ឌមួយចំនួនទៀតដើម្បីទទួលបានការអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ដោយមិនមានបើកមណ្ឌលកុមារកំព្រា ឬប្រើប្រាស់សម្រាប់សុំកូនអន្តរប្រទេស ហើយប្រទេសរបស់ទីភ្នាក់ងារ ជាប្រទេសមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា និងគោរព អនុវត្តតាមច្បាប់ស្តីពី សុំកូនអន្តរប្រទេស និងបទប្បញ្ញត្តិច្បាប់ជាធរមានផ្សេងទៀតរបស់ព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានអន្តរជាតិផ្សេងទៀតដែលពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេសដែលកម្ពុជា និងប្រទេសរបស់ទីភ្នាក់ងារបានផ្តល់សច្ចាប័ន ឬអនុម័តយល់ព្រម។[38]

**២. ការដាក់ពាក្យសុំធ្វើប្រតិបត្តិការជាទីភ្នាក់ងារសុំកូនអន្តរប្រទេស**

ការស្នើសុំការអនុញ្ញាតធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទីភ្នាក់ងារត្រូវមានសំណុំឯកសារដូចទៅ ៖

- ពាក្យស្នើសុំត្រូវចុះហត្ថលេខាដោយប្រធានទីភ្នាក់ងារ និងមានបិទតែមសារពើពន្ធតម្លៃ ៥០០០ (ប្រាំពាន់)រៀល។
- ច្បាប់ចម្លងលិខិតអនុញ្ញាតឱ្យបើកទីភ្នាក់ងារដែលមានទិសដៅមិនស្វែងរកផលចំណេញ ដោយមានការបញ្ជាក់ត្រឹមត្រូវ និងច្បាប់ចម្លងលិខិតបញ្ជាក់ទទួលស្គាល់គុណវុឌ្ឍិរបស់ទីភ្នាក់ងារ (នៅមានសុពលភាព) ចេញដោយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ។
- លិខិតរបស់អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារ ដែលអនុញ្ញាតឱ្យទីភ្នាក់ងារធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ។

[37] ប្រកាសលេខ១៩៨០ ស.អ.យ. ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស, ០៧ សីហា ២០១៤, ប្រការ៤

[38] ប្រកាសលេខ១៩៨០ ស.អ.យ. ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស, ០៧ សីហា ២០១៤, ប្រការ៥

- ឯកសារសង្ខេបអំពីប្រវត្តិ សកម្មភាព កម្មវិធី និងសេវារបស់ទីភ្នាក់ងារ បញ្ជីរាយនាមបុគ្គលិក និងលក្ខណសម្បត្តិរបស់បុគ្គលិកទាំងនោះ រួមទាំងភស្តុតាងដែលបង្ហាញអំពីបទពិសោធន៍ក្នុងវិស័យសុំកូនអន្តរប្រទេសយ៉ាងតិច ០៥ (ប្រាំ) ឆ្នាំ។
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំចុងក្រោយ ដែលបានធ្វើសវនកម្មឯករាជ្យរួមមាន ប្រភពមូលនិធិសោហ៊ុយសុំកូន និងថ្លៃចំណាយនានាទាក់ទងនឹងសុំកូនអន្តរប្រទេស។
- ជីវប្រវត្តិសង្ខេបមានបិទរូបថតទំហំ ៤ ស.ម X ៦ ស.ម របស់សមាជិកក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រងទីភ្នាក់ងារ និងរូបថតរបស់បុគ្គលិកមួយនាក់ ឬពីរនាក់ដែលបានទទួលការអនុញ្ញាតឱ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារលើការងារសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ច្បាប់ចម្លងឯកសារកិច្ចព្រមព្រៀងពីអតីតកាល ឬបច្ចុប្បន្នកាលជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាស្តីពីការផ្តល់ជំនួយមនុស្សធម៌ ឬការជួយឧបត្ថម្ភដល់កុមារកំព្រានានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- ច្បាប់ចម្លងកិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការសុំកូនអន្តរប្រទេសរវាងព្រះរាជាណាចក្រកម្ពុជា (ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ) និងប្រទេសរបស់ទីភ្នាក់ងារ ប្រសិនបើប្រទេសនេះមិនមែនជាប្រទេសភាគីអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។
- ឯកសារផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់ដើម្បីឧត្តមប្រយោជន៍កុមារ និងដើម្បីមានមូលដ្ឋានវាយតម្លៃពាក្យសុំឱ្យបានសមស្រប។[39]

### ៣. អាជ្ញាធរផ្តល់ការអនុញ្ញាតឱ្យទីភ្នាក់ងារសុំកូនអន្តរប្រទេស

ទីភ្នាក់ការដែលមានបំណងចង់ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅកម្ពុជា ត្រូវមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសរបស់ទីភ្នាក់ងារស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ចំពោះប្រទេសទទួលដែលគ្មានទីភ្នាក់ងារ អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួលនោះ មានសិទ្ធិធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ប៉ុន្តែត្រូវមានការទទួលស្គាល់ពីស្ថានទូត ឬស្ថានតំណាងរបស់ប្រទេសទទួល និងមានការយល់ព្រមពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងត្រូវមានការអនុញ្ញាតពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

[39] ប្រកាសលេខ១៩៨០ ស.អ.យ. ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស, ០៧ សីហា ២០១៤, ប្រការ៦

អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់ទីភ្នាក់ងារ ត្រូវចុះកិច្ចព្រមព្រៀងជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីកំណត់ចំនួនទីភ្នាក់ងារដែលអនុញ្ញាតឱ្យធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយចំនួននេះកំណត់ឱ្យមានត្រឹម ០១ (មួយ) ឬ០២ (ពីរ) លើកលែងតែក្នុងករណីចាំបាច់ ដើម្បីឧត្តមប្រយោជន៍កុមារអាចអនុញ្ញាតឱ្យមានលើសពីនេះ។[40]

### ៤. ទោសប្បញ្ញត្តិ

ជាគោលការណ៍ទោស សំដៅទៅលើទណ្ឌកម្មដែលត្រូវផ្តន្ទាទោសតាមច្បាប់ ដោយតុលាការ ទៅលើបុគ្គលទាំងឡាយណាដែលប្រព្រឹត្តបទល្មើស[41] ហើយទោសដែលមានចែងក្នុងច្បាប់ស្តីពីសុំអន្តរប្រទេសនេះ និងច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទមានការផ្តន្ទាទោស ចំពោះអំពើល្មើសពាក់ព័ន្ធនឹងការសុំកូនជាអាទិ៍ទោស ជាការពិន័យអន្តរការណ៍ និង ទោសដាក់ពន្ធនាគារ។

#### ៤.១. ការពិន័យអន្តរការណ៍

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមានមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចព្យួរ ឬដកហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឱ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេសជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចខាងក្រោម៖

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឱ្យឪពុកម្តាយ ឬឪពុក ឬម្តាយបោះបង់ទារកដែលកើតហើយ ឬដែលនឹងកើត ដើម្បីឱ្យដឹងប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស។
- អំពើប្រព្រឹត្តក្នុងគោលដៅបង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធ ដែលចង់សុំកូនយកចិញ្ចឹមតាមយៈសុំកូនអន្តរប្រទេស និងឪពុកម្តាយ ឬឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត។
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីម្នាក់យល់ព្រមពពោះ ដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ។
- អំពើក្លែងបន្លំ ឬសមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្តាយបង្កើតឬ ឪពុកបង្កើត ឬម្តាយបង្កើតឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។

[40] ប្រកាសលេខ១៩៨០ ស.អ.យ. ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស, ០៧ សីហា ២០១៤, ប្រការ២
[41] ស្លាយមេរៀន សាស្ត្រាចារ្យ លោកស្រី សាត ធីតា ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងខេត្តសៀមរាប

- អំពើរៀបចំឱ្យមានការយល់ព្រមរបស់ឪពុកម្តាយបង្កើតឬ ឪពុកបង្កើត ឬម្តាយបង្កើតឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារដោយការបង្ខិតបង្ខំ ការគំរាមគំហែង ការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬសន្យាផ្តល់ប្រាក់រង្វាន់ សំណង ឬផលប្រយោជន៍ណាមួយ។
- ការបញ្ចេញសំណុំឯកសារ និងកំណត់ហេតុទាំងអស់ ឬមួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬតុលាការមានសមត្ថកិច្ច។
- ការបង្គាប់ ឬការទទួលដោយផ្ទាល់ ឬដោយប្រយោលនូវថ្នូរប្រាក់កាស ទំនិញ ឬសេវាដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។
- ការផ្តល់ប្រាក់កាស ទំនិញ ឬសេវាទៅឱ្យមន្ត្រី ឬអ្នកតំណាងណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ឬមន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឱ្យផ្តល់នូវសិទ្ធិជាអាទិភាពនៅ ក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ។
- ការផ្សាយពាណិជ្ជកម្ម ឬការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬរូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឱ្យដាក់ពាក្យសុំកូន។
- ការតាក់តែង ឬចាត់តាំងអ្នកតំណាងមួយដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុក វិស័យសង្គមកិច្ច។
- ការចូលរួមក្នុងការរៀបចំការជួបជុំ ឬការទាក់ទងគ្នារវាងអ្នកសុំ និងឪពុកម្តាយបង្កើតឬ ឪពុកបង្កើត ឬ ម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុងគោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ។
- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមានៃការថែទាំជំនួសចំពោះកុមារ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។[42]

គ្មាននរណាម្នាក់អាចទាញយកផលកម្រៃផ្នែកហិរញ្ញវត្ថុ ឬផលកម្រៃដទៃទៀតពីសុំកូនអន្តរប្រទេសនោះទេ មិនថាតែនាយកអភិបាល និងនិយោជិតនៃអង្គការដែលពាក់ព័ន្ធក្នុងរឿងសុំកូនមិនត្រូវទទួលលាភ ដែលខ្ពស់

[42] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៥៤

មិនសមរម្យទាក់ទងនឹងសេវាកម្មដែលខ្លួនបានផ្តល់ទេ មានតែសោហ៊ុយ និងប្រាក់ចំណាយ រួមមានប្រាក់ឈ្នួលវិជ្ជាជីវៈសមរម្យរបស់ជន ដែលពាក់ព័ន្ធក្នុងរឿងសុំកូនប៉ុណ្ណោះ ទើបអាចយកបាន ឬចំណាយបាន។[43]

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមិនបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ដែលមានសិទ្ធិធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ឬមិនត្រូវអនុញ្ញាតឱ្យបើក ឬយកមណ្ឌលកុមារកំព្រា ជាប្រភពដើម្បីផ្គត់ផ្គង់ទារក និងកុមារកំព្រានៅក្នុងព្រះរាជាណាចក្រកម្ពុជា។ បើមិនដូច្នោះទេ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន)រៀល ទៅ ១០.០០០០.០០០ (ដប់លាន)រៀល។ ការដាក់ពិន័យជាអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ប្រាក់ពិន័យអន្តរការណ៍នេះ ត្រូវបង់ចូលក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលកុមារ។ ក្នុងករណី ទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ។[44]

### ៤.២. ទោសដាក់ពន្ធនាគារ

ការផ្តន្ទាទោសលើបុគ្គលណាដែលប្រព្រឹត្តអំពើ ជាបទល្មើសដោយអនុលោមតាមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទនៃព្រះរាជាណាចក្រកម្ពុជា ដែលត្រូវបានចូលជាធរមាននៅថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០០៨ លើទង្វើដែលមិនស្របច្បាប់ផ្ទុយពីគោលបំណងនៃការសុំកូនអន្តរប្រទេស។

<u>១.-ការនាំយកចេញដោយមិនស្របច្បាប់:</u>

–និយមន័យការនាំយកចេញដោយមិនស្របច្បាប់ ៖ ការធ្វើឱ្យមនុស្សម្នាក់ផ្លាស់ទីពីទីកន្លែងមួយ ដែលគេកំពុងរស់នៅទៅកាន់ទីកន្លែងដទៃ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ឬរបស់តតិយជនតាមមធ្យោបាយបង្ខិតបង្ខំ គម្រាមគំហែង បោកបញ្ឆោត បំពានដោយអំណាច ឬល្បួងលោម។

–និយមន័យការនាំយកចេញដោយមិនស្របច្បាប់ទៅលើអនីតិជន ៖ ការនាំយកអនីតិជន ឬជនដែលនៅក្រោមអាណាព្យាបាលទូទៅ ឬនៅក្រោមហិតូបត្ថម្ភ ឬនៅក្រោមអ្នកគ្រប់គ្រងស្របច្បាប់ដោយគ្មានអំណាចតាមផ្លូវច្បាប់ ឬយុត្តិកម្មតាមផ្លូវច្បាប់ចេញពីការគ្រប់គ្រងស្របច្បាប់នៃឪពុកម្តាយ អ្នកថែរក្សា ឬអ្នកអាណាព្យាបាលរបស់គេ។[45]

–និយមន័យការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ៖ ជនណាដែលនាំយកជនដទៃទៀតដោយមិនស្របច្បាប់ ក្នុងគោលដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបអាសអាភាស

[43] អនុសញ្ញាទីក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ១៩៩៣, មាត្រា ៣២

[44] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៥៥

[45] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨, មាត្រា៨

រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះសុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចន៍ផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។[46]

–និយមន័យការនាំយកចេញដោយមិនស្របច្បាប់សម្រាប់ឆ្លងដែន ៖ ជនណាដែលនាំយកជនដទៃចេញដោយមិនស្របច្បាប់ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។[47]

២.-អំពើលក់-ដូរមនុស្ស

–អំពើលក់-ដូរមនុស្ស ៖ មានន័យថា ប្រគល់ឱ្យដោយខុសច្បាប់នូវការគ្រប់គ្រងលើជនណាម្នាក់ទៅជនដទៃ ឬទទួលយកដោយខុសច្បាប់ នូវការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ពីជនដទៃ ដោយដោះដូរទៅនឹងរបស់មានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង។ អំពើធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នានឹងចារីដែរ[48]។

–ជនដែលលក់-ដូរជនដទៃ ដោយមានគោដៅស្វែងរកប្រយោជន៍ ឈ្លានពានខាងផ្លូវភេទ ផលិតរូបអាសអាភាស រៀបអាពាហ៍ពិពាហ៍ ផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះសុំកូន ឬទម្រង់ណាមួយនៃការកេងប្រវ័ញ្ចផ្សេងទៀត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ។

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។[49]

–និយមន័យកាអំពើលក់-ជួញដូរមនុស្សសម្រាប់ឆ្លងដែន ៖ ជនណាដែលលក់-ជួញដូរជនដទៃ ក្នុងគោលដៅប្រគល់ ឬ នាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ។

[46] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុងស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨, មាត្រា១០

[47] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុងស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨, មាត្រា១១

[48] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុងស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨, មាត្រា១៣

[49] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុងស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨, មាត្រា១៥

ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែលជនរងគ្រោះជាអនីតិជន។[50]

៣.-អំពើសញ្ចារកម្ម

-និយមន័យនៃសញ្ចារកម្ម ៖ អំពើសញ្ចារកម្ម នៅក្នុងច្បាប់នេះ មានន័យថា៖

១ -ទាញយកអត្ថប្រយោជន៍ហិរញ្ញវត្ថុពីអំពើពេស្យាចាររបស់ជនដទៃ

២-ជួយ ឬ ការពារអំពើពេស្យាចាររបស់អ្នកដទៃ

៣ -ជ្រើសរើស អូសទាញ ឬ បណ្តុះបណ្តាលបុគ្គលណាម្នាក់ឱ្យធ្វើអំពើពេស្យាចារ

៤- ធ្វើការគាបសង្កត់លើបុគ្គលណាមួយ ដើម្បីឱ្យបុគ្គលនោះធ្វើពេស្យាចារ។

-សញ្ចារកម្មទាក់ទងនឹងពេស្យាចារកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧ (ប្រាំពីរ) ឆ្នាំ ដល់ ១៥ (ដប់ប្រាំ) ឆ្នាំ កាលបើបុគ្គលដែលធ្វើពេស្យាចារនោះ ជាអនីតិជន។

៤.-រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ

-រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ៖ មានន័យថា សម្ភារៈដែលអាចមើលឃើញនឹងភ្នែកដូចជា រូបថត ខ្សែវីដេអូ រួមទាំងសម្ភារៈ អេឡិចត្រូនិច ដែលបង្ហាញពីរូបរាងអាក្រាតរបស់អនីតិជនដែលធ្វើឡើងដោយរំភើប ឬ រំជួលដល់ចំណង់ផ្លូវភេទ។

-ជនណាផលិតរូបភាព និងសម្ភារៈអាសអាភាសនៃកុមារ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ។

[50] ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨, មាត្រា១១

# ជំពូកទី២
# នីតិវិធីនៃការបង្កើតសុំកូន
# អន្តរប្រទេស

# ជំពូកទី២

# នីតិវិធីនៃការបង្កើតសុំកូនអន្តរប្រទេស

នីតិវិធីនៃការបង្កើតសុំកូនអន្តរប្រទេស ជាលក្ខខណ្ឌទម្រង់ដែលត្រូវតែបំពេញជាចាំបាច់ ដើម្បីទទួលបានភាពត្រឹមត្រូវតាមច្បាប់ បង្កើតអានុភាព និងធានាថា កុមារពិតជាទទួលបានការការពារ និងឧត្តមប្រយោជន៍យ៉ាងពិតប្រាកដ។ ចំពោះកិច្ចនីតិវិធីទាំងនេះត្រូវបែងចែកជាពីរផ្នែកគឺ **នីតិវិធីរដ្ឋបាល** និង**នីតិវិធីតុលាការ**។

## ផ្នែកទី១ ៖ នីតិវិធីរដ្ឋបាល

ក្នុងដំណាក់កាលនៃនីតិវិធីរដ្ឋបាលក្នុងការសុំកូន ត្រូវឆ្លងកាត់ការដាក់ពាក្យសុំរបស់អ្នកសុំ ហើយត្រូវបានពិនិត្យយ៉ាងហ្មត់ចត់ជាមុន ដើម្បីសម្រេចលើពាក្យសុំថាត្រឹមត្រូវ និងគ្រប់គ្រាន់ចំពោះសំណុំឯកសារស្នើសុំ។

### កថាភាគទី១ ៖ ការដាក់ពាក្យ

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន ៖

១–ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និងមានភាពសមស្របសម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុករ៉ាប់រងចំពោះសុំកូនអន្តរប្រទេស។

២–ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

៣–ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំដែលក្នុងនោះរួមមាន ឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន។

៤– ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន។

៥–ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ដែលមានការ

បញ្ជាក់ត្រឹមត្រូវ។[51] ចំពោះពាក្យសុំបង្កើតស្មុំកូនអន្តរប្រទេស អាចធ្វើទៅបានទាំងក្នុងករណីដែលកុមារនោះ ជាសាច់ញាតិ ឬ មិនមែនជាសាច់ញាតិនៃរបស់អ្នកសុំក៏ដោយ គឺត្រូវប្រព្រឹត្តទៅតាមបញ្ញត្តិនៃច្បាប់ស្តីពី ស្មុំកូនអន្តរប្រទេសដូចគ្នា។[52]

ពាក្យសុំដែលមានភ្ជាប់រួចជាស្រេចនូវភស្តុតាងដែលតម្រូវ បានដាក់រួចរាល់រួចហើយនោះ ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬស្ថានតំណាងនៃប្រទេសទទួលប្រចាំនៃព្រះរាជាណាចក្រកម្ពុជាដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារនោះ។ ក្រសួងការបរទេស និងការសហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និងត្រូវបញ្ជូនសំណុំឯកសារស្មុំកូនអន្តរប្រទេស ទៅក្រសួងបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេលក្នុងរយៈពេល១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានពាក្យសុំ។ ក្នុងរយៈពេលយ៉ាងយូរបំផុត (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃទទួលបានពាក្យសុំពីក្រសួងការបរទេស និងការសហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកមានសុំកូនដោយបញ្ជាក់ថាខ្លួនបានទទួលពាក្យសុំកូននេះ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬតាមរយៈទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍[53]។

ជាភារកិច្ចបន្ទាប់រដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវរៀបចំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិសម្រាប់ស្មុំកូនអន្តរប្រទេសដូចជា ៖ កុមារដែលមានសញ្ជាតិខ្មែរ ហើយកំពុងរស់នៅជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា អាយុ[54] អត្តសញ្ញាណ សាវតាជាតិ បរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិសុខភាពរបស់កុមារ និងប្រវត្តិសុខភាពគ្រួសាររបស់កុមារ និងសេចក្តីត្រូវការរបស់កុមារ។ ក្នុងករណីដែលកុមារត្រូវបានបោះបង់ចោល រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវធានាថា បានខិតខំប្រឹងប្រែងរកហើយតែនៅតែរកមិនឃើញដោយភស្តុតាងរួចដាក់បញ្ចូលក្នុងសំណុំឯកសាររបស់កុមារនោះ ផងដែរ[55]។ អ្នកសុំត្រូវបង់ប្រាក់ចំណាយសោហ៊ុយ និងវិភាគទាននានាសម្រាប់ជួយឧបត្ថម្ភដល់ជម្រើសនានានៃការថែទាំជំនួស និងការឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទាក់ទងទៅនឹងស្មុំកូនអន្តរប្រទេស

[51] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៣

[52] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣១

[53] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៤

[54] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា១០

[55] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២២

ដែលត្រូវបានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយស្មុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន[56]។

**កថាភាគទី២ ៖ ការពិនិត្យពាក្យសុំ**

បន្ទាប់ពីបានទទួលពាក្យសុំរដ្ឋបាលស្មុំកូនអន្តរប្រទេស[57] អនុវត្តភារកិច្ចត្រួតពិនិត្យពីភាពត្រឹមត្រូវ និងភាពគ្រប់គ្រាន់នៃសំណុំលិខិតស្នើសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ (បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតឯកសារ។ ប្រសិនបើសំណុំលិខិតឯកសារនូវមិនទាន់គ្រប់គ្រាន់ ឬមិនទាន់ត្រឹមត្រូវរដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬមិនទាន់គ្រប់គ្រាន់ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្ដាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬទីភ្នាក់ងារស្មុំកូនអន្តរប្រទេស ត្រូវត្រួតពិនិត្យឯកសារដែលស្នើសុំឱ្យកែតម្រូវ ស្មើគ្នានឹងអំឡុងពេលខាងលើគឺ ៦០ ថ្ងៃដែរ។ អំឡុងពេលដែលបានកំណត់ខាងលើ ក្រោយពីមានការជូនដំណឹងពីរដ្ឋបាលកណ្ដាលស្មុំកូនអន្តរប្រទេសឱ្យកែតម្រូវអ្នកសុំបានធ្វើឱ្យមានភាពយឺតយ៉ាវ នោះពាក្យសុំត្រូវចាត់ទុកជាមោឃៈ[58]។

**កថាភាគទី៣ ៖ ការសម្រេចលើពាក្យសុំ**

ក្នុងករណីដែលសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ[59]ហើយអ្នកសុំបានបំពេញលក្ខខណ្ឌនៃច្បាប់ស្មុំកូនអន្តរប្រទេស រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយ ដែលមានលក្ខណសម្បត្តិស្មុំកូនអន្តរប្រទេសបាន និងផ្គូផ្គងលក្ខណសម្បត្តិដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិកុមារ[60]។

ភារកិច្ចបន្តរបស់រដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលបានផ្គូផ្គងរួចហើយនោះដោយរួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា និងអំពីមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំទៅអាជ្ញាធរកណ្ដាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬ

[56] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៥

[57] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៦

[58] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៤

[59] ក្នុងការផ្គូផ្គងដោយត្រូវគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវគិតពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តអោយមានការបីបាច់ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតា ជាតិពន្ធ សាសនា និងវប្បធម៌របស់កុមារ។

[60] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៧

ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៃប្រទេស ដើម្បីពិនិត្យ និងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនឡើយ វៀរលែងតែករណីស្មុំកូនដោយសាច់ញាតិ[61]។

ជាគោលការណ៍ អ្នកសុំត្រូវធ្វើការឆ្លើយតបវិញជាលាយលក្ខណ៍អក្សរអំពីការយល់ព្រមសុំកុមារដែលខាងរដ្ឋបាលស្មុំកូនបានផ្តួផ្គងឱ្យ ទៅកាន់រដ្ឋបាលស្មុំកូនអន្តរប្រទេសវិញ តាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៃប្រទេសទទួល ដោយកំណត់អំឡុងពេល ៦០ ថ្ងៃ (ថ្ងៃធ្វើការ រាប់ចាប់ពីពេលរដ្ឋបាលស្មុំកូនបានផ្ញើសំណុំឯកសារទៅកាន់អ្នកសុំ)។ ក្នុងករណី អ្នកសុំមិនបានឆ្លើយតទាន់ក្នុងរយៈពេលខាងលើទេ ត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន តែមិនយកមកអនុវត្តឡើយ ក្នុងករណីដែលមានការខកខាននោះមានមូលហេតុត្រឹមត្រូវ ដោយរដ្ឋបាលស្មុំកូនអន្តរប្រទេសជាអ្នកមានសមត្ថកិច្ចក្នុងសម្រេចថា តើឱ្យមានការផ្គូផ្គងសាជាថ្មី ឬការទទួលពាក្យសុំកូនសាជាថ្មី។[62]

ដោយឡែក បើអ្នកសុំធ្វើការឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្គូរផ្គងឱ្យខ្លួននោះទេ អ្នកសុំអាចស្នើសុំឱ្យរដ្ឋបាលស្មុំកូនអន្តរប្រទេសផ្គូផ្គងកុមារជាលើកទីពីរបាន។ តែការផ្គូផ្គងនេះមិនអនុញ្ញាតឱ្យមានធ្វើជាលើកទីបីឡើយ[63]។

ផ្ទុយទៅវិញ បើអ្នកសុំបានឆ្លើយតបយល់ព្រមលើការសម្រេចរបស់រដ្ឋបាលស្មុំកូនអន្តរប្រទេសចំពោះការផ្គូផ្គងរវាងអ្នកសុំ និងកូនសុំនោះ។ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវរៀបចំឱ្យមានការជួបគ្នារវាងអ្នកសុំ និងកុមារដែលបានផ្គូផ្គងរួចហើយនោះ ក្នុងកាលបរិច្ឆេទមួយដែលសមស្របសម្រាប់អ្នកសុំ រួមទាំងរដ្ឋបាលស្មុំកូនអន្តរប្រទេស និងមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ក្នុងរយៈពេល ៦០ ថ្ងៃ (ថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ)។ មុនមានការជួបគ្នារវាងអ្នកសុំ និងកូនសុំ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវធ្វើសម្ភាសន៍អ្នកសុំ និងត្រូវធានាថា អ្នកសុំ និងកុមារបានរៀបចំខ្លួនជាស្រេច តាមរយៈការពិគ្រោះយោបល់ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូរ រូបថត និងវិធានការណ៍ផ្សេងៗទៀតដើម្បីការជួបគ្នានេះ[64]។ នៅក្នុងកាលបរិច្ឆេទនៃការជួបគ្នាលើកដំបូងនេះ បើមានសហព័ទ្ធណាម្ខាងអវត្តមាន ចាំបាច់ត្រូវមានលិខិតប្រគល់សិទ្ធិឱ្យសហព័ទ្ធម្ខាងទៀត ដែលមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួលធ្វើជា

[61] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៨

[62] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៩
ករណីនេះ រដ្ឋបាលស្មុំកូនអាចផ្គូផ្គងកុមារនោះឱ្យអ្នកសុំផ្សេងទៀត ចំណែកឯប្រាក់ចំណាយ សោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានបង្វិលឱ្យវិញឡើយ។

[63] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា២៩

[64] ច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣០

អ្នកតំណាងខ្លួនបាន។ ប្រសិនបើអ្នកសុំមិនបានជួបក្នុងរយៈពេលខាងលើដោយគ្មានមូលហេតុត្រឹមត្រូវ ចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។ បន្ទាប់មក រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យដឹងអំពីអានុភាពដែលកើតចេញពីសុំកូនអន្តរប្រទេសនេះ [65] ដោយត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីកាសម្ភាស និងការជួបគ្នាខាងលើនេះ។

រដ្ឋបាលសុំកូនអន្តរប្រទេស ធ្វើការពិនិត្យបើយល់ឃើញថា រវាងអ្នកសុំ និងកូនសុំបានបំពេញនូវលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ ហើយត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ ថ្ងៃ (ថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នា)។ រួចដាក់សំណុំឯកសារជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍លើដំណើរការសុំកូន[66]។ ក្រោយពីបានពិនិត្យ និងផ្តល់អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចរួចមក អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្គូផ្គងរួចតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសនៅសាលាដំបូងរាជធានីភ្នំពេញ។ រដ្ឋបាលសុំកូនអន្តរប្រទេសមានកាតព្វកិច្ចបញ្ជូនពាក្យសុំ រួមជាមួយសំណុំឯកសាររបស់អ្នកសុំ និងកូនសុំ ព្រមទាំង

អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដោយមានបកប្រែជាភាសាខ្មែរ និងមានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេសផង ដើម្បីសុំដីកាសម្រេចសុំកូន ក្នុងរយៈពេល ៧ ថ្ងៃ។ ផ្ទុយទៅវិញបើអ្នកសុំមិនបានដាក់ពាក្យសុំ ក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ (ថ្ងៃធ្វើការបន្ទាប់ពីទទួលអនុសាសន៍របស់រដ្ឋមន្ត្រីត្រូវបានចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំដោយខ្លួនឯង)។[67]

## ផ្នែកទី២ ៖ នីតិវិធីតុលាការ

ក្រៅពីកិច្ចនីតិវិធីផ្នែករដ្ឋបាលដែលបានអនុវត្តដោយអនុលោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសរួចមក គឺត្រូវមានការវិលចូលក្នុងកិច្ចនីតិវិធីរបស់តុលការ ដើម្បីទទួលបានដីកាសម្រេចសុំកូនអន្តរប្រទេស។ ដីកាសម្រេចប្រភេទនេះ គឺត្រូវស្ថិតក្នុងប្រភេទបណ្តឹងទាមទារឱ្យបង្កើត ផ្លាស់ប្តូរ និងរំលត់នៃសិទ្ធិ និងទំនាក់ទំនងគតិយុត្ត ដូចមានចែងក្នុងមាត្រា ៣៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសបានចង្អុលបង្ហាញថា ៖ "តុលាការ

[65] ត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងអោយបានច្បាស់អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូន ក្នុងនោះជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និងកម្រិតយល់ដឹងរបស់កុមារ។

[66] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣២

[67] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៣

ដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស...”។

**កថាភាគទី១៖ សមត្ថកិច្ចផ្តាច់មុខ**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស[68]។ អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យបណ្តឹង ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ចូលឯកសារ ការផ្សព្វផ្សាយ ការជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពនីតិវិធីផ្សេងៗទៀតដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និងបង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមជាមុនបាន ក្នុងករណីដែលសោហ៊ុយចាំបាច់មានចំនួនលើសពីការកំណត់ខាងលើ[69]។

**កថាភាគទី២៖ ការពិនិត្យភស្តុតាង**

ជាគោលការណ៍ សំណុំឯកសារ និងរបាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតថាជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និងភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំ លើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់។[70]

បើមានភាពចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកធ្វើការបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកសង្គមកិច្ចទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និងភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវដែលដាក់ចូលទៅតុលាការ[71]។

❖ **តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា៖**

- លក្ខណវិនិច្ឆ័យ ឬលក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ។
- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងការផ្តល់យល់ព្រម។
- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារតាមផ្នែកទី២ ជំពូកទី៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

[68] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៤
រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូន វិធានការដែលអាជ្ញាធរមានសមត្ថកិច្ចចាត់ការ និងការវិវត្តនៃសុំកូននៅគ្រប់ដំណាក់កាលរបស់នីតិវិធីសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតតាមបទប្បញ្ញត្តិនៃមាត្រា ៤៣។

[69] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៥

[70] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៦

[71] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៦

- មានការពិចារណាពីត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- អាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ។
- កុមារនឹងត្រូវអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសទទួល។
- សុំកូនអន្តរប្រទេសពិតជាឧត្តមប្រយោជន៍របស់កុមារ។[72]

**កថាភាគទី៣៖ ដីកាសម្រេច**

ការសម្រេចសេចក្តីលើការសុំកូនអន្តរប្រទេសរបស់តុលាការ មិនចាំបាច់ឆ្លងកាត់ការទាញហេតុផលផ្ទាល់មាត់ឡើយ។[73] ការចេញដីកាសម្រេចលើសំណុំរឿងសុំកូនអន្តរប្រទេស តុលាការត្រូវធ្វើការវិនិច្ឆ័យ និងចេញសេចក្តីសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ (បន្ទាប់ពីបានទទួលពាក្យសុំ)។ ដីកាសម្រេចមិនត្រូវបានចូលជាស្ថាពរ នៅមុនផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលបានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ នឹងមិនត្រូវចូលជាស្ថាពរទេ។[74]

បុគ្គលដែលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ចំពោះដីកានោះបាន។ ក្នុងករណីដែលបុគ្គលអាចប្តឹងទាស់ជាជនដែលបានទទួលការជូនដំណឹងអំពីដីកាសម្រេចខាងលើ ក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)ថ្ងៃ (គិតចាប់ពីថ្ងៃដែលត្រូវទទួលដំណឹង)។ ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចនោះ បណ្តឹងជំទាស់នោះត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)ថ្ងៃដូចចិរវេលាខាងលើ (គិតចាប់ពីថ្ងៃដែលអ្នកសុំទទួលដំណឹងពីដីកាសម្រេច)[75] ដោយមិនអាចពន្យាបានតទៅទៀតទេ។

សាលាឧទ្ធរណ៍ត្រូវធ្វើការវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ ថ្ងៃ (បន្ទាប់ពីទទួលពាក្យបណ្តឹង) ហើយដីកាសម្រេចនេះបិទផ្លូវតវ៉ា។[76]

[72] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៧

[73] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៨

[74] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៣៩

[75] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៤០

[76] ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៤០

**កថាភាគទី៤៖ សោហ៊ុយលើការសុំកូន**

១-អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាជូនរដ្ឋបាលសុំកូនអន្តរប្រទេស សម្រាប់ជួយឧបត្ថម្ភជម្រើសនានានៃការថែទាំជំនួស និងការជួយឧបត្ថម្ភទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលត្រូវបានកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច (អ្នកសុំកូនត្រូវបង់ចំនួន ៥.០០០ USD (ប្រាំពាន់ដុល្លាអាម៉េរិក) សម្រាប់ការសុំកុមារ ០១ នាក់ ដែលទុកជាថវិកាវិភាគទានមនុស្សធម៌)។

លើកទី១៖ អ្នកសុំត្រូវបង់ប្រាក់ចំនួន ១.៥០០ USD (មួយពាន់ប្រាំរយដុល្លាអាម៉េរិក) នៅពេលដែលសំណុំឯកសារសុំកូន ត្រូវបានបញ្ជូនមកដល់រដ្ឋបាលសុំកូនអន្តរប្រទេសនៃអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។ ចំនួនទឹកប្រាក់នេះ មិនអាចបង្វិលជូនវិញទេ។

លើកទី២៖ អ្នកសុំត្រូវបង់ប្រាក់ចំនួន ៣.៥០០ USD (បីពាន់ប្រាំរយដុល្លាអាម៉េរិក) មុនពេលធ្វើការប្រគល់កុមារជាផ្លូវការ[77]។

ក្រៅពីនេះ មិនត្រូវយកប្រាក់សោហ៊ុយសុំកូនពីអ្នកសុំ ឬទីភ្នាក់ងាររបស់អ្នកសុំកូន។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន បង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬទៅតាមសោហ៊ុយសុំកូនមួយដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬមិនអនុញ្ញាតឱ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្តល់សោហ៊ុយ អំណោយ ឬការទូទាត់ទោះបី ក្នុងរូបភាពណាក៏ដោយ ទៅឱ្យមណ្ឌលកុមារកំព្រាដែលកុមារកំព្រានៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឱ្យមណ្ឌលកុមារកំព្រាដែលកុមារកំព្រានៅទីនោះ ត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឱ្យបុគ្គលិកនាយក ឬសមាជិកនៃគណៈគ្រប់គ្រង ទោះបីជាដោយផ្ទាល់ ឬដោយប្រយោលក្តី។

១-តុលាការត្រូវកំណត់ឱ្យអ្នកសុំបង់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយ សេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងទៀតដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេសនោះ ហើយតុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយចាំបាច់ ដែលបានកំណត់ខាងលើនេះលើសពី

[77] ប្រកាសរួមលេខ ៨៤៨សហវ.ប្រក ស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស, ១០ មេសា ២០១៣, ប្រការ១ និងប្រការ២

១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះមុន រីឯចំនួនទឹកប្រាក់នេះមិនបង្វិលជូនវិញទេ។

## ផ្នែកទី៣ ៖ កុមារក្រោយពេលទៅដល់ប្រទេសសុំ

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអំពីដីកាសម្រេចនេះ។ នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេស ត្រូវបានបញ្ចប់ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវរៀបចំពិធីប្រគល់កុមារ និងលិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំ និងការផ្តល់លិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារចាំបាច់នានាដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួលត្រូវអមដំណើរដោយរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការបញ្ជូនកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ។

មួយផ្នែកទៀត រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលដើម្បីផ្តល់ ឬសម្របសម្រួលដល់កុមារគ្រួសារចិញ្ចឹម និងគ្រួសារបង្កើតតាមការចាំបាច់។

ក្រោយពីកុមារត្រូវបានទទួលអនុញ្ញាតឱ្យធ្វើជាកូន នោះឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវត្តន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ (ប្រាំមួយ) ខែម្តងក្នុងរយៈពេល ៣ ឆ្នាំ បន្ទាប់មកត្រូវផ្តល់ជារបាយការណ៍ ១ ឆ្នាំម្តងរហូតដល់កុមារមានអាយុ ១៨ ឆ្នាំ។

ឪពុកម្តាយចិញ្ចឹមត្រូវធ្វើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេស ដោយផ្ទាល់ ឬតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេស ឬប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប។

រដ្ឋបាលសុំកូនអន្តរប្រទេស និងសាលាដំបូងរាជធានីភ្នំពេញត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ ឆ្នាំគិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះ ចូលជាស្ថាពរ។

សំណុំឯកសារ និងកំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយទោះជារក្សាទុកនៅតុលាការក៏ដោយរដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និងអ្នកជំនាញផ្សេងៗទៀត ដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាជាការសម្ងាត់។ ក៏ប៉ុន្តែសំណុំឯកសារ និងកំណត់ហេតុ ឬព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារអាចនឹងត្រូវបានបញ្ចេញទៅតាមការស្នើសុំ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ចនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងករណីមានតម្រូវការទាក់ទងទៅនឹងករណី ឬនីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅក្នុងកាលៈទេសៈពិសេសដទៃទៀត។

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិតដែលរួមមាន អត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ។ នៅពេលដែលមានផលវិបាកនៃការដឹងអត្តសញ្ញាណកូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អាចត្រូវបានអនុញ្ញាតឱ្យមើល សំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា។ កូនដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និងកំណត់ហេតុទាក់ទងរបស់ខ្លួនដោយមានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន។

# ជំពូកទី៣
# ផលវិជ្ជមាន និងអវិជ្ជមាននៃ
# សុំកូនអន្តរប្រទេស

# ជំពូកទី៣

# ផលវិជ្ជមាន និងអវិជ្ជមាននៃសុំកូនអន្តរប្រទេស

ការសុំកូនអន្តរប្រទេស ជានីតិវិធីចុងក្រោយនៃការចាត់នីតិវិធីនៃការស្វែងរកគ្រួសារអចិន្ត្រៃយ៍សម្រាប់កុមារ ដែលត្រូវបានពិចារណាលើការសុំកូនក្នុងស្រុកជាអាទិភាព ហើយនៅតែមិនទទួលជោគជ័យ។[78] ហេតុនេះ ជាមធ្យោបាយក្នុងការស្វែងរកគ្រួសារអចិន្ត្រៃយ៍មួយសម្រាប់កុមារដែលជាជនរងគ្រោះ កុមារដែលត្រូវការនូវការថែទាំពិសេស ឬកុមារដែលមានតម្រូវការពិសេស។

## ផ្នែកទី១ ៖ ផលប្រយោជន៍នៃការសុំកូនអន្តរប្រទេស

អត្ថប្រយោជន៍ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ៖

១. ជាការធ្វើសមាហរណកម្មទៅតាមចរន្តនៃសកលភាវូបនីយកម្ម នៃវិស័យសិទ្ធិកុមារ។ ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សច្ចាប័ន អនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារមួយចំនួន។ ទន្ទឹមនេះ យើងកំពុងពិនិត្យចូលជាភាគីនៃអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសដែរ។ សេចក្តីថ្លែងការណ៍នៃសហប្រជាជាតិ ស្តីពីអំពីការចិញ្ចឹម ដោយឪពុកម្តាយធម៌ និងសុំកូន ឆ្នាំ ១៩៨៦ បានតម្រូវឱ្យរដ្ឋាភិបាលនានាត្រូវបង្កើតគោលនយោបាយច្បាប់ និងការត្រួតពិនិត្យ ដ៏មានប្រសិទ្ធភាព ដើម្បីការពារដែលមានការពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេស។

នៅខែមិថុនា ឆ្នាំ២០០០ គណកម្មាធិការសហប្រជាជាតិ ស្តីពីសិទ្ធិកុមារ បានចេញអនុសាសន៍ លើរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជាដែលហៅថា "សេចក្តីសង្កេតចុងក្រោយ" លើកទឹកចិត្តប្រទេសកម្ពុជា ឱ្យបន្តតាក់តែងច្បាប់ស្តីពី សុំកូនអន្តរប្រទេសឱ្យឆាប់។

២. ជាការធានានូវសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារកំព្រា ត្រូវបោះបង់ចោល និងតាមរយៈការផ្តល់ឱកាស តាមសុំកូនអន្តរប្រទេសដោយមានការធានាត្រឹមត្រូវ ដោយច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ។

៣. ធានាឱ្យឧត្តមប្រយោជន៍របស់កុមារកម្ពុជា ដែលត្រូវបានគេសុំយកទៅចិញ្ចឹមនៅបរទេស និងដើម្បីការពារកុមារកម្ពុជា គេចផុតពីការជួញដូរតាមរូបភាពសុំកូនអន្តរប្រទេស។

[78] ប្រកាសស្តីពី នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, ប្រការ២៥

៤.បង្កើតច្រកចេញចូលតែមួយ ប្រកបដោយតម្លាភាព ប្រសិទ្ធភាព និងយន្តការសុំកូនអន្តរប្រទេស នៃព្រះរាជាណាចក្រកម្ពុជា ក្រោមអាណាព្យាបាលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។[79]

**កថាភាគទី១ ៖ ចំពោះឪពុក និងម្តាយបង្កើត**

ការសុំកូនអន្តរប្រទេសបានចូលរួមចំណែកជា អត្ថប្រយោជន៍ដល់គ្រួសារ មិនថាតែវិស័យសេដ្ឋកិច្ចនយោបាយក្នុងគ្រួសារទេ នូវសម្រាលកាតព្វកិច្ចសង្គមផ្សេងៗដល់កូនៗក្នុងបន្ទុក ជាអាទិ៍ការអប់រំ សុខភាពជាដើម។ តែគប្បីបញ្ជាក់ផងដែរថា មិនគ្រប់សំណុំរឿងសុំកូនអន្តរប្រទេសទាំងអស់ទេ ដែលមានឪពុកម្តាយបង្កើត ឬឪពុកបង្កើត ឬម្តាយបង្កើតនោះ អាស្រ័យហេតុនេះ ប្រយោជន៍ដែលឪពុកម្តាយបង្កើតទទួលបានមាន ៖

➢ ការបន្ធូរបន្ទុកនៅក្នុងគ្រួសារ៖ កុមារជា អនីតិជន ហើយអនីតិជននេះ គឺបង្កើតនូវភារៈដល់គ្រួសារដោយសារតែគាត់នូវក្មេង មិនមានសមត្ថភាពគ្រប់គ្រាន់តាមផ្លូវច្បាប់ ជាបុគ្គលទន់ខ្សោយ និងងាយរងគ្រោះ។ ដោយហេតុនេះ ឪពុកម្តាយគឺមានកាតព្វកិច្ចទំនុកបម្រុងធ្វើការការពារ ឧបត្ថម្ភគ្រប់បែបយ៉ាង ទាល់តែដល់យុវភាព ឬនីតិភាពនេះឯង ផ្ទុយមកវិញបើមានការសុំកូនយកទៅចិញ្ចឹម ជាប្រការមួយល្អក្នុងចេតនារួចផុតពីកាតព្វកិច្ច។

➢ បង្កើតឱកាសថ្មីមួយ ៖ គ្រួសារមួយដែលមិនបានត្រៀមទុកពីគម្រោងយកកូនជាមុនទេ នាំឱ្យមានកត្តាបោះបង់ចោលទារក ឬកុមារក្នុងបន្ទុក។ របបនៃសុំកូនអន្តរប្រទេសអាចជាវិធីមួយដែល អាចផ្តល់ឱកាសថ្មីដល់ពួកគាត់ ប្រគល់កូនទៅអ្នកចង់បានយកទៅចិញ្ចឹមដោយទុកចិត្ត។

➢ ប្រើសិទ្ធិចាត់ចែង ឬសិទ្ធិជ្រើសគ្រួសារល្អមួយសម្រាប់កូន ៖ ប្រការនេះ គឺចង់មានន័យថា ឪពុកម្តាយបង្កើតនៃសុំកូនអន្តរប្រទេស នៅពេលធ្វើការសម្រេចចិត្តយល់ព្រមបង្កើតសុំកូនអន្តរប្រទេសនេះ ដោយបានគិតគូរយ៉ាងល្អិតល្អន់ពីលក្ខណសម្បត្តិរបស់អ្នកសុំ ដើម្បីធានាថាកូនខ្លួនបានទទួលទ្រនំដ៏ល្អសាជាថ្មី ដោយដឹងថាខ្លួនមិនអាចផ្តល់ឱ្យ។

➢ មិនចាំបាច់ចំណាយ ៖ ក្នុងប្រតិបត្តិការសុំកូនអន្តរប្រទេសនេះ អ្នកជាឪពុកម្តាយបង្កើតគឺ ច្បាប់មិនតម្រូវឱ្យគាត់បង់សោហ៊ុយ ការចំណាយគ្រប់ដំណាក់កាលកិច្ចនីតិវិធីអ្វីទាំងអស់។

[79] សេចក្តីថ្លែងហេតុ នៃសេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេស, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៥ និង
លោក ខន សុខេង, សៀវភៅ ស្តីពី ការសុំកូន, (ភ្នំពេញ៖ ចំណារ, ២០២០), ទំព័រ ៤០

**កថាភាគទី២ ៖ ផលប្រយោជន៍ចំពោះកូនសុំ**

អានុភាពនៃដីកាសម្រេចរបស់តុលាការចំពោះពាក្យសុំបង្កើតសុំកូនអន្តរប្រទេស គឺបញ្ចប់ទំនាក់ទំនងរវាងកូនសុំជាមួយឪពុកម្ដាយបង្កើត ហើយបង្កើតទំនាក់ទំនងគតិយុត្តថ្មីរវាងកូនសុំ និងអ្នកសុំ ហេតុនេះកូនសុំអាចទទួលបាននូវឧត្តមប្រយោជន៍ដូចជា ៖

➢ កុមារដែលជាកម្មវត្ថុនៃការសុំកូនអន្តរប្រទេសនឹងបានទទួលដោយមិនដឹងខ្លួនពី ៖

– គ្រួសារថ្មី ៖ ផ្អែកលើគោលបំណងនៃច្បាប់នេះ ការបង្កើតសុំកូនគឺ ដើម្បីធានានូវឧត្តមប្រយោជន៍របស់កុមារ ការការពារ ការតាមដានជាពិសេសទាំងនេះ ជាហេតុផលចម្បងក្នុងការបង្កើតសុំកូនអន្តរប្រទេស។ លើសពីនេះ គ្រួសារថ្មីជាជនដែលត្រូវការកូនជាចាំបាច់ ដែលហ៊ានផ្ដល់គ្រប់យ៉ាងក្នុងការទំនុកបម្រុងដល់កុមារ។ ហើយ

– បំពេញនូវមនោសញ្ចេតនាដែលខ្វះ ឬបាត់បង់ ៖ កុមារដែលត្រូវបានគេសុំយកទៅចិញ្ចឹមនឹងក្លាយជាកូនស្របច្បាប់តាមផ្លូវច្បាប់។[80] បន្ថែមពីនេះ ជាការបង្រួបនូវទំនាក់ទំនងដែលបានខ្វះឱ្យគ្នាទៅវិញទៅមក ជាអាទិ៍ក្ដីស្រឡាញ់ ភាពសុខដុមរមនា សុភមង្គលជាអចិន្ត្រៃយ៍ដោយមិនមានអ្នកមកដណ្ដើមបាន។

➢ ការទទួលបានគ្រួសារអចិន្ត្រៃយ៍សម្រាប់កូនសុំ ៖ ក្រៅអំពីការស្រឡាញ់ថ្នាក់ថ្នមពីគ្រួសារថ្មីហើយ កុមារក៏ទទួលបានការរស់នៅដែលមានសុវត្ថិភាពខ្ពស់ មានកម្រិតរស់នៅកាន់តែប្រសើរឡើងទៅតាមជីវភាពរបស់អ្នកសុំ អាហារូបត្ថម្ភគ្រប់គ្រាន់ ការអប់រំកាន់តែសម្បូរបែប និងស្តង់ដារជាងមុន ការចិញ្ចឹមបីបាច់ទាំងផ្នែករូបរាងកាយ ផ្នែកផ្លូវចិត្ត និងផ្នែកបញ្ញាស្មារតី ដើម្បីទទួលបានអនាគតដ៏ភ្លឺស្វាង។

➢ បំពេញបានតាមគោលបំណងរបស់ច្បាប់ស្ដីពីសុំកូនអន្តរប្រទេស និងគោលនយោបាយនានា[81] ៖ ចំណុចនេះ មានន័យថា កូនសុំដែលបានសុំយកទៅចិញ្ចឹមខ្លះ ជាអនីតិជនដែលត្រូវបានគេបោះបង់ចោល ឬ កុមារកំព្រា

[80] លោក ខន សុខេង, សៀវភៅ ស្ដីពី ការសុំកូន, (ភ្នំពេញ៖ ចំណារ, ២០២០), ទំព័រ ៤០

[81] របាយការណ៍លេខ ០០២ ស.អ.យ ស្ដីពីការងារសុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជា, ទំព័រទី០១ ចំណុចទី១ សភាពការណ៍ការងារសុំកូនចិញ្ចឹមអន្តរប្រទេស កថាខណ្ឌទី១ និងទី៣ សរសេរថា៖

"រាជរដ្ឋាភិបាលកម្ពុជា អនុវត្តគោលនយោបាយការពារសិទ្ធិកុមារ ស្របតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ការអនុវត្តអនុសញ្ញារបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិកុមារនៅកម្ពុជាសម្រេចបានគោលដៅជាច្រើននៃគោលដៅអភិវឌ្ឍសហសវត្ស ដែលពាក់ព័ន្ធនឹងវិស័យសុខុមាលភាពកុមារ។

រាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការងារសុំកូនអន្តរប្រទេស ជាគោលនយោបាយមួយក្នុងគោលដៅមនុស្សធម៌ ផ្សារភ្ជាប់ការគោរពអនុវត្តសិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ និងទប់ស្កាត់អំពើជួញដូរកុមារតាមរយៈសុំកូនអន្តរប្រទេស"។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានដាក់ចេញគោលនយោបាយស្ដីពីការថែទាំជំនួសចំពោះកុមារនៅឆ្នាំ ២០០៦ ដែលមានគោលបំណង "ធានាថា កុមារធំលូតលាស់នៅក្នុងគ្រួសារ និងសហគមន៍" និងលើកស្ទួយទស្សនទានថា "ការថែទាំ

ឬ គ្រួសារអលទ្ធភាព យកទៅផ្ញើក្នុងមណ្ឌលកុមារកំព្រា ឬក្មេងដើរសុំទានជាដើម ទាំងនេះជាភាពផ្ទុយនានៃបរិយាកាសមុនរបស់គាត់។

➢ ទទួលបានការការពារ ៖ កូនសុំដែលបានទៅរស់នៅជាអចិន្ត្រៃយ៍តាមឪពុកម្តាយចិញ្ចឹម (អ្នកសុំ) គឺត្រូវបានការពារយ៉ាងយកចិត្តទុកដាក់ពីសំណាក់ឪពុកម្តាយចិញ្ចឹមក្នុងនាមជាអ្នកមានអំណាចមេបា។ មិនតែប៉ុណ្ណោះទេ គឺកុមារត្រូវបានការពារដោយច្បាប់នៃប្រទេសដែលកុមាររស់នៅជាអចិន្ត្រៃយ៍នោះផងដែរ។

➢ កាតព្វកិច្ចរបស់រដ្ឋដើម ៖ ក្រោយពីបានបញ្ចប់ការសុំកូន កុមារបានទទួលការយកចិត្តទុកដាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស តាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធនឹងសុំកូន ដើម្បីអង្កេតតាមដាន ការរស់នៅជាប្រចាំ តាមរយៈរបាយការណ៍ដែលបញ្ជូនមក ក៏ព្រោះថា កាតព្វកិច្ចក្នុងការឃ្លាំមើលប្រជាជនរបស់ខ្លួន ជាបន្ទុករបស់រដ្ឋដើមផងដែរ។

**កថាភាគទី៣ ៖ ផលប្រយោជន៍ចំពោះអ្នកសុំ**

កត្តាដែលអ្នកសុំខ្នះខ្នែងក្នុងការសុំកូនអ្នកដទៃយកទៅចិញ្ចឹមនេះ គឺមានអត្ថប្រយោជន៍ដល់គាត់ កាលបើបានសម្រេចដូចបំណងហើយនោះ ឯផលប្រយោជន៍ទាំងនោះមានដូចតទៅ ៖

១. ការសម្រេចតាមគោលបំណងរបស់អ្នកដែលចង់ទទួលបានគ្រួសារមួយដែលបរិបូរណ៍ ដែលធ្លាប់ជាគ្រួសារដែលពិការ មានន័យថា គ្រួសារដែលមានប្តីប្រពន្ធ និងកូន មិនខ្វះម្នាក់ណាមួយឡើយ។ ប្រការនេះ គឺជាការបន្តនូវក្តីសង្ឃឹមសម្រាប់មនុស្សដែលបង់ប្រាថ្នាមានកូន ស្របតាមអារម្មណ៍ ក្តីស្រឡាញ់ពីធម្មជាតិរបស់មនុស្ស នាំឱ្យគ្រួសាររបស់គាត់ប្រកបដោយភាពសុខដុមរមនា មានបរិយាកាសសុខសាន្ត សុភមង្គល បូករួមទាំងភាពកក់ក្តៅពីសមាជិកគ្រួសារម្នាក់ៗ បំពេញមនោសញ្ចេតនាដែលខ្វះខាតបាន នេះជាការឆ្លើយតបនូវអ្វីដែលមនុស្សភាគច្រើនចង់បាន។

២. ការបន្តពូជពង្សតាមទិដ្ឋភាពច្បាប់ ដោយជាទូទៅខ្សែលោហិត (តាមលក្ខណៈវេជ្ជសាស្រ្ត) ទើបចាត់ទុកជា ញាតិ។ ហេតុនេះ ការបន្តពូជពង្សតាមទិដ្ឋភាពច្បាប់ គឺអ្នកសុំជាបុគ្គលដែលអលទ្ធភាពក្នុងការបង្កកំណើតដោយខ្លួនឯង ឬមូលហេតុផ្សេងៗទៀត គឺដើម្បីសម្រេចគោលបំណងនេះបាន មានតែអត្ថិភាពនៃច្បាប់គឺការសុំកូនអន្តរប្រទេសនេះ បានបង្កើតអានុភាពដូចគ្នា។

កុមារនៅតាមមណ្ឌលគឺជាជម្រើសចុងក្រោយ និងជាដំណោះស្រាយបណ្តោះអាសន្ន"។ តាមរយៈគោលនយោបាយនេះ ក្រសួងក៏បានលើកទឹកចិត្តដល់ក្រសួង និងស្ថាប័នពាក់ព័ន្ធផ្សេងទៀតឱ្យចូលរួមអនុវត្តគោលនយោបាយ និងកម្មវិធីនានាទាក់ទងនឹងការថែទាំជំនួស កសាងសមត្ថភាពមន្ត្រីដែលធ្វើការជាមួយកុមារបង្កើតនូវប្រព័ន្ធត្រួតពិនិត្យតាមដាន និងវាយតម្លៃ។

៣. តាមរយៈសន្តតិកម្មជាអាទិ៍ គឺកូនសុំនោះអាចបន្តថែរក្សាតាមបណ្តាំ ឬតាមមត៌កបានបន្សល់ទុកដោយជននេះដូចគ្នា។ យ៉ាងណាមិញ កូនសុំជាអ្នកបំពេញនូវតួនាទីជាបុត្តគ្រប់ប្រការដូចគ្នានឹងកូនបង្កើតដែរ។ ចំណុចនេះគឺ មិនអាចកើតមានគ្រប់ករណីនោះទេ ព្រោះបើយោងតាមមាត្រា ២១ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសក៏អនុញ្ញាតឱ្យគ្រួសារដែលមានកូនតែម្នាក់សុំដែរ។

៤. ការមើលថែ ៖ ប្រការនេះ ជាអត្ថប្រយោជន៍ដែលអ្នកសុំបានទទួលក្នុងនាមជាឪពុកម្តាយរបស់គេ ការមើលថែទាំពេលចាស់ជរា ការតបស្នងសងគុណ កតញ្ញូតាធម៌ពីកូនសុំដូចគ្នាដោយសម្របទៅតាមស្ថានភាពនៃសង្គម ទំនៀមទម្លាប់ និងវប្បធម៌របស់ប្រទេសអ្នកសុំនោះ។

៥. ចូលរួមអភិវឌ្ឍន៍ធនធានមនុស្ស៖ សប្បុរសធម៌ និងមនុស្សធម៌ដែលអ្នកសុំធ្វើការជួយដល់កុមារដែលត្រូវការជំនួយទាំងនេះទៅគាត់យ៉ាងពិតប្រាកដ ជាការចូលរួមជ្រោមជ្រែងដល់ធនធានមនុស្ស។

## ផ្នែកទី២ ៖ គុណវិបត្តិនៃសុំកូនអន្តរប្រទេស

គុណវិបត្តនៃសុំកូនអន្តរប្រទេសបែងចែកជាបី គឺគុណវិបត្តិចំពោះឪពុក និង/ឬ ម្តាយបង្កើត ចំពោះកូនសុំ និងអ្នកសុំ។

### កថាភាគទី១ ៖ គុណវិបត្តិចំពោះឪពុក និង/ឬ ម្តាយបង្កើត

គ្មានភាពវិជ្ជមានណា ដែលឥតភាពអវិជ្ជមាននោះទេ។ ហេតុនេះ ការដែលឪពុកម្តាយបានទទួលនូវគុណសម្បត្តិតាមរយៈសុំកូនអន្តរប្រទេសនេះ គុណវិបត្តិការក៏អាចនឹងប្រឈមបានដូចមាន៖

១. ផលវិបាកខាងមនោសញ្ចេតនា ៖ ការសម្រេចចិត្តរបស់ឪពុកម្តាយជាការសំខាន់មួយក្នុងការបង្កើតសុំកូនអន្តរប្រទេស តែវាអាចនាំឱ្យមានភាពប៉ះទង្គិចកើតមាន កាលណាការបរិច្ចាគកូនរបស់ខ្លួនបង្កើត ឬជាញាតិលោហិតទៅឱ្យអ្នកដទៃណាក៏មិនដឹង។ អាស្រ័យហេតុនេះ ក្នុងនាមជាអ្នកសម្រេចចិត្តលើជោគវាសនារបស់កុមារមិនដឹងថាខុស ឬត្រូវបង្កើតទុកកង្វល់សម្រាប់គាត់។

២.ការបារម្ភ ៖ ការព្រួយបារម្ភតាមរយៈការដើរបញ្ច្រាសពីការរំពឹងទុករបស់អ្នកជាឪពុកម្តាយលើការសុំកូននេះទៅជាការលក់-ដូរជួញដូរកុមារ ការធ្វើទារុណកម្ម ឬការបង្ខំ ឬការបង្ខាំង ឬការកេងប្រវ័ញ្ច ឬការបំពានលើរូបរាងកាយ ក្លាយជាការដោះដូរដូចជាទំនិញ។ ផលអាក្រក់ដូចរៀបរាប់ខាងលើ កើតមានតែក្នុងករណីដែលកូនសុំជាកូនដែលមានឪពុកម្តាយបង្កើត ឬឪពុកបង្កើត ឬម្តាយបង្កើត ហើយអលទ្ធភាព ជាគ្រួសារទីទាល់ក្រលំបាក[82] ចំពោះកូនដែលត្រូវបានបោះបង់ ឬកូនកំព្រាវិញ គឺមិនកើតមានករណីនេះទេ។

---

[82] អនុក្រឹត្យលេខ១១៩ អនក្រ.បក ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ, ១១ កញ្ញា ២០០៥

**កថាភាគទី២ ៖ គុណវិបត្តិចំពោះកូនសុំ**

ការបង្កើតស្មុំកូនអន្តរប្រទេស គឺមិនមែនជារឿងធម្មតាទេ ព្រោះវាបង្កើតនូវអានុភាពរបស់វានឹងទៅផ្លាស់ប្តូរនៅអនាគតទាំងស្រុងរបស់កុមារ ឬប្តូរពីមនុស្សទៅមនុស្សម្នាក់ថ្មីទៀត ជាក់ស្តែងកុមារក្លាយជា កូនរបស់អ្នកសុំយ៉ាងពេញច្បាប់។ លទ្ធផលអវិជ្ជមាននៃការបង្កើតស្មុំកូនអន្តរប្រទេសដូចជា៖

១– ការសម្របខ្លួនរបស់កុមារ ៖ ជាធម្មតា ក្មេងមានចរិតជាសភាវគតិ តែងប្រព្រឹត្តតាម ការចង់ចាំ ទទួលយកនូវអ្វីៗដោយសន្សឹមៗ ការដែលគាត់ត្រូវបានប្តូរពីសង្គមមួយទៅសង្គមមួយផ្សេងដែលមិនធ្លាប់ជួបកន្លងមកនឹងបង្កើតនូវភាពភ័យខ្លាច។ ភាពភ័យខ្លាចដែលកុមារឈានដល់បញ្ហាខាងស្មារតីចំពោះការផ្លាស់ប្តូរដោយរហ័សនេះ។

២– ការបោះបង់ចោល ៖ ករណីដែលកុមារក្លាយខ្លួនជាក្មេងទំនើង ឬមានភាពកោងកាច គឺប្រឈមនឹងការបោះបង់ចោលពីសំណាក់អ្នកសុំ។ តាមគោលការណ៍សញ្ជាតិ កុមារត្រូវការពារដោយច្បាប់របស់ប្រទេសទទួលនោះ។

៣– ករណីបទល្មើស ៖ កន្លងមកមានបទល្មើសដែលកើតចេញពីប្រតិបត្តិការស្មុំកូននេះ មុនការអនុវត្តតាមច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស គឺអនុក្រឹត្យលេខ២៩ អនក្រ.បក ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស[83]។

**កថាភាគទី៣ ៖ គុណវិបត្តិចំពោះអ្នកសុំ**

ថ្វីបើមានអត្ថប្រយោជន៍ក្នុងការបង្កើតនូវស្មុំកូនអន្តរប្រទេស ក៏ប៉ុន្តែគុណវិបត្តិចំពោះអ្នកសុំមានដូចតទៅ ៖

១. ទំនួលខុសត្រូវ និងបន្ទុក ៖ អ្នកសុំត្រូវជាប់កាតព្វកិច្ចដែលច្បាប់តម្រូវឱ្យអ្នកមានអំណាចមេបាចំពោះអនីតិជនត្រូវប្រណិបត្តិ គឺការចិញ្ចឹមបីបាច់ មើលថែរក្សា ផ្គត់ផ្គង់គ្រប់វិស័យ និងតម្រូវការរបស់កុមារ អាហារូបត្ថម្ភទាំងរូបរាងកាយ ការអប់រំ បញ្ញាស្មារតី គឺធ្វើយ៉ាងណាធានាដល់ជីវភាពប្រចាំថ្ងៃមានភាពគ្រប់គ្រាន់ មិនតែប៉ុណ្ណោះទទួលខុសត្រូវរាល់ទង្វើដែលជាការទទួលខុសត្រូវក្នុងនាមជាឪពុកម្តាយស្របច្បាប់។

[83] របាយការណ៍លេខ ០០២ ស.អ.យ ស្តីពីការងារស្មុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជា, ទំព័រទី០២ ចំណុចទិ២ អំពីកិច្ចសហប្រតិបត្តិការស្មុំកូនអន្តរប្រទេសកម្ពុជា-អាមេរិក កថាខណ្ឌទី២ សរសេរថា "នៅដើមខែមីនា ឆ្នាំ២០០២ រដ្ឋាភិបាលអាម៉េរិកបានផ្អាកកិច្ចសហប្រតិប្តិការស្មុំកូន ជាមួយកម្ពុជាដោយយកហេតុថាមានការជួញដូរកុមារ ពិសេសយោងហេតុផលលើករណីបទល្មើសដែលរកឃើញចំប្រធានអង្គការអាម៉េរិកម្នាក់ ឈ្មោះ Laryn Galindo ដែលបានឆបោកចំពោះពលរដ្ឋអាម៉េរិក ហើយត្រូវបានអាជ្ញាធរអាម៉េរិកចាប់ខ្លួន"។

២. កាតព្វកិច្ចត្រូវរាយការណ៍ ៖ អ្នកសុំត្រូវមានកាតព្វកិច្ចតាមរយៈច្បាប់ស្ដីពីការសុំកូនអន្តរប្រទេសជាអាទិ៍ ក្រោយពេលដែលអនីតិជនបានទៅរស់នៅជាអចិន្ត្រៃយ៍ជាមួយខ្លួន ក្នុងការរាយការណ៍អំពីស្ថានភាពជាក់ស្ដែងរបស់កុមារពេលបានទៅរស់នៅទីនោះ។ កាតព្វកិច្ចនេះ ត្រូវបន្តតាមការកំណត់របស់ច្បាប់ ហើយមានរយៈពេលដល់អនីតិជនដល់នីតិភាព ១៨ឆ្នាំ។

**ផ្នែកទី៣ ៖ អានុភាពនៃការសុំកូនអន្តរប្រទេស**

សុំកូនអន្តរប្រទេសត្រូវតែជាសុំកូនពេញលេញ។ សុំកូនអន្តរប្រទេសមានអនុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្ដាយ និងកូនអចិន្ត្រៃយ៍ ដោយផ្ដល់ដល់កុមារនូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្ដាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវងាកុមារ និងឪពុកម្ដាយបង្កើតរបស់ខ្លួន។[84] អានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ។ ចំណែកឯអានុភាពនៃសុំកូនអន្តរប្រទេសដោយសាច់ញាតិវិញ មានអានុភាពដូចគ្នានឹងសុំកូនអន្តរប្រទេសករណីខាងលើ រួមទាំងការអនុញ្ញាតឱ្យកូនសុំអាចប្រើនាមត្រកូលឪពុកម្ដាយចិញ្ចឹម ឬ នាមត្រកូលដើមមុនពេលសុំកូនក៏បាន។[85]

[84] ច្បាប់ស្ដីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩, មាត្រា៤១

[85] ប្រកាសលេខ១៣៨ ស.អ.យ. ស្ដីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ, ២៣ មករា ២០១៤, ប្រការ១៧ ទំព័រទី៧

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានស្រាវជ្រាវរួចមក ចំពោះកិច្ចការចងក្រងសារណានេះ អាចធ្វើការសន្និដ្ឋានលើប្រធានបទ "**សុំកូនអន្តរប្រទេស**" ដូចខាងក្រោម ៖

១. ការសិក្សាលើក្របខណ្ឌគតិយុត្តលើទំនាក់ទំនងមួយនៃនីតិអន្តរជាតិឯកជន សម្រាប់បង្កើតសុំកូនអន្តរប្រទេសនេះ គឺបោះជំហានទៅរកការគោរពនូវសិទ្ធិរបស់កុមារជាចម្បងដែលពាក់ព័ន្ធសិទ្ធិរស់រានមានជីវិតតាំងពីកំណើត ហើយដែលត្រូវធានាដោយរដ្ឋ។ ពិសេសនេះ ជាវិធានការមួយក្នុងការស្វែងរកនូវគ្រួសារអចិន្ត្រៃយ៍មួយក្នុងការមើលថែទាំជំនួស ការការពារកុមារ និងរក្សានូវឧត្តមប្រយោជន៍ដល់កុមារ ដើម្បីភាពរីកចំរើន និងការគិតគូរលើអនាគតរបស់កុមារ។

២. ការបង្កើតនូវសុំកូនអន្តរប្រទេសនេះ ត្រូវធានាពីនិយ័តភាពនៃការគោរពតាម គោលការណ៍ លក្ខខណ្ឌ និងលក្ខខណ្ឌពិសេសសម្រាប់កុមារទៅតាមប្រភេទនីមួយៗ បែបបទ និងនីតិវិធីដែលបានកំណត់នៅក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ទើបបង្កើតនូវអានុភាពនៃសុំកូនអន្តរប្រទេស និងដើម្បីធានាថា ឧត្តមប្រយោជន៍របស់កុមារត្រូវបានធានាយ៉ាងពិតប្រាកដ។ ដូចបានរៀបរាប់ខាងលើ ចាប់តាំងពីការពិនិត្យលើគោលការណ៍ទូទៅលក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ត្រូវផ្សារភ្ជាប់នូវការបំពេញបែបបទនៃនីតិវិធីពីរធំៗ ដែលបានធ្វើបំណែងចែកពីកាតព្វកិច្ច និងការទទួលខុសត្រូវលើមុខងារ និងភារកិច្ចរៀងខ្លួនៗ ក្នុងការដំណើរការសុំកូនអន្តរប្រទេសឱ្យស្របតាមលក្ខខណ្ឌច្បាប់។ ប្រតិបត្តិការរបស់រដ្ឋបាលកណ្ដាលសុំកូនអន្តរប្រទេស ក្រោមការទទួលខុសត្រូវរបស់អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេស ក្នុងនីតិវិធីរដ្ឋបាល ទើបបានឈានដល់ការសម្រេចសេចក្ដីដោយតុលាការពីអត្ថិភាពនៃការសុំកូនអន្តរប្រទេសនេះ។ លើសពីនេះ គឺការតាមដានចំពោះកូនសុំ នៅពេលដែលការបង្កើតសុំកូនអន្តរប្រទេសបានបញ្ចប់ គឺជាការបញ្ជាក់ពីកិច្ចខិតខំប្រឹងរបស់ស្ថាប័នមានសមត្ថកិច្ច ដើម្បីស្ទាបស្ទង់ពីភាពជោគជ័យនៃការបង្កើតសុំកូនអន្តរប្រទេសនោះ។

៣. ប្រសិទ្ធភាពដែលបានទទួលពីការបង្កើតសុំកូន ជាកត្តាដែលអាចនាំទៅរកការវាយតម្លៃលើសារៈប្រយោជន៍ក្នុងការបង្កើតរបបសុំកូនអន្តរប្រទេសក្នុងរដ្ឋមួយ ហើយពិតជាអាចស្វែងរកគ្រួសារអចិន្ត្រៃយ៍មួយសម្រាប់កុមារ។ ដោយឡែកក្នុងក្របខណ្ឌនៃការអនុវត្តច្បាប់ស្តីពីសុំកូនអន្តរប្រទេស វាពិតជាអាចរារាំងការបំពាន ការរំលោភសិទ្ធិរបស់កុមារ និងអាចធានាដល់ការការពារសិទ្ធិជាមូលដ្ឋាន និងផ្តល់នូវឧត្តមប្រយោជន៍ដល់កុមារបានមែន។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីស្រាវជ្រាវ និងចងក្រងនូវប្រធានបទ "**សុំកូនអន្តរប្រទេស**" រួចមក សង្កេតឃើញថា បានទទួលការអប់រំច្រើនពាក់ព័ន្ធនឹងគោលបំណងនៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងចំណេះដឹងពាក់ព័ន្ធនឹងការបង្កើត ក៏ដូចជានីតិវិធីនៃការសុំកូនអន្តរប្រទេស ក្នុងវង្វង់នីតិវិធីដែលបានកំណត់ក្នុងច្បាប់សិសេសនេះ។ ហេតុនេះ ក្នុង កិច្ចការស្រាវជ្រាវមួយនេះ បានបំផុសជាគំនិតផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១–សុំឱ្យមានការស្វែងយល់កាន់ស៊ីជម្រៅលើគោលបំណង ការអនុវត្តដែលធានាថា បានគោរពតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស មិនថាលក្ខខណ្ឌសម្រាប់ការបង្កើតសុំកូន និងនីតិវិធីដែលបានកំណត់ដោយច្បាប់នេះ ដោយផ្សារភ្ជាប់នឹងការអនុវត្តតាមគោលការណ៍ដែលមាន។ ម៉្យាង ត្រូវជៀសវាងដាច់ខាត់ការអនុវត្តនីតិវិធីខុស ជាហេតុនាំឱ្យមានភាពគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះកុមារ។

២–គប្បីយកចិត្តទុកដាក់ ធ្វើការអភិវឌ្ឍលើក្របខណ្ឌគតិយុត្តដែលនៅមិនទាន់គ្រប់គ្រាន់ ឬដែលនៅមានភាពខ្វះចន្លោះ ជាអាទិ៍ ពុំទាន់មានបញ្ញត្តិស្តីពីការកាត់កាល់ ឬការទទួលយកកុមារត្រឡប់មកវិញសោះឡើយ ក្នុងករណីណាមួយដែល មានបទល្មើសកើតឡើងចំពោះកុមារដែលបានសុំយកទៅចិញ្ចឹមនៅប្រទេសអចិន្ត្រៃយ៍។ គួរបញ្ជាក់ផងដែរថា ការបង្កើតសុំកូនអន្តរប្រទេសនេះឡើងមិនមែនជា កម្មវត្ថុនៃការបង្កើតនូវបទល្មើសអ្វីមួយនោះទេ ក៏ប៉ុន្តែការស្ថាបនាចំពោះបញ្ហាចន្លោះប្រហោង ឬករណីដែលច្បាប់មិនបានចែងអាចនាំឱ្យមានការពិបាកក្នុងការដោះស្រាយចំពោះបញ្ហានេះនាពេលអនាគត។

៣–វិធានការតាមដាន ស្វែងរកកង្វះខាតដែលមានជាក់ស្តែងចំពោះនីតិវិធីអនុវត្ត គឺភារកិច្ចរបស់ភាគីពាក់ព័ន្ធមិនថា រដ្ឋសាមី អង្គការរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធ ដើម្បីធ្វើការរាយការណ៍ ឃ្លាំមើលចំពោះការអនុវត្តពីលទ្ធផលរបស់អ្នកអនុវត្ត ដើម្បីធានាដល់អនាគតរបស់កុមារដែលបានផ្តល់សម្រាប់សុំកូនអន្តរប្រទេស។ ពេលដែលមានការបញ្ជាក់អំពីអាជ្ញាធរមានសមត្ថកិច្ចបែបនេះ វាបង្ហាញពីតម្លាភាព ភាពស្មោះត្រង់ និងប្រសិទ្ធភាពពិតប្រាកដមួយ ក៏ប៉ុន្តែវិធានការនេះ ដាច់ខាតមិនត្រូវផ្ទុយពីបំណងក្នុងការតាមដានដែលនាំឱ្យក្លាយជាការបំពានសមត្ថកិច្ច ឬភាពឯករាជ្យរបស់ស្ថាប័នទទួលបន្ទុកទៅវិញ។

# ឯកសារយោង

# ឯកសារយោង

- ❖ **ប្រភពពីលិខិតបទដ្ឋានគតិយុត្តនានា**
  - ➢ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣
  - ➢ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស, លេខ២១៧ A(III), ១០ ធ្នូ ១៩៤៨
  - ➢ អនុសញ្ញាស្តីពីសិទ្ធិកុមារ, ២០ វិច្ឆិកា ១៩៨៩
  - ➢ ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស, ២២ មករា ២០០៧
  - ➢ ក្រមរដ្ឋប្បវេណី,នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៨
  - ➢ ច្បាប់ស្តីពីសុំកូនអន្តរប្រទេស, នស/រកម/១២០៩/០២៤, ១៧ វិច្ឆិកា ២០០៩
  - ➢ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ, ១៧ កក្កដា ១៩៨៩
  - ➢ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុងស្ស និងធ្វើអាជីវកម្មផ្លូវភេទ, នស/រកម/០២០៨/០០៥, ១៥ កុម្ភៈ ២០០៨
  - ➢ ច្បាប់ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹង, នស/រកម/០៧១០/០១៣, ២៥ មិថុនា ២០១០
  - ➢ អនុក្រឹត្យលេខ២៩ អនក្រ.បក ស្តីពីការសុំទារកកំព្រា ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅបរទេស, ១៤ មីនា ២០០១
  - ➢ អនុក្រឹត្យលេខ ១១៩ អនក្រ.បក ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ, ១១ កញ្ញា ២០០៥
  - ➢ ប្រកាសអន្តរក្រសួងលេខ ៤៤៨.សហវ.ប្រក ស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស, ១០ មេសា ២០១៣
  - ➢ ប្រកាសលេខ១៣៨ ស.អ.យ. ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ, ២៣ មករា ២០១៤
  - ➢ ប្រកាសលេខ១៣៩ ស.អ.យ. ស្តីពីការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស, ២៣ មករា ២០១៤
  - ➢ ប្រកាសលេខ១៩៤ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា, ០៥ វិច្ឆិកា ២០១៣

- ប្រកាសលេខ១៩៩ ស.អ.យ. ស្តីពីការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស, ០៦ វិច្ឆិកា ២០១៣
- ប្រកាសលេខ២៥០ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស, ៣១ មករា ២០១៣
- ប្រកាសលេខ១២៣០ ស.អ.យ. ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស , ៣០ មេសា ២០១៤
- ប្រកាសលេខ១៩៨០ ស.អ.យ. ស្តីពីនីតិវិធីផ្តល់ការអនុញ្ញាតដល់ទីភ្នាក់ងារសុំកូនអន្តរប្រទេស, ០៧ សីហា ២០១៤
- របាយការណ៍លេខ០០២ ស.អ.យ. ស្តីពីការងារសុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជា, ១២ កុម្ភៈ ២០១៣
- សេចក្តីថ្លែងហេតុ នៃសេចក្តីព្រាងច្បាប់ស្តីពីសុំកូនអន្តរប្រទេស, ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៥

❖ **ប្រភពពីសៀវភៅសិក្សា និងឯកសារស្រាវជ្រាវផ្សេងៗ**

- អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, *សៀវភៅផ្ទត់ស្តីពី នីតិវិធីសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា*
- **កញ្ញា រិន បូរី,** សារណាបញ្ចប់ការសិក្សា ស្តីពី*សុំកូននៅកម្ពុជា,* សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១៧
- **កញ្ញា ឡា សុទ្ធានាថ**, សារណាបញ្ចប់ការសិក្សា ស្តីពី *សុំកូន,* សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ឆ្នាំ២០១៩,
- **លោក ឈិត ចំរើន**, បរិមាណធិប្បាយគតិយុត្ត ស្តីពី *សុំកូនអន្តរប្រទេស*
- **លោកស្រី សាត ធីតា**, "សញ្ញាណនៃទោស" បទបង្ហាញក្នុងសាលាភូមិន្ទក្រឡាបញ្ជី, រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, (២២ មិថុនា ២០២០)
- **លោក ខន សុខេង**, សៀវភៅ ស្តីពី *ការសុំកូន,* (ភ្នំពេញ៖ ចំណារ, ២០២០)
- សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO), របាយការណ៍សង្ខេប *កុមារដែលត្រូវបានបញ្ជូនចេញពីប្រទេសកម្ពុជាដោយលួចលាក់៖ ការក្លែងបន្លំ និងអំពើដែលត្រូវបានអះអាងថា ជាអំពើពុករលួយក្នុងប្រព័ន្ធសុំកូនអន្តរប្រទេស*, ផ្សាយ ខែមីនា ឆ្នាំ២០១៨

❖ **ប្រភពពីគេហទំព័រ**

❖ គេហទំព័រចំណេះដឹងផ្នែកច្បាប់( legal Knowledge), *លក្ខខណ្ឌនៃការបង្កើតសុំកូនអន្តរប្រទេស (នីតិបេតិកភណ្ឌ និងគ្រួសារ)*, https://knowledgelegalkrn.blogspot.com/2017/04/blog-post_52.html(ថតចម្លងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០)

❖ សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ (LICADHO), របាយការណ៍សង្ខេប *កុមារដែលត្រូវបានបញ្ជូនចេញពីប្រទេសកម្ពុជាដោយលួចលាក់៖ ការក្លែងបន្លំ និងអំពើដែលត្រូវបានអះអាងថា ជាអំពើពុករលួយក្នុងប្រព័ន្ធសុំកូនអន្តរប្រទេស*, ផ្សាយខែមីនា ឆ្នាំ២០១៨, https://www.licadho-cambodia.org/reports.php?perm=226&khmer (ថតចម្លងថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០២០)

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធទី១

# ព្រះរាជក្រម

នស/រកម/០២០៧/០០៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី២ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារ កុមារនិងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ដែលធ្វើនៅទីក្រុងឡាអេ នាថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៣ ហើយដែលមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តអនុសញ្ញាអន្តរជាតិនេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០០៧

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ព/ល.០៧០១.០២៤

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
**ហត្ថលេខា**
**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
**ហត្ថលេខា**
**អ៊ិត សំហេង**

លេខ: ៥៧ ធ.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ មករា ឆ្នាំ ២០០៧
អគ្គលេខាធិការរាជរដ្ឋាភិបាល
**ឃុន ជិនកេន**

# អនុសញ្ញាក្រុងឡាអេ

# ស្តីពី

# ការការពារកុមារ និង

# សហប្រតិបត្តិការទាក់ទងនឹង

# សុំកូនអន្តរប្រទេស

# អនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស

( អនុម័ត ថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ១៩៩៣ )

## បុព្វកថា

**រដ្ឋជាភាគីហត្ថលេខីនៃអនុសញ្ញានេះ**

- ដោយទទួលស្គាល់ថាកុមារត្រូវចំរើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ នៅក្នុងបរិយាកាសនៃសុភមង្គល សេចក្តីស្រឡាញ់ និង កិត្តិយស សំរាប់ការចំរើនលូតលាស់ពេញលេញ និងយ៉ាងសុខដុម នៃបុគ្គលិកលក្ខណៈរបស់គេ
- ដោយរំលឹកឡើងវិញថារដ្ឋនីមួយៗ ជាអាទិភាពត្រូវចាត់វិធានការសមស្របដើម្បីឱ្យកុមារស្ថិតក្នុងការបីបាច់រក្សាពីសំណាក់គ្រួសារកំណើតរបស់គេ
- ដោយទទួលស្គាល់ថាសុំកូនអន្តរប្រទេសអាចផ្តល់អត្ថប្រយោជន៍នៃគ្រួសារអចិន្ត្រៃយ៍ដល់កុមារ ដោយសារគេមិនអាចរកគ្រួសារមួយសមស្របបាននៅក្នុងប្រទេសដើមរបស់កុមារនោះ
- ដោយជឿជាក់អំពី ភាពចាំបាច់ក្នុងការចាត់វិធានការ ដើម្បីធានាថាសុំកូនអន្តរប្រទេសគឺធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារ និងដោយសេចក្តីគោរពសិទ្ធិមូលដ្ឋានរបស់កុមារ និងវិធានការដើម្បីបង្ការការចាប់ពង្រត់ការលក់ ឬ ជួញដូរកុមារ
- ដោយមានសេចក្តីប្រាថ្នាចង់បង្កើតបញ្ញត្តិរួមសំរាប់បញ្ហាទាំងអស់នេះ ដោយពិចារណាដល់គោលការណ៍ចែងនៅក្នុងលិខិតូឧបករណ៍អន្តរជាតិ ជាពិសេសអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩ និងសេចក្តីថ្លែងការណ៍នៃអង្គការសហប្រជាជាតិស្តីពីគោលការណ៍សង្គម និងច្បាប់ទាក់ទងនឹងការការពារសុខុមាលភាពកុមារ ដែលយោងជាពិសេសដល់ការដាក់កុមារអោយរស់នៅជាមួយគ្រួសារធម៌ និងសុំកូន នៅក្នុងប្រទេស និងក្រៅប្រទេស (សេចក្តីសំរេចមហាសន្និបាតលេខ ៤១/៨៥ ចុះថ្ងៃទី ៣ ខែធ្នូ ឆ្នាំ១៩៨៦) បានព្រមព្រៀងគ្នាដូចតទៅនេះ :

## ជំពូកទី ១

## វិសាលភាពនៃអនុសញ្ញា

**មាត្រា ១**

គោលបំណងនៃអនុសញ្ញាគឺដើម្បី :

(ក) បង្កើតមធ្យោបាយការពារដើម្បីធានាថា ស្មុំកូនអន្តរប្រទេសធ្វើឡើងក្នុងឧត្តមប្រយោជន៍របស់កុមារនិងដោយសេចក្តីគោរពចំពោះសិទ្ធិជាមូលដ្ឋានរបស់កុមារដូចបានទទួលស្គាល់នៅក្នុងច្បាប់អន្តរជាតិ ។

(ខ) បង្កើតប្រព័ន្ធសហប្រតិបត្តិការក្នុងចំណោមរដ្ឋជាភាគីដើម្បីធានាថា មធ្យោបាយការពារទាំងនោះត្រូវបានគោរព ហើយតាមរយៈប្រព័ន្ធនោះទប់ស្កាត់ ការចាប់ពង្រត់ ការលក់ ឬ ការជួញដូរកុមារ ។

(គ) ធានាអោយមានការទទួលស្គាល់នៅក្នុងរដ្ឋជាភាគីថា ស្មុំកូនត្រូវប្រព្រឹត្តទៅស្របតាមអនុសញ្ញានេះ ។

**មាត្រា ២**

១) អនុសញ្ញានេះត្រូវអនុវត្តក្នុងករណីកុមារម្នាក់មានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋជាភាគីមួយ (រដ្ឋដើម) ត្រូវបានកំពុង ឬនឹងត្រូវបានយកទៅនៅរដ្ឋជាភាគីមួយទៀត (រដ្ឋទទួល) ក្រោយពីការសំរេចលើស្មុំកូន ដោយសហព័ទ្ធ ឬដោយជនម្នាក់ដែលមានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋទទួលបានប្រព្រឹត្តទៅនៅក្នុងរដ្ឋដើម ឬ ក្នុងគោលបំណងស្មុំកូននេះ ការសំរេចលើស្មុំកូនធ្វើឡើងនៅក្នុងរដ្ឋទទួលក្តី ឬរដ្ឋដើមក្តី ។

២) អនុសញ្ញានេះគ្របដណ្តប់តែលើស្មុំកូនទាំងឡាយណា ដែលបង្កើតទំនាក់ទំនងជា ឪពុក/ម្តាយ និងកូនជាអចិន្ត្រៃយ៍ប៉ុណ្ណោះ ។

**មាត្រា ៣**

អនុសញ្ញានេះលែងអនុវត្តបានទៅទៀត បើការព្រមព្រៀងដែលបញ្ជាក់នៅក្នុងមាត្រា១៧ អនុកថាខ័ណ្ឌគ មិនបានធ្វើមុនពេលកុមារឈានដល់អាយុដប់ប្រាំបីឆ្នាំ ។

## ជំពូកទី ២

## លក្ខខណ្ឌតម្រូវសំរាប់ស្មុំកូនអន្តរប្រទេស

**មាត្រា ៤**

ស្មុំកូនដែលស្ថិតក្នុងវិសាលភាពនៃអនុសញ្ញានេះ អាចប្រព្រឹត្តទៅបានលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដើម :

(ក) បានកំណត់ថាកុមារមានលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបាន ។

# ឧបសម្ព័ន្ធទី២

# ព្រះរាជក្រម

នស/រកម/១២០៩/០២៤

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

## ប្រកាសឱ្យប្រើ

ច្បាប់ ស្តីពីសុំកូនអន្តរប្រទេស ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី៣ នីតិកាលទី៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី៦ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់

# ស្តីពី

# សុំកូនអន្តរប្រទេស

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះ មានគោលដៅកំណត់ពីគោលការណ៍ លក្ខខណ្ឌ នីតិវិធី ទម្រង់បែបបទ និង អានុភាពនៃសុំកូនអន្តរប្រទេស ។

**មាត្រា ២.-**

ច្បាប់នេះ មានគោលបំណងធានាឧត្តមប្រយោជន៍ និង ការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ។

**មាត្រា ៣.-**

ច្បាប់នេះ មានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយប្តីប្រពន្ធ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត ដើម្បីយកទៅចិញ្ចឹមជាកូន ដែលទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ ។

**មាត្រា ៤.-**

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់ក្នុងច្បាប់នេះ មាននិយមន័យដូចតទៅ :

- **ការថែទាំជំនួស** សំដៅដល់ការថែទាំ ដែលផ្តល់ទៅឱ្យកុមារកំព្រា និង កុមារងាយរងគ្រោះ ដែលមិនស្ថិតនៅក្រោមការថែទាំរបស់ឪពុកម្តាយបង្កើតនៃកុមារទាំងនោះ ។
- **កុមារដែលត្រូវការនូវការថែទាំពិសេស** សំដៅដល់កុមារពិការផ្នែកកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ ។
- **កុមារដែលត្រូវបោះបង់ចោល** សំដៅដល់កុមារដែលអាជ្ញាធរមានសមត្ថកិច្ចរកឃើញ ឬ ត្រូវបានសាធារណជនរាយការណ៍ទៅអាជ្ញាធរមានសមត្ថកិច្ច និង ជាកុមារដែលមិនស្គាល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ ជាកុមារដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបោះបង់ចោល និង រកមិនឃើញអ្នកទាំងនោះ យ៉ាងតិច ៥ (ប្រាំ) ខែជាប់គ្នា ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

- **ជនម្នាក់** សំដៅដល់ជនដែលគ្មានសហព័ទ្ធស្របច្បាប់ ។

- **ទីភ្នាក់ងារសុំកូនអន្តរប្រទេស** សំដៅដល់ទីភ្នាក់ងារដែលបានទទួលការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និង ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលកូនសុំ ដើម្បីធ្វើប្រតិបត្តិការក្នុងនីតិវិធីសុំកូនអន្តរប្រទេស ។

- **បុត្តភាព** សំដៅដល់ក្រសែញាតិ ដែលទាក់ទងពីឪពុកម្តាយទៅកូនបង្កើតរបស់ខ្លួន ។

- **ប្រទេសលំនៅឋានអចិន្ត្រៃយ៍** សំដៅដល់ប្រទេសដែលជនណាម្នាក់កំពុងរស់នៅដោយមានបំណងយកប្រទេសនោះធ្វើជាលំនៅឋានអចិន្ត្រៃយ៍ ។ ជននោះត្រូវបានទទួលស្គាល់ដោយច្បាប់នៃប្រទេសដែលខ្លួនរស់នៅ ថាមានសិទ្ធិរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសនោះ ។

- **មណ្ឌលកុមារកំព្រា** សំដៅដល់មណ្ឌលរបស់រដ្ឋ ឬ របស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលស្គាល់ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច សម្រាប់ចិញ្ចឹមថែទាំ និង ផ្តល់នូវតម្រូវការជាមូលដ្ឋានគ្រប់យ៉ាងក្នុងការអភិវឌ្ឍរបស់កុមារដែលគ្មានឪពុកម្តាយ ឬ គ្មានឪពុក ឬ គ្មានម្តាយ ឬ កុមារ ដែលត្រូវបោះបង់ចោល ឬ កុមារដែលឪពុកម្តាយ ឬ អ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់ ។

- **ប្តីប្រពន្ធ** សំដៅដល់បុរសម្នាក់ និង ស្ត្រីម្នាក់ដែលមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់ ។

- **សុំកូនដោយសាច់ញាតិ** សំដៅដល់ការសុំកូនដោយអ្នកសុំនូវកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន ។

- **សុំកូនពេញលេញ** សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ ជាឪពុកម្តាយ និង កូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំ និង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់ខ្លួន ។

- **អ្នកសុំ** សំដៅដល់ប្តីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ។

- **ឪពុកម្តាយចិញ្ចឹម** សំដៅដល់ប្តីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី

តុលាការមានសមត្ថកិច្ច ឱ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់នេះ ។

## ជំពូកទី ២
## គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស

**មាត្រា ៥.-**

សុំកូនអន្តរប្រទេសត្រូវអនុវត្តតាមគោលការណ៍ដូចតទៅ :

១- កុមារត្រូវចម្រើនធំធាត់នៅក្នុងបរិយាកាសគ្រួសារ បរិយាកាសសុភមង្គល សេចក្តីស្រឡាញ់ និង ការយោគយល់ ដើម្បីឱ្យមានការអភិវឌ្ឍពេញលេញ និង យ៉ាងសុខដុមនូវបុគ្គលិកលក្ខណៈរបស់ខ្លួន ។ សុំកូនអន្តរប្រទេស អាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្តល់ការឧបត្ថម្ភគាំទ្រ ដើម្បីឱ្យកុមាររស់នៅក្នុងគ្រួសារកំណើត និង ក្រោយពីបានធ្វើការពិចារណា អំពីសុំកូននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

២- សុំកូនអន្តរប្រទេស អាចប្រព្រឹត្តទៅបានលុះត្រាតែជាសុំកូនពេញលេញ ដែលបង្កើតនូវទំនាក់ទំនងរវាងអ្នកសុំ និង កូនសុំជាអចិន្ត្រៃយ៍ និង ដែលផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ ។

៣- កុមារទាំងឡាយណាដែលបំពេញបាននូវលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១០ អាចធ្វើជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបានដោយមិនមានការរើសអើងអំពីពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិកំណើត ឋានៈក្នុងសង្គម ធនធាន ពិការភាព ឬ ស្ថានភាពផ្សេងៗទៀតរបស់កុមារ ឬ របស់ឪពុកម្តាយ ឬ របស់ឪពុក ឬ របស់ម្តាយ ឬ របស់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

៤- រាល់ការសម្រេច និង សកម្មភាពទាក់ទងនឹងដំណើរការសុំកូនអន្តរប្រទេស ត្រូវគិតគូរឱ្យបានច្រើនលើសលប់ដល់ឧត្តមប្រយោជន៍របស់កុមារ ។

៥- តុលាការ និង អាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការសុំកូនអន្តរប្រទេសត្រូវធានាថា នៅពេលកំពុងដំណើរការនីតិវិធីសុំកូន កុមារដែលមានសមត្ថភាពអាចបង្កើតយោបល់ ត្រូវបានពិគ្រោះយោបល់ និង ពន្យល់ណែនាំឱ្យបានត្រឹមត្រូវអំពីអានុភាព

ទានា ដែលកើតចេញពីសុំកូននេះដោយគិតគូរដល់សេចក្តីប្រាថ្នា និង មតិរបស់កុមារ ដើម្បីឧត្តមប្រយោជន៍របស់កុមារ ។

៦- ហាមការធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេស ។ អាជីវកម្ម ឬ សកម្មភាពយកផលកម្រៃពីសុំកូនអន្តរប្រទេសមាន :

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឱ្យបោះបង់ទារកដែលកើតមកហើយ ឬ ដែលនឹងកើតដើម្បីឱ្យប្រគល់កូនតាមរយៈសុំកូនអន្តរប្រទេស

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ឪពុក ឬ ម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬ ដែលនឹងកើត និង

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្តីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និង ស្ត្រីម្នាក់យល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឱ្យអ្នកសុំ ។

៧- អាជ្ញាធរមានសមត្ថកិច្ច ដែលពាក់ព័ន្ធក្នុងនីតិវិធីសុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការសុំកូនអន្តរប្រទេស មិនបណ្តាលឱ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ និង ត្រូវបង្ការមិនឱ្យមានការចាប់ពង្រត់ ការលក់ និង ការជួញដូរកុមារក្នុងពេលកំពុងដំណើរការសុំកូនអន្តរប្រទេស ។ មានតែប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាន ដែលកំណត់ដោយបទប្បញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់ ។

## ជំពូកទី ៣
## អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

**មាត្រា ៦.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ។

ប្រទេស ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស ឬ ការដកហូតការអនុញ្ញាត ជូនអាជ្ញាធរកណ្តាលទទួលខុសត្រូវកិច្ចការសុំកូនអន្តរប្រទេស ។

១០- បំពេញភារកិច្ចផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសតាមការចាំបាច់ ដោយអនុលោមទៅតាមច្បាប់ និង បទបញ្ញា របស់ព្រះរាជាណាចក្រកម្ពុជា និង តាមការប្រគល់អំណាចរបស់អាជ្ញាធរកណ្តាល ។

## ជំពូកទី ៤
## លក្ខខណ្ឌសម្រាប់សុំកូន
### ផ្នែកទី ១
### កូនសុំ

**មាត្រា១០.–**

កុមារដែលអាចជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌទាំងអស់ ដូចខាងក្រោម៖

១- កុមារសញ្ជាតិខ្មែរដែលមានលំនៅឋានជាអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា ។

២-កុមារមានអាយុក្រោម៨ (ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែករណីកុមារត្រូវការទូវការថែទាំពិសេស ដែលអាចអនុញ្ញាតបានដល់អាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ ក្នុងករណី កុមារមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី) ឆ្នាំ អាចអនុញ្ញាតឱ្យសុំកុមារនោះរួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។

៣- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

៤- កុមារទាំងនោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត ។

៥- កុមារនោះត្រូវបានប្រកាសថាអាចសុំជាកូនចិញ្ចឹមបាន ដោយអនុលោមតាមមាត្រា ១៦ នៃច្បាប់នេះ ។

10/35 Kol

ក្នុងករណីសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ដែលរស់នៅក្នុង ឬ ក្រៅមណ្ឌលកុមារកំព្រា ។

**មាត្រា ១១.-**

ករណីមានកុមារត្រូវបានរកឃើញ និង បញ្ជូនមកមណ្ឌលកុមារកំព្រា ហើយរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ប្រធានមណ្ឌលកុមារកំព្រា ត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត អំពីវត្តមានរបស់កុមារ ដែលបានចូលមកស្នាក់នៅក្នុងមណ្ឌល យ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីពេលដែលកុមារមកដល់មណ្ឌល ។ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីបញ្ចូលឈ្មោះកុមារទៅក្នុងបញ្ជី ស្តីពីកុមារដែលត្រូវបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល ។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាលសម្រាប់អនីតិជនមុន នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសាធារណៈទៅតាមលទ្ធភាពដូចជា ទូរទស្សន៍ វិទ្យុ ឬ សារព័ត៌មាន និង រូបភាពរបស់កុមារនោះ ។ ជនណាដែលអះអាងថាខ្លួនជាឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទងជាសាច់ញាតិ ឬ អ្នកអាណាព្យាបាល សម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទប្បញ្ញត្តិជាធរមាន ។

បន្ទាប់ពីការផ្សព្វផ្សាយដំណឹងរយៈពេល ៥ (ប្រាំ) ខែ នៅតែរកមិនឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ និង អ្នកអាណាព្យាបាល សម្រាប់អនីតិជនមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការខិតខំស្រាវជ្រាវនេះ ហើយត្រូវផ្ញើមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល ។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការ បានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត គឺជាអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ បញ្ញត្តិស្តីពីអាណាព្យាបាលសម្រាប់អនីតិជនដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ត្រូវយកអនុវត្តផងដែរ ចំពោះអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន ។ អ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន គ្មានសិទ្ធិផ្តល់ការយល់ព្រមលើសុំកូនទេ ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលត្រូវបោះបង់ចោល ។

ករណីកុមារដែលត្រូវបោះបង់ចោលពុំអាចរកឃើញឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហើយពុំមានសំបុត្រអត្រានុកូលដ្ឋានកំណើត ប្រធានមណ្ឌលកុមារកំព្រា ត្រូវសុំចុះសៀវភៅអត្រានុកូលដ្ឋានកំណើតកុមារនោះទៅតាមបទប្បញ្ញត្តិច្បាប់ជាធរមាន ។

**មាត្រា ១២.-**

ប្រសិនបើ អ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចត្រូវរៀបចំបញ្ជី និង បញ្ចូលព័ត៌មានថ្មីៗឱ្យបានទៀងទាត់ស្តីពីកុមារដែលអ្នកអនុវត្តអំណាចមេបារបស់ខ្លួន បានធ្វើការទុកដាក់កុមារឱ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

**មាត្រា ១៣.-**

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវខិតខំឱ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើត ហើយបើមិនអាចធ្វើទៅបានទេ ត្រូវទុកដាក់កុមារតាមរយៈសុំកូនក្នុងស្រុកនៅក្នុងព្រះរាជាណាចក្រកម្ពុជា មុននឹងពិនិត្យរកលក្ខណសម្បត្តិសុំកូនអន្តរប្រទេសរបស់កុមារ ។

នៅពេលវិធានការនានា ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវបានបញ្ចប់ កុមារអាចនឹងត្រូវបានបញ្ចូលឈ្មោះទៅក្នុងបញ្ជីស្តីពីកុមារដែលកំណត់ថាមានលក្ខណ-សម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស ។

## ផ្នែកទី ២

## ការយល់ព្រមលើសុំកូន

**មាត្រា១៤.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបានលុះត្រាតែមានការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចខាងក្រោមនេះ :

ក- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុក និង ម្តាយ ការយល់ព្រមត្រូវផ្តល់ដោយឪពុក និង ម្តាយរបស់កុមារនោះ ។

ខ- ក្នុងករណីដែលឪពុក ឬ ម្តាយណាមួយរបស់កុមារបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយឪពុក ឬ ម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់ ។

គ- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬ ស្ថិតនៅក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬ ត្រូវបានដកហូតអំណាចមេបា ការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ ។

**មាត្រា១៥.-**

ការយល់ព្រមខាងលើត្រូវផ្តល់ឱ្យដោយសេរី និង ច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជា ការបង្ខិតបង្ខំ ការឆបោក ឬ ការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬ ការសន្យាផ្តល់ប្រាក់ រង្វាន់ សំណង ឬ ផលប្រយោជន៍ណាមួយឡើយ និង ដោយបានដឹងច្បាស់អំពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស ។

**មាត្រា១៦.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលបានទទួលការអនុញ្ញាតជាមុនសិន មុននឹងផ្តល់ការយល់ព្រម ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវប្រាប់យ៉ាងច្បាស់លាស់ ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រម ការបញ្ចប់នូវបុត្តភាព ព្រមទាំងការបញ្ចប់សិទ្ធិនិងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន និង ត្រូវប្រាប់អំពីបែបបទ និង រយៈពេលបញ្ឈប់ការយល់ព្រមដូចមានចែងក្នុងមាត្រា ១៧ នៃច្បាប់នេះ ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

មេឃុំ ឬ ចៅសង្កាត់ និងភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធានាថា រាល់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ជាការយល់ព្រមដែលគោរពទៅតាមខ្លឹមសារនៃមាត្រា ១៥ នៃច្បាប់នេះ ។

មេឃុំ ឬ ចៅសង្កាត់ ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថា ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចបានពិគ្រោះយោបល់ជាមុនជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និង បានប្រាប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ ។

**មាត្រា១៧.-**

ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មុនពេលសេចក្តីសម្រេចរបស់តុលាការស្តីពីការផ្តល់កូនចិញ្ចឹមជាស្ថាពរ ។ ការបញ្ឈប់ការយល់ព្រមរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចធ្វើជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ នៅចំពោះមុខមេឃុំ ឬ ចៅសង្កាត់ខាងលំនៅឋានរបស់ខ្លួន ។ មេឃុំ ឬ ចៅសង្កាត់ខាង

ROYAUME DU CAMBODGE ... LE MINISTRE DU PALAIS

KK35 Ksl

លំនៅឋានរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និង ត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្ដីបញ្ជាក់នៅលើកំណត់ហេតុនោះ ទៅឱ្យឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ។

**មាត្រា ១៨.-**

ដំណើរការសុំកូនអាចប្រព្រឹត្តទៅបាន លុះត្រាតែផុតកំណត់ពេល ៩០ (កៅសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយការយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ។

**មាត្រា ១៩.-**

ករណីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាចប្ដឹងសុំឱ្យតុលាការប្រកាសដកហូតអំណាចមេបាពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ បញ្ឈប់ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថា ការបដិសេធ ឬ ការបញ្ឈប់ការយល់ព្រមនេះ ធ្វើឱ្យបាត់បង់ផលប្រយោជន៍របស់កុមារ ឬ បណ្ដាលឱ្យប៉ះពាល់ដល់សុខភាព សុវត្ថិភាព ឬ សីលធម៌របស់កុមារ ។ ពាក្យបណ្ដឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ ក្រោយពីឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ បដិសេធ ឬ បញ្ឈប់ការយល់ព្រមរបស់ខ្លួន ។

**មាត្រា ២០.-**

ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ដែលយល់ថា ការយល់ព្រមរបស់ខ្លួនបានមកពីការបង្ខាញឆន្ទៈដែលមានវិការៈ ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អាចបញ្ឈប់ ឬ លុបចោលនូវការយល់ព្រមរបស់ខ្លួនបាន រហូតដល់មុនដីកាសម្រេចរបស់តុលាការលើសុំកូនចូល

## ផ្នែកទី ៣

## អ្នកសុំ

**មាត្រា ២១.-**

អ្នកសុំដែលអាចអនុញ្ញាតឱ្យ សុំកុមារយកទៅចិញ្ចឹមជាកូនបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌ ដូចតទៅ :

១-អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី ៣០(សាមសិប)ឆ្នាំ និង មានអាយុលើសកូនសុំយ៉ាងតិច ២២(ម្ភៃពីរ)ឆ្នាំ និង យ៉ាងច្រើនបំផុត ៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន ។

២-ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុច ១ ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឱ្យ បាន ក្នុងស្ថានភាពដូចតទៅ :

ក-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬ

ខ-អ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត ឬ

គ-អ្នកសុំ សុំកុមារដែលត្រូវការការថែទាំពិសេស ឬ ស្ថានភាពផ្សេងទៀត ដែលបម្រើឧត្តមប្រយោជន៍របស់កុមារ ។

៣-ក្នុងករណីអ្នកសុំមានប្តី ឬ ប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាង សុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀត ។

៤-ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និង ច្បាប់ប្រទេសនៃលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និង អនុញ្ញាតនូវបុគ្គភាពនៃសុំកូនពេញលេញ ។

៥-ប្រទេសនៃសញ្ជាតិ ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសដែលមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា ។

៦-អ្នកសុំត្រូវមានលក្ខណសម្បត្តិ និង លក្ខខណ្ឌជាសារវន្តនានាសម្រាប់សុំកូនស្របទៅតាមច្បាប់ប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួន ។



៧-អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្ដន្ទាទោស ឬ កំពុងត្រូវបានប្ដឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមារយាទ ឬ ការប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬ ប្រទេសលំនៅឋានអចិន្ត្រៃយ៍ ឬ ក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ ។

៨-អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្ដល់ការថែទាំសមស្រប និង ការគាំទ្រចាំបាច់ដល់កូនសុំ ។

៩-អ្នកសុំត្រូវបានអនុញ្ញាតឱ្យសុំកូនបាន លុះត្រាតែអ្នកសុំកូនគ្មានកូន ឬ មានកូនតែម្នាក់នៅក្នុងបន្ទុក ។ អ្នកសុំអាចសុំកូនបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឱ្យសុំច្រើននាក់បាន ។

## ជំពូកទី ៥
## នីតិវិធីសុំកូន
### ផ្នែកទី ១
### នីតិវិធីរដ្ឋបាល

**មាត្រា ២២.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារ ភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ និង ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និង សេចក្ដីត្រូវការជាពិសេសណាមួយរបស់កុមារ ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរថា រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របទៅតាមបទប្បញ្ញត្តិនានានៃច្បាប់នេះ ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ ឬ ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ សាច់ញាតិ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ ។

**មាត្រា ២៣.-**

អ្នកសុំត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយភ្ជាប់មកជាមួយនូវឯកសាររួមមាន :

១-ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់ខ្លួន ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណសម្បត្តិ និង មានភាពសមស្របសម្រាប់សុំកូនដោយផ្អែកលើការវាយតំលៃលើជីវប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ បរិយាកាសសង្គម មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុកភ្ញាប់រងចំពោះសុំកូនអន្តរប្រទេស ។

២-ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានាដែលមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ ។

៣-ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន ។

៤-ព័ត៌មានទាក់ទងនឹងលក្ខណសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន ។

៥-ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល ។

ឯកសារទាំងអស់ ត្រូវបញ្ជាក់ដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ឯកសារច្បាប់ដើមទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំង ដែលមានការបញ្ជាក់ត្រឹមត្រូវ ។

មាត្រា ២៤.-

ពាក្យសុំដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ត្រូវបញ្ជូនមកក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសទទួលប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ។ ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវពិនិត្យផ្តល់យោបល់ និង ត្រូវបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេស ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំ ។ ក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃបានទទួលពាក្យសុំពីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថា ខ្លួនបានទទួលពាក្យសុំកូន ។

មាត្រា ២៥.-

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទាននានា សម្រាប់ជួយឧបត្ថម្ភដល់ជីវភាពនានានៃការថែទាំជំនួស និង ការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និង កម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ក្រៅពីនេះ មិនត្រូវយកថ្លៃសោហ៊ុយសុំកូនពីអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូន ។ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនបង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយៗដែលនឹងត្រូវបញ្ជូនទៅឱ្យមណ្ឌលកុមារកំព្រាណាមួយ ឬ មិនអនុញ្ញាតឱ្យអ្នកសុំកូន ឬ ទីភ្នាក់ងាររបស់អ្នកសុំកូនធ្វើការផ្តល់សោហ៊ុយ អំណោយ ឬ ការទូទាត់ ទោះក្នុងរូបភាពណាក៏ដោយឱ្យទៅមណ្ឌលកុមារកំព្រាដែលកុមារនៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬ ទៅឱ្យបុគ្គលិក នាយក ឬ សមាជិកនៃគណៈគ្រប់គ្រងទោះជាដោយផ្ទាល់ ឬ ដោយប្រយោលក្តី ។

9/35

Kol

**មាត្រា ២៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលសំណុំលិខិតសុំកូន ដូចមានចែងក្នុងមាត្រា ២៣ នៃច្បាប់នេះ ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវបញ្ជាក់ថា អ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេស មិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជូនដំណឹងទៅអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលឯកសារដែលនៅខ្វះ ឬ កែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬ មិនទាន់ត្រឹមត្រូវក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសបានជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬ មិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ ។

ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ ។

**មាត្រា ២៧.-**

ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និង ត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយដែលមានលក្ខណសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និង ត្រូវផ្គូផ្គងអំពីលក្ខណសម្បត្តិរបស់អ្នកសុំណាដែលត្រូវគ្នាល្អបំផុតនឹងលក្ខណសម្បត្តិរបស់កុមារ ។

ក្នុងការផ្តល់ផ្តងដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិចារណាឱ្យបានសមស្របទៅលើអត្ថប្រយោជន៍នៃការបន្តឱ្យមានការបីបាច់ ថែរក្សាកុមារ ដូចពេលកន្លងមក ព្រមទាំងពិចារណាទៅលើសាវតារសង្គម ជាតិពន្ធុ សាសនា និង វប្បធម៌របស់កុមារ ។

**មាត្រា ២៨.-**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្តល់ផ្តង រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការយល់ព្រមចាំបាច់នានា ត្រូវបានទទួលរួចហើយ និង មូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារជាមួយអ្នកសុំនោះទៅអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យនិងបញ្ជូនទៅអ្នកសុំដោយមិនចាំបាច់ជូនដំណឹងអំពីអត្តសញ្ញាណឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែករណីសុំកូនដោយសាច់ញាតិ ។

**មាត្រា ២៩.-**

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមសុំកុមារ ដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្តល់ផ្តងឱ្យតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

ក្នុងករណីអ្នកសុំមិនបានឆ្លើយតបមករដ្ឋបាលសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃដែលរដ្ឋបាលសុំកូនអន្តរប្រទេសបានផ្ញើសំណុំឯកសាររបស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសអាចចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្តល់ផ្តងកុមារនោះឱ្យទៅអ្នកសុំផ្សេងទៀតបាន ។ ប្រាក់ចំណាយ សោហ៊ុយ និង វិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានបង្វិលជូនវិញឡើយ ។

ក្នុងករណីអ្នកសុំបានឆ្លើយតបថាមិនទទួលយកកុមារដែលបានផ្តួផ្គងឱ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឱ្យរដ្ឋបាលសុំកូនអន្តរប្រទេសផ្គូផ្គងកុមារជាលើកទីពីរបាន ។ ការផ្គូផ្គងនេះមិនត្រូវអនុញ្ញាតឱ្យធ្វើជាលើកទីបីឡើយ ។

ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រានេះ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសាជាថ្មីស្របតាមនីតិវិធីនៃច្បាប់នេះ ។ ក្នុងការសម្រេចអំពីការសុំឱ្យមានការផ្គូផ្គងសាជាថ្មី ឬ ការទទួលពាក្យសុំកូនសាជាថ្មី រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬ ឆ្លើយតបថា មិនមានបំណងសុំកុមារដែលបានផ្គូផ្គងពីលើកមុននាពេលកន្លងមក ។

**មាត្រា ៣០.-**

បន្ទាប់ពីអ្នកសុំ បានបញ្ជាក់ការយល់ព្រមរបស់ខ្លួនស្របតាមបទប្បញ្ញត្តិក្នុងមាត្រា ២៩ នៃច្បាប់នេះ ហើយអាជ្ញាធរកណ្តាលនៃប្រទេសទទួល បានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ត្រូវរៀបចំឱ្យមានការជួបគ្នារវាងអ្នកសុំ និង កុមារដែលត្រូវបានផ្គូផ្គងរួចហើយ ។

ការជួបគ្នានេះត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និង រដ្ឋបាលសុំកូនអន្តរប្រទេស និង ត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង ។ ការជួបគ្នានេះ ត្រូវធ្វើក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ ។

មុនការជួបគ្នារវាងអ្នកសុំ និង កុមារ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើសម្ភាសន៍អ្នកសុំ និង ធានាថា អ្នកសុំ និង កុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មាន ការផ្លាស់ប្តូររូបថត និង វិធានការចាំបាច់ផ្សេងៗទៀត ដើម្បីការជួបគ្នានេះ ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឱ្យទៅសហព័ទ្ធម្ខាងទៀត ធ្វើជាអ្នកតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូននោះ ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ។

2/35k

Kol

ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើ ដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបាន ព្រមទាំងប្រាប់កុមារឱ្យបានដឹងអំពីអានុភាពដែលកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវយល់ដឹងឱ្យបានច្បាស់ អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូន ក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និង កម្រិតយល់ដឹងរបស់កុមារ ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និង ការជួបគ្នាខាងលើនេះ ។

**មាត្រា ៣១.-**

បទប្បញ្ញត្តិ ដែលមានចែងក្នុងជំពូកនេះត្រូវយកមកអនុវត្តផងដែរចំពោះសុំកូនដោយសាច់ញាតិ ។

**មាត្រា ៣២.-**

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និង កុមារបំពេញបាននូវលក្ខណវិនិច្ឆ័យ និង លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និង កុមារ ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំការពិនិត្យ និង ផ្តល់អនុសាសន៍លើដំណើរការសុំកូន ។

ROYAUME DU CAMBODGE — LE MINISTRE DU PALAIS ROYAL

**មាត្រា ៣៣.–**

ក្រោយពីទទួលអនុសាសន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដាក់ពាក្យសុំកូនដែលបានផ្តិតផ្តងរួច តាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចសុំកូន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និង អ្នកសុំ ព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និង មានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស ។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ។

## ផ្នែកទី ២
## នីតិវិធីតុលាការ

**មាត្រា ៣៤.–**

សាលាដំបូងរាជធានីភ្នំពេញ មានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ។

តុលាការដែលមានយុត្តាធិការលើរឿងក្តីសុំកូនអន្តរប្រទេស ត្រូវយកបទប្បញ្ញត្តិស្តីពីនីតិវិធីរឿងក្តីរដ្ឋប្បវេណី ដែលមិនមែនជាបណ្តឹងមកអនុវត្តចំពោះនីតិវិធីតុលាការទាក់ទងនឹងសុំកូនអន្តរប្រទេស លើកលែងតែមានបទប្បញ្ញត្តិពិសេសដូចមានចែងនៅក្នុងច្បាប់នេះ ។

**មាត្រា ៣៥.–**

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន ១.០០០.០០០ (មួយលាន) រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និង សកម្មភាពខាងនីតិវិធីផ្សេងៗទៀត

ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស ។ តុលាការត្រូវបង្គាប់ឱ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន ។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០ (មួយលាន) រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែម និង បង្គាប់ឱ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះជាមុន ។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញទេ ។

**មាត្រា ៣៦.-**

ជាគោលការណ៍ សំណុំឯកសារ និង របាយការណ៍ដែលដាក់ជូនតុលាការដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្តុតាងនៃអង្គហេតុពិតទាក់ទងនឹងលក្ខណសម្បត្តិ សុំកូនរបស់កុមារ និង ភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំលើកលែងតែមានភស្តុតាងផ្ទុយមកបញ្ជាក់ ។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឱ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសរួមទាំងឯកសារ របាយការណ៍ និង ភស្តុតាងជាឯកសារពាក់ព័ន្ធដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ ។

**មាត្រា ៣៧.-**

តុលាការត្រូវពិនិត្យផ្ទៀងផ្ទាត់ថា :

ក- លក្ខណវិនិច្ឆ័យ ឬ លក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ ។

ខ- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្តល់ការយល់ព្រម ។

គ- ការយល់ព្រមចាំបាច់នានាត្រូវបានផ្តល់ ដោយគោរពតាមខ្លឹមសារផ្នែកទី ២ ជំពូកទី ៤ នៃច្បាប់នេះ ។

ឃ- មានការពិចារណាត្រឹមត្រូវលើគ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល យល់ព្រមលើការទុកដាក់កុមារ ។

ច- កុមារនឹងត្រូវបានអនុញ្ញាតឱ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេស [illegible]

[illegible] សុំកូនអន្តរប្រទេសនេះពិតជាឧត្តមប្រយោជន៍របស់កុមារ ។

មាត្រា ៣៨.-

តុលាការសម្រេចសេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់តាមការទាញហេតុផលដោយផ្ទាល់មាត់ឡើយ ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬ អ្នកតំណាង ឬ អ្នកមានអំណាចមេបាម្ខាង ឬ ទាំងពីរ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬ នត្ថិភាពនៃអង្គហេតុ ។

មាត្រា ៣៩.-

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន ។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូនសុំ និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ ដែលបានកំណត់នៅក្នុងមាត្រា ៤០ នៃច្បាប់នេះ ។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ ។

មាត្រា ៤០.-

បុគ្គលដែលមានសិទ្ធិ ឬ ផលប្រយោជន៍របស់ខ្លួនត្រូវបានបំពានដោយដីកាសម្រេចលើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ ចំពោះដីកាសម្រេចនោះបាន ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច ។

ក្នុងករណីដែលបុគ្គលអាចប្តឹងជំទាស់ មិនមែនជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ)

ROYAUME DU CAMBODGE LE MINISTRE DU PALAIS

ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច ។

អំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ ដែលកំណត់ក្នុងកថាខណ្ឌទី ២ និង ទី ៣ ខាងលើមិនអាចពន្យារបានឡើយ ។

សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និង ចេញដីកាសម្រេចក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យបណ្តឹងជំទាស់ ។

ដីកាសម្រេចរបស់សាលាឧទ្ធរណ៍លើបណ្តឹងជំទាស់មិនអាចប្តឹងជំទាស់ទៀតបានឡើយ ។

## ជំពូកទី ៦
## អានុភាពនៃសុំកូន

**មាត្រា ៤១.-**

សុំកូនអន្តរប្រទេសត្រូវតែជាសុំកូនពេញលេញ ។ សុំកូនអន្តរប្រទេសមានអានុភាពបង្កើតនូវទំនាក់ទំនងញាតិភាពរវាងឪពុកម្តាយ និង កូនជាអចិន្ត្រៃយ៍ ដោយផ្តល់ដល់កុមារនូវឋានៈ សិទ្ធិ និង កាតព្វកិច្ចដូចជាកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម ហើយវាបញ្ចប់ញាតិភាពរវាងកុមារ និង ឪពុកម្តាយបង្កើតរបស់ខ្លួន ។

**មាត្រា ៤២.-**

អានុភាពផ្សេងទៀតនៃសុំកូនអន្តរប្រទេស ត្រូវគ្រប់គ្រងដោយច្បាប់ជាតិរបស់អ្នកសុំ ឬ ប្រសិនបើគ្មានច្បាប់រួមមួយទេ ត្រូវគ្រប់គ្រងដោយច្បាប់នៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

## ជំពូកទី ៧
## ការជូនដំណឹងពីចំណាត់ការ និង នីតិវិធី
## បន្ទាប់ពីបញ្ចប់ដំណើរការសុំកូនអន្តរប្រទេស

**មាត្រា ៤៣.-**

អ្នកជាប់សុំកូនអន្តរប្រទេស ត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅនៃនីតិវិធីសុំកូនដល់អាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និង ការវិវត្តនៃការសុំកូននៅគ្រប់

ដំណាក់កាលរបស់នីតិវិធីសុំកូនឱ្យបានទៀងទាត់ ទៅអ្នកសុំតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាត ។

**មាត្រា ៤៤.-**

ក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវជូនដំណឹងទៅក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អំពីដីកាសម្រេចនេះ ។

នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ ដោយអនុលោមទៅតាមអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និង សហប្រតិបត្តិការ ទាក់ទងនឹងសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចេញលិខិតបញ្ជាក់អនុលោមតាមមាត្រា ២៣ នៃអនុសញ្ញានេះ ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំពិធីប្រគល់កុមារ និង លិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជួយសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ច ក្នុងការរៀបចំ និង ផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និង ឯកសារចាំបាច់នានា ដើម្បីឱ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថាការផ្ទេរកុមារទៅកាន់ប្រទេសទទួល ប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ ។

**មាត្រា ៤៥.-**

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬ សម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់ ។

ក្រោយពីកុមារត្រូវបានទទួលការអនុញ្ញាតឱ្យធ្វើជាកូន ឪពុកម្តាយចិញ្ចឹមត្រូវផ្តល់របាយការណ៍អំពីស្ថានភាពវិវឌ្ឍន៍របស់កុមារមករដ្ឋបាលសុំកូនអន្តរប្រទេសជារៀងរាល់ ៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ៣ (បី) ឆ្នាំ បន្ទាប់មកត្រូវផ្តល់របាយការណ៍ ១ ឆ្នាំម្តង រហូតដល់កុមារមានអាយុ ១៨ ឆ្នាំ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ក្រសួងព្រះបរមរាជវាំង

28/45

ឪពុកម្តាយចិញ្ចឹមត្រូវផ្ញើរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល ឬ ប្រទេសជាលំនៅឋានអចិន្ត្រៃយ៍របស់ខ្លួនទៅតាមស្ថានភាពសមស្រប ។

**មាត្រា ៤៦.-**

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាទុកសំណុំឯកសារសុំកូនអន្តរប្រទេសក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទដែលដីកាសម្រេចសុំកូនអន្តរប្រទេសនោះចូលជាស្ថាពរ ។

សំណុំឯកសារ និង កំណត់ហេតុទាំងអស់ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការ រដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និង អ្នកជំនាញផ្សេងៗទៀតដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាការសម្ងាត់ ។ ក៏ប៉ុន្តែសំណុំឯកសារនិងកំណត់ហេតុ ឬ ព័ត៌មានទាំងឡាយដែលមាននៅក្នុងសំណុំឯកសារ និង កំណត់ហេតុទាំងនោះអាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬ ការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុង ឬ ក្រៅព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនឹងករណី ឬ នីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬ កាលៈទេសៈពិសេសដទៃទៀត ។

ឪពុកម្តាយចិញ្ចឹមអាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតរបស់កូនសុំក្រោយពីដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ខ្លួន អាចត្រូវបានអនុញ្ញាតឱ្យមើលសំណុំលិខិតរបស់ខ្លួនរួមទាំងអត្តសញ្ញាណរបស់ឪពុកម្តាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្តាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និង កំណត់ហេតុទាក់ទងនឹងអត្តសញ្ញាណខ្លួន ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធានាថា កូនសុំទទួលបានការពិគ្រោះយោបល់សមស្របមុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន ។

29/35

មាត្រា ៥៥.-

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយមិនអនុវត្តតាមកថាខណ្ឌទី ១ មាត្រា ៤៧ ឬ កថាខណ្ឌទី ២ មាត្រា ៤៨ នៃច្បាប់នេះ ត្រូវពិន័យអន្តរការណ៍ជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលទៅក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ ។

ក្នុងករណីទីភ្នាក់ងារមិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូនសំណុំរឿងទៅតុលាការ ។

មាត្រា ៥៦.-

បទល្មើសពាក់ពន្ធ័ទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និង បទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

មាត្រា ៥៧.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៥៨.-

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩

៣៤៧. ០៩១២. ១១៤៩

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី

ហត្ថលេខា

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានជម្រាបជូនសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

ហត្ថលេខា

អ៊ិត សំហេង

លេខ ១០៥៩ ច.ល
[illegible] ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៩
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible]

# ឧបសម្ព័ន្ធទី៣

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១១៩ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការគ្រប់គ្រងមណ្ឌលថែទាំកុមារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ការពង្រឹងគុណភាពនិងប្រសិទ្ធភាពនៃការគ្រប់គ្រងមណ្ឌលថែទាំកុមារនិងការការពារឧត្តមប្រយោជន៍កុមារ។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅគ្រប់គ្រងមណ្ឌលថែទាំកុមារ ដែលផ្តល់នូវការថែទាំ ស្នាក់នៅ និងផ្តល់នូវតម្រូវការជាមូលដ្ឋានឲ្យកុមាររស់នៅជាក្រុមដល់កុមារដែលគ្មានឪពុកម្តាយ ឬគ្មានឪពុក ឬគ្មានម្តាយ ឬកុមារដែលត្រូវគេបោះបង់ចោល ឬក៏កុមារដែលឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលពុំមានលទ្ធភាពផ្តល់ការថែទាំគ្រប់គ្រាន់។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះមណ្ឌលថែទាំកុមារទាំងអស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៤ .-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាស្ថាប័នមានសមត្ថកិច្ចក្នុងការគ្រប់គ្រងមណ្ឌលថែទាំកុមារ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាត្រួតពិនិត្យនិងវាយតម្លៃអំពីសមត្ថភាពនិងលទ្ធភាពដោយផ្អែកលើសភាពការណ៍ជាក់ស្តែង ដើម្បីធ្វើប្រតិភូកម្មនិងផ្ទេរមុខងារគ្រប់គ្រងមណ្ឌលថែទាំកុមារដែលអាចផ្ទេរបាន ជាដំណាក់កាលឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៥ .-**

ក្នុងការបង្កើត ដំណើរការអនុវត្ត ការសម្របសម្រួល ការត្រួតពិនិត្យ និងការវាយតម្លៃមណ្ឌលថែទាំកុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវបង្គាប់នាយកដ្ឋានជំនាញឲ្យបំពេញភារកិច្ចដូចតទៅ៖

- ទទួលពាក្យស្នើសុំបើកមណ្ឌលថែទាំកុមារ
- ចុះធ្វើការប៉ាន់ប្រមាណលក្ខណសម្បត្តិរបស់រូបវន្តបុគ្គលឬនីតិបុគ្គល ស្នើសុំធ្វើរបាយការណ៍ និងលើកយោបល់ជំនាញជូនថ្នាក់ដឹកនាំក្រសួងដើម្បីពិនិត្យនិងសម្រេច

# ឧបសម្ព័ន្ធទី៤

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ២២៨០ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០១១

# ប្រកាស
## ស្តីពី
## នីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលព្រះរាជាណាចក្រកម្ពុជាបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩១២/១១៤៨ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មិនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ២១៧ ស.អ.យ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តគោលនយោបាយ ស្តីពីការថែទាំជំនួសចំពោះកុមារ
- បានឃើញប្រកាសលេខ ៦១៦ ស.អ.យ. ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីបទដ្ឋានអប្បបរមាសម្រាប់ការថែទាំកុមារក្នុងមណ្ឌល

១- មុនពេលចាប់ផ្តើមធ្វើផែនការអចិន្ត្រៃយ៍ ត្រូវមានឯកសារគ្រប់គ្រាន់ដែលបញ្ជាក់ពីការប្រឹងប្រែង នៃការផ្តល់សេវារក្សាកុមារក្នុងគ្រួសារ និងសេវាបង្រួបបង្រួមគ្រួសារដែលបានធ្វើកន្លងមក ព្រមទាំងបញ្ជាក់ពីមូលហេតុ ដែលនាំឱ្យមានការសម្រេចចិត្តបញ្ជូនករណីនេះ សម្រាប់ធ្វើផែនការអចិន្ត្រៃយ៍។ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ឃុំ សង្កាត់ និង មន្ត្រីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ពាក់ព័ន្ធ ឬមន្ត្រីមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវសម្រេចចិត្តរួមគ្នាក្នុងការចាប់ផ្តើមធ្វើផែនការអចិន្ត្រៃយ៍នេះ។

២- ការទុកដាក់អចិន្ត្រៃយ៍ដែលអាចកំណត់ថាជោគជ័យបាន លុះត្រាតែកុមារត្រូវបានបញ្ចូលឱ្យរស់នៅក្នុងគ្រួសារមួយ ក្រោមរូបភាពជាអាណាព្យាបាលស្របច្បាប់ សុំកូនក្នុងប្រទេស ឬសុំកូនអន្តរប្រទេស។

៣- រាល់ការទុកដាក់អចិន្ត្រៃយ៍ត្រូវមានដីកាសម្រេចពីតុលាការ ដកហូតអំណាចមេបាពីឪពុកម្តាយបង្កើត ឬឪពុកម្តាយកុមារបានយល់ព្រមឱ្យធ្វើផែនការអចិន្ត្រៃយ៍សម្រាប់កុមារ។ មានតែតុលាការទេ ដែលអាចសម្រេចការទុកដាក់កុមារជាអចិន្ត្រៃយ៍។

៤- ករណីដែលឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ស្ម័គ្រចិត្តលាលែងពីអ្នកមានអំណាចមេបា ឬផ្តល់ការព្រមព្រៀងឱ្យធ្វើផែនការអចិន្ត្រៃយ៍សម្រាប់កុមារ ត្រូវផ្តល់ការពិគ្រោះយោបល់ជាមួយឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ជាមុនសិនអំពីសេវាដែលមានសម្រាប់រក្សាកុមារក្នុងគ្រួសារបាន និងលទ្ធផលចុងក្រោយ នៃការសម្រេចចិត្តរបស់ពួកគាត់។ ការពិគ្រោះយោបល់ត្រូវធ្វើឡើងដោយភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ច ដែលទទួលបានការបណ្តុះបណ្តាលត្រឹមត្រូវ ហើយត្រូវធ្វើឡើងនៅចំពោះមុខមេឃុំ ចៅសង្កាត់។

**ប្រការ ២៥.-**

នីតិវិធីនៃការស្វែងរកគ្រួសារអចិន្ត្រៃយសម្រាប់កុមារ ត្រូវអនុវត្តដូចខាងក្រោម:

១- ការស្វែងរកគ្រួសារថ្មីឱ្យកុមារ ត្រូវផ្តល់អាទិភាពដល់ការទុកដាក់កុមារឱ្យរស់នៅជាមួយសាច់ញាតិនៅក្នុងសហគមន៍ ឬ រាជធានី ខេត្តរបស់កុមារ។ ប្រសិនបើកុមារមានសាច់ញាតិនៅក្នុងរាជធានី ខេត្តផ្សេង មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៃរាជធានី ខេត្តនោះ ត្រូវសម្របសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីទុកដាក់កុមារជាមួយនឹងសាច់ញាតិរបស់កុមារ។

២- ក្នុងករណីកុមារគ្មានគ្រួសារ ឬរកគ្រួសារមិនឃើញ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា រាជធានី ខេត្ត ត្រូវប្រឹងប្រែងរកគ្រួសារអចិន្ត្រៃយ៍ផ្សេងទៀតនៅឃុំ សង្កាត់ ក្រុង ស្រុក ខណ្ឌ និង រាជធានី ខេត្តរបស់កុមារ។

៣- ក្នុងករណីមិនអាចរកគ្រួសារអចិន្ត្រៃយ៍បានសម្រាប់កុមារក្នុងរយៈពេល ៤ (បួន) ខែយ៉ាងតិច មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវបញ្ជូនឈ្មោះរបស់កុមារទៅនាយកដ្ឋានសុខុមាលភាពកុមារ ដើម្បីពិចារណារកជម្រើសទុកដាក់នៅតាមបណ្តារាជធានី ខេត្ត ផ្សេងទៀត។

៤- បន្ទាប់ពីនាយកដ្ឋានសុខុមាលភាពកុមារបានពិនិត្យពិចារណា ក្នុងការស្វែងរកគ្រួសារអចិន្ត្រៃយ៍ក្នុងប្រទេសអស់រយៈពេល ៦ (ប្រាំមួយ)ខែ នៅតែរកមិនបានគ្រួសាសមស្របសម្រាប់កុមារ ត្រូវបញ្ជូន

សំណុំឯកសាររបស់កុមារទៅអាជ្ញាធរសុំកូនអន្តរប្រទេស ដើម្បីរកដំណោះស្រាយសុំកូនអន្តរប្រទេស។ រយៈពេលនេះនឹងត្រូវពិនិត្យឡើងវិញជារៀងរាល់ឆ្នាំ ហើយអាចធ្វើការកែប្រែឱ្យខ្លីជាងនេះ ក្នុងករណីចាំបាច់ និងសមស្រប។

**ប្រការ ២៦.-**

ការទទួលខុសត្រូវក្នុងការលើកកម្ពស់នៃការទុកដាក់កុមារក្នុងប្រទេស ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោមៈ

១- នាយកដ្ឋានសុខុមាលភាពកុមារ និងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវទទួលខុសត្រូវក្នុងការលើកកម្ពស់ការទុកដាក់កុមារជាអចិន្ត្រៃយ៍នៅក្នុងប្រទេស។

២- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវធ្វើយុទ្ធនាការជាបន្តបន្ទាប់នៅតាមរាជធានី ខេត្តរៀងៗខ្លួន ដើម្បីជ្រើសរើសគ្រួសារធម៌ អាណាព្យាបាលស្របច្បាប់ និងអ្នកសុំកូនក្នុងប្រទេស។ កិច្ចខិតខំប្រឹងប្រែងនេះត្រូវធ្វើឡើង ដោយមានការចូលរួមពីការិយាល័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់ និងពីអង្គការមិនមែនរដ្ឋាភិបាលនានា ដែលមិនមានកម្មវិធីធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេស។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវបណ្តុះបណ្តាលដល់គ្រួសារ និងចេញលិខិតបញ្ជាក់ជូនគ្រួសារមានបំណងយកកុមារឱ្យរស់នៅក្នុងផ្ទះរបស់ខ្លួន។

៣- នាយកដ្ឋានសុខុមាលភាពកុមារ ត្រូវកៀរគររកដៃគូអភិវឌ្ឍន៍ និងធ្វើសំណើទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីស្នើសុំមូលនិធិ និងការគាំទ្រផ្នែកបច្ចេកទេសសម្រាប់មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ក្នុងការជ្រើសរើសគ្រួសារ បណ្តុះបណ្តាលគ្រួសារ និងចេញលិខិតបញ្ជាក់ជូនគ្រួសារ។ នាយកដ្ឋានសុខុមាលភាពកុមារក៏ត្រូវដឹកនាំធ្វើយុទ្ធនាការថ្នាក់ជាតិ ដើម្បីស្វែងរកគ្រួសារ ដែលយល់ព្រមទទួលយកកុមារទៅចិញ្ចឹម និងបញ្ជូនសំណុំឯកសារគ្រួសារទាំងនោះទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត នៃលំនៅដ្ឋានរបស់កុមារ។

**ប្រការ ២៧.-**

ការពង្រឹងការថែរក្សាកុមារជាអចិន្ត្រៃយ៍ជាមួយសាច់ញាតិ ត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

១- នៅពេលសាច់ញាតិបានថែទាំកុមារអស់រយៈពេលយ៉ាងតិចប្រាំមួយខែ ហើយកុមារនោះមានការអភិវឌ្ឍល្អប្រសើរ ត្រូវចាត់ទុកថា ជាការថែទាំអចិន្ត្រៃយ៍ លើកលែងតែមានមូលហេតុដែលនាំឱ្យមានក្តីបារម្ភ។

២- ក្នុងករណីបែបនេះ ត្រូវលើកទឹកចិត្តសាច់ញាតិដែលថែទាំកុមារបានល្អនោះឱ្យធ្វើជាអាណាព្យាបាលស្របច្បាប់របស់កុមារ ឬសុំយកកុមារនោះទៅចិញ្ចឹមជាអចិន្ត្រៃយ៍ ប៉ុន្តែមិនតម្រូវ ឬបង្ខំឡើយ។

៣- ក្នុងករណីសាច់ញាតិត្រូវការជំនួយសម្រាប់ថែទាំកុមារ ត្រូវផ្តល់សេវាជំនួយទាំងនោះឱ្យគ្រួសារសាច់ញាតិនោះក្នុងនាមជាសេវារក្សាកុមារក្នុងគ្រួសារ។

# ឧបសម្ព័ន្ធទី៥

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៤៤៤ សហវ.ប្រក

រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៣

# ប្រកាសរួម
# ស្តីពី
# ការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់ស្មុំកូនអន្តរប្រទេស

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់នឹងស្មុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីស្មុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ និងអនុក្រឹត្យពាក់ព័ន្ធ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- បានឃើញអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញបទបញ្ជាលេខ ០៤ បប. ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៦ របស់រាជរដ្ឋាភិបាល ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញលិខិតលេខ ២៩ សជណ.អវ ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០១២ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- ប្រកាសលេខ ២៧២ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១១ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពី ការដាក់ឱ្យប្រើប្រាស់បង្កាន់ដៃបង់ប្រាក់
- បានឃើញប្រកាសលេខ ២៤៩ ស.អ.យ. ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខ ២៥០ ស.អ.យ. ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស
- យោងតាមការចាំបាច់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

# សម្រេច

**ប្រការ ១ :**

ត្រូវបានកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា ដែលអ្នកសុំកូនត្រូវបង់ចំនួន ៥.០០០ USD (ប្រាំពាន់ដុល្លាអាម៉េរិក)សម្រាប់ការសុំកុមារ ០១ (មួយ) នាក់ ដែលទុកជាថវិកាវិភាគទានមនុស្សធម៌។ ថវិកាវិភាគទានមនុស្សធម៌នេះ ទុកប្រើប្រាស់សម្រាប់ឧបត្ថម្ភដល់ជម្រើសនានានៃកម្មវិធីថែទាំជំនួសចំពោះកុមារ និងការជួយឧបត្ថម្ភដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស ។

**ប្រការ ២ :**

អ្នកសុំកូនត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានានេះ ចំនួន៥.០០០ USD (ប្រាំពាន់ដុល្លាអាម៉េរិក ) ជាពីរលើកដូចខាងក្រោម ៖

**លើកទី១ :** អ្នកសុំត្រូវបង់ប្រាក់ចំនួន ១.៥០០ USD (មួយពាន់ប្រាំរយដុល្លាអាម៉េរិក) នៅពេលដែលសំណុំឯកសារសុំកូន ត្រូវបានបញ្ជូនមកដល់រដ្ឋបាលសុំកូនអន្តរប្រទេសនៃអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។ ចំនួនទឹកប្រាក់នេះមិនអាចបង្វិលជូនវិញបានទេ។

**លើកទី២ :** អ្នកសុំត្រូវបង់ប្រាក់ចំនួន ៣.៥០០ USD (បីពាន់ប្រាំរយដុល្លាអាម៉េរិក) មុនពេលធ្វើពិធីប្រគល់កុមារជាផ្លូវការ ។

ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានានេះ អ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស។ ចំពោះប្រទេសដែលគ្មានទីភ្នាក់ងារសុំកូនអន្តរប្រទេស ការបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា ត្រូវបង់តាមរយៈអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល ។

# ឧបសម្ព័ន្ធទី៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
លេខ ១៩៤ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាល ស្មុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១០៥ / ០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញាស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជា បានសុំចូលជាភាគីនៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រម នស / រកម / ០១០៧ / ០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងស្មុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២០៩ / ០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

### ប្រការ ១.-

ប្រកាសនេះកំណត់ពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា មានអក្សរកាត់ថា " **អ.ក.ស.ក** " ជាភាសាអង់គ្លេស " Central Authority for Inter-country Adoption ( C.A.I.A )។



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

**ប្រការ ២.-**

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាស្របតាមមាត្រា ៦ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

**ប្រការ ៣.-**

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចដូចតទៅ៖

១- រៀបចំ និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងការសម្រេចលើកិច្ចការសុំកូនអន្តរប្រទេស។

២- ធ្វើសហប្រតិបត្តិការ និងសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នាទៅនឹងកិច្ចការសុំកូនអន្តរប្រទេសជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជានិងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៣- ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៤- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ។

៥- ពិនិត្យលើសំណើរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។

៦- ធ្វើអធិការកិច្ចលើការងារទាំងឡាយដែលពាក់ព័ន្ធជាមួយសុំកូនអន្តរប្រទេស។ គ្មានជនណាអាចរារាំង បង្អាក់ ឬ ជ្រៀតជ្រែកក្នុងការងារអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់បានឡើយ។

៧- ចាត់វិធានការដ៏សមស្របដើម្បីប្រមូល រក្សាការពារ និងផ្លាស់ប្តូរព័ត៌មានអំពីស្ថានភាពរបស់កុមារ និងរក្សាទុកព័ត៌មានទាក់ទងនឹងប្រភពកំណើតរបស់កុមារ អត្តសញ្ញាណរបស់កុមារ ឪពុកម្តាយកុមារ និងប្រវត្តិសុខភាពកុមារ។

៨- រក្សា និងផ្តល់ស្ថិតិទាក់ទងនឹងសុំកូនអន្តរប្រទេសដល់ប្រទេសនានាតាមសំណើ។

៩- ទទួលប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាពីអ្នកសុំកូនត្រូវបង់តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេស ឬអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

១០-ទទួលខុសត្រូវក្នុងការកត់ត្រា តាមដានប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើរបស់គណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌នៅរតនាគារជាតិ។

១១-ធ្វើរបាយការណ៍ស្តីពីស្ថានភាពប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាដែលប្រមូលបាន និងបង់ប្រាក់ចូលក្នុងគណនីប្រាក់បញ្ញើនៅរតនាគារជាតិជាទៀងរាល់ខែ ត្រីមាស និងប្រចាំឆ្នាំជូនគណៈកម្មាធិការគ្រប់គ្រង និងចាត់ចែងប្រាក់វិភាគទានមនុស្សធម៌។

១២-ពិនិត្យ ផ្តល់អនុសាសន៍ និងបញ្ជូនសំណុំឯកសារសុំកូនអន្តរប្រទេសនីមួយៗទៅតុលាការ។



៤៤

១៣- បំពេញភារកិច្ចផ្សេងៗទៀតដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា យល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ប្រការ ៤.-

អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ដឹកនាំដោយគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

## ប្រការ ៥.-

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានសមាសភាពដូចតទៅៈ

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ទទួលបន្ទុកវិស័យសុខុមាលភាពកុមារ | អនុប្រធាន |
| ៣- | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៤- | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ | សមាជិក |
| ៥- | នាយកខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ៦- | តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | សមាជិក |
| ៧- | អ្នកជំនាញការជាតិលើវិស័យសុខុមាលភាពកុមារ | សមាជិក |
| ៨- | ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ៩- | ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស | អគ្គលេខាធិការ |

ការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ប្រការ ៦.-

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសមានតួនាទី និងភារកិច្ចដូចខាងក្រោមៈ

១-ពិនិត្យ និងសម្រេចចុងក្រោយពាក់ព័ន្ធនិងនីតិវិធីសុំកូនអន្តរប្រទេស។

២-ពិនិត្យ និងផ្តល់អនុសាសន៍តាមការចាំបាច់លើគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងសុំកូនអន្តរប្រទេស។

៣-ធ្វើសហប្រតិបត្តិការជាមួយក្រសួង ស្ថាប័ន និងទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយកិច្ចការសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។

៤-ចាត់វិធានការសមស្របដើម្បីបង្ការ ទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេស។

៥-ពិនិត្យ និងផ្តល់អនុសាសន៍លើសកម្មភាពបណ្តុះបណ្តាលជំនាញដល់មន្ត្រីពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធផ្សេងទៀតលើការងារសុំកូនអន្តរប្រទេស។

៦-ពិនិត្យ សម្រេចលើសំណើផ្គូផ្គងកុមារនឹងអ្នកសុំដែលស្នើឡើងដោយរដ្ឋបាលសុំកូនអន្តរប្រទេស និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៧-ពិនិត្យ និងអនុម័តគម្រោងថវិកា ប្រាក់ចំណាយ សោហ៊ុយ ស្របតាមច្បាប់ស្តីពីសុំកូនអន្តរប្រទេស និងសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

៨- ទាក់ទង និងធ្វើសហប្រតិបត្តិការជាមួយការិយាល័យអចិន្ត្រៃយ៍នៃសន្និសីទក្រុងឡាអេ ស្តីពីច្បាប់អន្តរជាតិឯកជនពាក់ព័ន្ធនឹងការងារសុំកូនអន្តរប្រទេស អង្គការអន្តរជាតិពាក់ព័ន្ធ និងប្រទេសដែលមានទំនាក់ទំនងសហប្រតិបត្តិការលើវិស័យសុំកូនអន្តរប្រទេស ជាមួយព្រះរាជាណាចក្រកម្ពុជា។

៩- អនុវត្តភារកិច្ចផ្សេងៗទៀតដែលរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាប្រគល់ជូន។

## ប្រការ ៧.-

ត្រូវបានបង្កើតគណៈកម្មាធិការគ្រប់គ្រង ចាត់ចែងវិភាគទានមនុស្សធម៌នៃអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដែលរួមមានសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស បន្ថែមតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ០១រូប។ សមាសភាពតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់ដោយលិខិតរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ប្រការ ៨.-

របៀបរបបធ្វើការរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសៈ

-គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសបើកសម័យប្រជុំ ដើម្បីពិនិត្យឲ្យយោបល់លើករណីសុំកូននីមួយៗ និងពិនិត្យឲ្យយោបល់ក្នុងការរៀបចំត្រួតពិនិត្យការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាំងឡាយទាក់ទងនឹងសុំកូនអន្តរប្រទេស និងអនុវត្តភារកិច្ចដូចមានចែងក្នុងប្រការ ៦ នៃប្រកាសនេះ។

-ការប្រជុំ និងការសម្រេចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសអាចយកជាការបានលុះត្រាតែមានសមាជិកចូលរួមយ៉ាងតិច ៥០% + ១ នៃសមាជិកគណៈកម្មាធិការទាំងអស់។

-ការប្រជុំត្រូវដឹកនាំដោយប្រធានគណៈកម្មាធិការ ក្នុងករណីប្រធានអវត្តមាន អាចប្រគល់សិទ្ធិឲ្យអនុប្រធានដឹកនាំជំនួស។

-ការសម្រេចរបស់អង្គប្រជុំទាំងអស់ត្រូវអនុម័តដោយសំឡេងភាគច្រើននៃសមាជិកអង្គប្រជុំ ករណីមានសំឡេងស្មើគ្នា សំឡេងប្រធានមានឧត្តមានុភាព។

-ផ្អែកលើសារៈសំខាន់នៃបញ្ហានីមួយៗ ប្រធានគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គការ និងជនពាក់ព័ន្ធដទៃទៀតឲ្យចូលរួមយោបល់តាមការចាំបាច់។

-គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ត្រូវប្រជុំមួយខែម្តង ឬញឹកញាប់ជាងនេះទៅតាមការចាំបាច់។

## ប្រការ ៩.-

ត្រូវបានបង្កើតរដ្ឋបាលសុំកូនអន្តរប្រទេស មានអក្សរកាត់ថា " **រ.ស. អ.** " ជាភាសាអង់គ្លេស " Inter- country Adoption Administration ( I . C . A . A ) " ដើម្បីធ្វើជាសេនាធិការរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលស្នុំកូនអន្តរប្រទេស កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ប្រការ ១០.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

## ប្រការ ១១.-

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលស្នុំកូនអន្តរប្រទេស ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រី

**វង សូត**

<u>ចម្លងជូន:</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
-ខុទ្ទកាល័យឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងយុត្តិធម៌
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ក្រសួង ស្ថាប័នពាក់ព័ន្ធ
-ដូចប្រការ ១១
-រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣✵៥

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ១៩៥ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែវិច្ឆិកា ឆ្នាំ ២០១៣

# ប្រកាស

## ស្តីពី

## ការតែងតាំងសមាសភាពគណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/00១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញា ស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជាបានសុំចូលជាភាគី នៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/00៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- យោងប្រកាសលេខ ១៩៤ ស.អ.យ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញការចាំបាច់របស់ក្រសួង

## សម្រេច

**ប្រការ ១.-**

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានសមាសភាពដូចខាងក្រោម:

| | | |
|---|---|---|
| ១- ឯកឧត្តម **វង សូត** | រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ប្រធាន |
| ២- ឯកឧត្តម **នឹម ធូត** | រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | អនុប្រធាន |
| ៣- ឯកឧត្តម **ឆាយ វណ្ណា** | អនុរដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | សមាជិក |
| ៤- ឯកឧត្តម **សំហេង បុរស** | អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក **ម៉ែន សុចិត្រ** | នាយកខុទ្ទកាល័យរដ្ឋមន្ត្រី | សមាជិក |
| ៦- អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ | | សមាជិក |
| ៧- អ្នកជំនាញការជាតិលើវិស័យសុខុមាលភាពកុមារ | | សមាជិក |
| ៨-លោក **អ៊ុំ សុផាន់ណារ៉ា** | ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ | សមាជិក |
| ៩-លោក **រឿន រិទ្ធីរ័ត្ន** | ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស | អគ្គលេខាធិការ |

**ប្រការ ២.-**

គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស មានភារកិច្ចដូចចែងក្នុងប្រកាស លេខ ១៩៤ ស.អ.យ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស និងឯកឧត្តម លោកជំទាវ អស់លោក លោកស្រីដូចមានឈ្មោះក្នុងប្រការ១ មានភារកិច្ចរៀងៗខ្លួនអនុវត្តតាមប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**វង សូត**

**ចម្លងជូន:**
- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ខុទ្ទកាល័យ **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- -ខុទ្ទកាល័យឯកឧត្តម **គាត ឈន់** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- -ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- -ក្រសួងយុត្តិធម៌
- -ក្រសួង ស្ថាប័នពាក់ព័ន្ធ
- -ដូចប្រការ ៤
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៨

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៣✵៣

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ១៣៨ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ[illegible]ឆ្នាំ ២០១៤

# ប្រកាស
# ស្តីពី
# ការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញា ស្តីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃកម្ពុជាបានចុះហត្ថលេខាថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងបានផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីនីតិវិធីនៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ១៩៤ ស.អ.យ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខ ២៥០ ស.អ.យ. ចុះថ្ងៃទី៣១ ខែ មករា ឆ្នាំ ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស
- បានឃើញប្រកាសរួមលេខ ៤៤៨ សហវ.ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស
- យោងសំណូមពរចាំបាច់របស់ក្រុមគ្រួសារដែលជាសាច់ញាតិ
- បានឃើញការចាំបាច់របស់ក្រសួង



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ. ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២ ៦១ ០៣
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia . Fax/Phone: (855) 23 72 61 03

## សម្រេច

**ប្រការ ១ .-**

ប្រកាសនេះកំណត់អំពីគោលបំណង គោលដៅ វិសាលភាព គោលការណ៍ លក្ខខណ្ឌ សំណុំឯកសារ និងនីតិវិធីអនុវត្តសុំកូនអន្តរប្រទេសដោយសាច់ញាតិ ដូចមានចែងក្នុងជំពូកទី ១ មាត្រា ៤ (និយមន័យចំណុចទី ១០) ជំពូកទី ៤ មាត្រា ១០ កថាខណ្ឌចុងក្រោយ និងជំពូកទី ៥ មាត្រា ៣១ នៃច្បាប់ ស្តីពីសុំកូនអន្តរប្រទេស។

**ប្រការ ២ .-**

ប្រកាសនេះមានគោលបំណង៖

- ធានាឧត្តមប្រយោជន៍ និងការពារសិទ្ធិជាមូលដ្ឋានរបស់កុមារ ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសដោយសាច់ញាតិ
- ធានាថាកុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ត្រូវជាសាច់ញាតិពិតប្រាកដរបស់អ្នកសុំ ដូចមានចែងក្នុងប្រការ ៦ និងប្រការ ៨ ចំណុច ២ នៃប្រកាសនេះ
- លើកស្ទួយឲ្យមានការជួបជុំគ្រួសារ និងការរក្សាអត្តសញ្ញាណ ទំនៀមទម្លាប់និងវប្បធម៌ដើមរបស់កុមារ
- លើកស្ទួយការបន្តចិញ្ចឹមបីបាច់កុមារនៅក្នុងបរិយាកាសគ្រួសារដែលមានលក្ខណៈដូច ឬប្រហាក់ប្រហែល ស្របនឹងបរិយាកាសដូចកុមាររស់នៅក្នុងគ្រួសារកំណើតរបស់ខ្លួន។

**ប្រការ ៣ .-**

ប្រកាសនេះមានគោលដៅកំណត់អំពី គោលការណ៍ លក្ខខណ្ឌ នីតិវិធី និងសំណុំឯកសាររបស់កុមារ និងអ្នកសុំ សម្រាប់អនុវត្តលើករណីសុំកូនអន្តរប្រទេសដោយសាច់ញាតិ។

**ប្រការ ៤ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តលើការសុំកុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានជនជាតិបរទេសមានដើមកំណើតខ្មែរត្រូវជាសាច់ញាតិ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀតសុំយកទៅចិញ្ចឹមជាកូន និងត្រូវបានទទួលស្គាល់ដោយច្បាប់នៅប្រទេសនោះ។

**ប្រការ ៥ .-**

គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេសដោយសាច់ញាតិ ត្រូវអនុវត្តតាមខ្លឹមសារជំពូកទី ២ (គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស) មាត្រា ៥ (ចំណុច ១-២-៣-៤-៥-៦ និង ៧) នៃច្បាប់ស្តីពី សុំកូនអន្តរប្រទេស។ គោលការណ៍ផ្សេងៗទៀតដែលមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់ផ្សេងៗទៀតដែលទាក់ទងនឹងសុំកូនពេញលេញត្រូវយកមកអនុវត្តផងដែរ លើកលែងតែមានចែងនៅក្នុងច្បាប់ ស្តីពីសុំកូនអន្តរប្រទេស និងនៅក្នុងប្រកាសនេះ។

**ប្រការ ៦ .-**

កុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេសដោយសាច់ញាតិ ត្រូវបំពេញនូវលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

ក. កុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ.កុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលពាក្យសុំកូន។

គ.កុមារមានស្ថានភាពៈ

-ត្រូវការជំនួយអាស្រ័យដោយស្ថានភាពលំបាក ឬ ស្ថានភាពប្រឈមគ្រោះថ្នាក់

- កំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ រស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀតដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- កំពុងស្ថិតនៅក្រោមអាណាព្យាបាលសម្រាប់អនីតិជន ឬ ស្ថិតនៅក្រោមអំណាចមេបាលំបាក។

ឃ-១. កុមារជាចៅ ចៅទួត ក្មួយ របស់អ្នកសុំ ឬ

ឃ-២. កុមារជាកូន ចៅ ចៅទួត ក្មួយ របស់សហព័ទ្ធរបស់ខ្លួន។

ក្នុងករណីកុមារដែលបានបំពេញលក្ខខណ្ឌទាំងអស់ខាងលើនៃប្រការនេះ ហើយមានបងប្អូនបង្កើតច្រើននាក់ ដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ កុមារនោះ និងបងប្អូនបង្កើតអាចត្រូវបានពិចារណាឲ្យសុំយកទៅចិញ្ចឹមជាមួយគ្នា។

**ប្រការ ៧ .** –

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារជាកូនសុំអន្តរប្រទេសដោយសាច់ញាតិត្រូវមានដូចខាងក្រោមៈ

១-ប្រវត្តិរូបសង្ខេប (មានបិទរូបថត ៤ ស.ម x ៦ ស.ម ថតថ្មីមិនលើសពីរយៈពេលបីខែមុនប្រើប្រាស់)។

២-សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតរបស់កុមារ និងសំបុត្របញ្ជាក់កំណើតរបស់អ្នកអាណាព្យាបាល ឬ ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយបង្កើតរបស់កុមារ។

៣-លិខិតបញ្ជាក់សុខភាព ចេញដោយវេជ្ជបណ្ឌិតមានសមត្ថកិច្ចធ្វើការក្នុងមន្ទីរពេទ្យរដ្ឋ ឬ គ្លីនិកឯកជនផ្សេងទៀតដែលរដ្ឋទទួលស្គាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤-ឯកសារ ឬ ភស្តុតាងបញ្ជាក់អំពីអ្នកសុំត្រូវជាសាច់ញាតិជាមួយកុមារដែលអាចយកជាផ្លូវការបានដូចជាសៀវភៅគ្រួសារ ដីកា ឬ សាលក្រមតុលាការ ឬ ឯកសារពាក់ព័ន្ធផ្សេងទៀតរបស់អ្នកសុំដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល ឬ ប្រទេសដើមរបស់កុមារ។

៥-លិខិតយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវអនុវត្តតាមខ្លឹមសារក្នុងជំពូកទី ៤ (លក្ខខណ្ឌសម្រាប់សុំកូន) ផ្នែកទី ២ (ការយល់ព្រមលើសុំកូន) នៃច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស។

៦-ឯកសារផ្សេងទៀតតាមការចាំបាច់។

**ប្រការ ៨ .** –

អ្នកសុំដែលអាចអនុញ្ញាតឲ្យសុំកុមារជាសាច់ញាតិរបស់ខ្លួនយកទៅចិញ្ចឹមជាកូនបាន ត្រូវមានលក្ខខណ្ឌដូចតទៅៈ

១-អនុវត្តតាមខ្លឹមសារជំពូកទី ៤ (លក្ខខណ្ឌសម្រាប់សុំកូន) ផ្នែកទី ៣ (អ្នកសុំ) មាត្រា ២១ (ចំណុច ១-២(ក-ខ)-៣-៤-៥-៦-៧-៨ និង ៩) នៃច្បាប់ ស្តីពីសុំកូនអន្តរប្រទេស។

២-អ្នកសុំមានដើមកំណើតសញ្ជាតិខ្មែរសុំកុមារដែលត្រូវជាចៅរបស់ខ្លួន ចៅទួតរបស់ខ្លួន ក្មួយរបស់ខ្លួន ឬ កុមារដែលត្រូវជាកូន ចៅ ចៅទួត ឬ ក្មួយរបស់សហព័ទ្ធរបស់ខ្លួន។

ករណីកំពុងដំណើរការសុំកូន ប្រសិនបើសហព័ទ្ធដែលមានសញ្ជាតិខ្មែរដែលជាអនាគតឪពុក ឬ ម្តាយចិញ្ចឹមបានស្លាប់ ឬ ស្ថិតក្នុងស្ថានភាពមិនអាចបង្ហាញឆន្ទៈបាន រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសួរបញ្ជាក់ទៅអ្នកសុំជាប្តី ឬ ប្រពន្ធដែលជាអនាគតឪពុក ឬ ម្តាយចិញ្ចឹមអំពីដំណើរការនីតិវិធីសុំកូនអន្តរប្រទេសត្រូវផ្អាក ឬ បន្តហើយមានការយល់ព្រមពីកុមារដែលត្រូវសុំនោះផង (ក្នុងករណីកុមារអាចសម្តែងឆន្ទៈបាន) ដោយត្រូវមានការឯកភាពពីអាជ្ញាធរនៃប្រទេសទាំងពីរ និងត្រូវគិតពីឧត្តមប្រយោជន៍របស់កុមារ។

**ប្រការ ៩ .** –

សំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នកសុំកូនអន្តរប្រទេសដោយសាច់ញាតិ មានដូចខាងក្រោម៖

១- ពាក្យសុំកូន។

២- លិខិតអនុញ្ញាតឲ្យសុំកូនចិញ្ចឹមចេញដោយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំ ដោយមានបញ្ជាក់ថាកូនសុំត្រូវបានអនុញ្ញាតឲ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសរបស់អ្នកសុំ។

៣-របាយការណ៍ស្តីពីស្ថានភាពគ្រួសារដែលធ្វើដោយភ្នាក់ងារជំនាញ និងមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់អ្នកសុំ។

៤- សេចក្តីចម្លងសំបុត្រកំណើត ឬ លិខិតបញ្ជាក់កំណើត។

៥- សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍។

៦- លិខិតបញ្ជាក់សុខភាពរបស់អ្នកសុំ។

៧-របាយការណ៍អំពីចិត្តវិទ្យាធ្វើឡើងដោយគ្រូពេទ្យចិត្តវិទ្យា ដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ច។

៨-ភ័ស្តុតាងដែលបញ្ជាក់ថាអ្នកសុំបានទទួលព័ត៌មានគ្រប់គ្រាន់ និងបានទទួលការប្រឹក្សាយោបល់។

៩- លិខិតបញ្ជាក់ថាគ្មានទោសចេញដោយអាជ្ញាធរមានសមត្ថកិច្ចក្នុងប្រទេសកំណើត ឬ កន្លែងដែលអ្នកសុំរស់នៅចុងក្រោយ ឬ លិខិតថ្កោលទោសចេញដោយតុលាការ ឬ អាជ្ញាធរមានសមត្ថកិច្ចហើយនៅមានសុពលភាពប្រើប្រាស់។

១០-លិខិតបញ្ជាក់ពីកិរិយាមារយាទនៅកន្លែងប្រកបការងារ និងនៅក្នុងសង្គមរស់នៅរបស់អ្នកសុំចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

១១-លិខិតបញ្ជាក់ពីស្ថានភាពហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់អ្នកសុំ ចេញដោយអាជ្ញាធរមានសមត្ថកិច្ច។

១២-កិច្ចសន្យាគោរពសិទ្ធិជាកូន ផ្តល់ការសិក្សា ព្រមទាំងសិទ្ធិផ្តល់កេរមរតកដូចកូនបង្កើតរបស់ខ្លួន។

១៣-កិច្ចសន្យាស្តីពីការផ្តល់របាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការវិវឌ្ឍរបស់កូនសុំមករដ្ឋបាលសុំកូនអន្តរប្រទេសដោយផ្ទាល់ ឬ តាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច

ទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំរៀងរាល់ ០៦ (ប្រាំមួយ) ខែម្តង ក្នុងរយៈពេល ០៣ (បី) ឆ្នាំបន្ទាប់មកត្រូវផ្តល់របាយការណ៍០១ ( មួយ ) ឆ្នាំម្តងរហូតដល់កូនសុំមានអាយុ១៨ ( ដប់ប្រាំបី ) ឆ្នាំ។

ឯកសារទាំងអស់ខាងលើ ត្រូវមានការបញ្ជាក់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំ ឬ ប្រទេសរបស់អ្នកសុំកំពុងរស់នៅ។

ឯកសារទាំងអស់ត្រូវភ្ជាប់មកជាមួយនូវការបកប្រែជាភាសាអង់គ្លេស ឬ ភាសាបារាំងដោយមានការបញ្ជាក់ត្រឹមត្រូវពីស្ថាប័នមានសមត្ថកិច្ច។

១៤-រូបថតរបស់អ្នកសុំ (ទំហំ ៦ ស.មx ៨ ស.ម) យកក្នុងអំឡុងបីខែចុងក្រោយ។

១៥- ច្បាប់ថតចម្លងលិខិតឆ្លងដែនរបស់អ្នកសុំ។

១៦-រូបថតអ្នកសុំចំនួន ១០សន្លឹក និងលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំជាមួយការពិពណ៌នា។

ពាក្យសុំកូន ត្រូវសរសេរត្រង់ទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាដោយអ្នកសុំត្រូវបង្ហាញពីឆន្ទៈសុំកុមារ និងផ្តល់ព័ត៌មានពេញលេញអំពីអត្តសញ្ញាណ អាសយដ្ឋានរបស់ឪពុកម្តាយ ឬ ឪពុក ឬ ម្តាយ ឬ អ្នកអាណាព្យាបាលកុមារដែលត្រូវសុំ។

សំណុំឯកសារទាំងអស់ត្រូវធ្វើជាប្រាំច្បាប់ដោយរក្សាទុកនៅៈ

- អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំ ចំនួន ០១ ច្បាប់
- ស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់អ្នកសុំប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ ច្បាប់
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ ច្បាប់
- អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ០១ ច្បាប់ រួមទាំងការបកប្រែជាភាសាខ្មែរ
- ពាក្យសុំច្បាប់ដើម និងសំណុំឯកសារ ចំនួន ០១ ច្បាប់ បញ្ជូនទៅតុលាការរួមទាំងការបកប្រែជាភាសាខ្មែរ។

**ប្រការ ១០ .–**

អ្នកសុំ ត្រូវដាក់ពាក្យសុំកូនទៅអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំមកស្ថានទូត ឬ ស្ថានតំណាងនៃប្រទេសរបស់អ្នកសុំប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដោយមានកំណត់ទូតបញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារទាំងនោះ ហើយត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា។

ក្រោយពីទទួលបាននូវការផ្តល់យោបល់របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំក្នុងរយៈពេលយ៉ាងយូរបំផុត ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬ អាជ្ញាធរមាន

សមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬ តាមរយៈទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅឋានអចិន្ត្រៃយ៍របស់អ្នកសុំដោយបញ្ជាក់ថាខ្លួនបានទទួលពាក្យសុំកូនរួចហើយ។

**ប្រការ ១១ .–**

ក្រោយពីទទួលបានពាក្យសុំ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវលើកយោបល់ដើម្បីសុំគោលការណ៍អនុវត្តពីអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសដូចខាងក្រោម៖

ក-ក្នុងករណីកុមារដែលត្រូវសុំមានឈ្មោះក្នុងបញ្ជីកុមារជាកម្មវត្ថុសុំកូនអន្តរប្រទេសរួចហើយ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវអនុវត្តនីតិវិធីបន្តទៀតតាមច្បាប់ជាធរមាន។

ខ-ក្នុងករណីកុមារដែលត្រូវសុំនោះមិនទាន់មានឈ្មោះក្នុងបញ្ជីខាងលើ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសុំគោលការណ៍ពីអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីឲ្យនាយកដ្ឋានសុខុមាលភាពកុមារសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានីខេត្ត និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធចុះទៅពិនិត្យស្ថានភាពជាក់ស្តែង និងសិក្សាផ្ទៀងផ្ទាត់ព័ត៌មានដែលទទួលបានដោយធ្វើការវាយតម្លៃសភាពការណ៍រួម និងផ្តល់មតិអំពីលទ្ធផលដែលរកឃើញនូវភាពសមស្រប ឬ មិនសមស្របសម្រាប់កុមារដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស និងមានការចុះហត្ថលេខាទទួលខុសត្រូវទាំងអស់គ្នា ដើម្បីរាយការណ៍ជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងសុំអនុសាសន៍សម្រាប់អនុវត្តនីតិវិធីបន្ត។

គ-ក្នុងនីតិវិធីដំណើរការការងារទាំងអស់ ប្រសិនបើរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថាមានចំណុចណាមួយមានភាពមិនច្បាស់លាស់ ឬ មិនសមស្របរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវសុំយោបល់ពីអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីអញ្ជើញភាគីពាក់ព័ន្ធមកបំភ្លឺនៅចំណុចដែលមិនសមស្រប ឬដែលមិនច្បាស់លាស់នោះ។ ក្នុងករណីចាំបាច់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសអនុញ្ញាតឲ្យរដ្ឋបាលសុំកូនអន្តរប្រទេសចុះពិនិត្យវាយតម្លៃជាក់ស្តែងដល់ទីតាំងកុមាររស់នៅ។

ក្នុងករណីពិនិត្យឃើញថាអ្នកសុំ និងកុមារមិនមានលក្ខណៈសមស្របសម្រាប់សុំកូនអន្តរប្រទេសដោយសាច់ញាតិទេ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់យោបល់ក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការជូនអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីសុំអនុសាសន៍ឆ្លើយតបទៅអ្នកសុំវិញ ហើយត្រូវបញ្ចប់នីតិវិធីសុំកូនអន្តរប្រទេសដោយសាច់ញាតិ។

**ប្រការ ១២ .–**

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាតាមខ្លឹមសារប្រកាសរួមលេខ ៤៤៨ សហវ.ប្រកចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ស្តីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស។

**ប្រការ ១៣ .–**

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំឯកសារសុំកូនអន្តរប្រទេសដោយសាច់ញាតិដោយអនុវត្តតាមខ្លឹមសារ ជំពូកទី ៥ (នីតិវិធីសុំកូន) ផ្នែកទី ១ (នីតិវិធីរដ្ឋបាល) មាត្រា ២៦ នៃច្បាប់ ស្តីពីសុំកូនអន្តរប្រទេស។

**ប្រការ ១៤ .–**

រដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវបានដោយអនុវត្តតាមជំពូកទី ៥ មាត្រា ៣០ កថាខណ្ឌទី ៦ និងទី ៧ នៃច្បាប់ ស្តីពីស្មុំកូនអន្តរប្រទេស។ ក្នុងករណីកុមារអាចបង្ហាញឆន្ទៈបានចាំបាច់ត្រូវសុំការយល់ព្រមពីកុមារខ្លួនឯងផងដែរ។

**ប្រការ ១៥ .–**

ក្រោយពីបានពិនិត្យឃើញថាអ្នកសុំ និងកុមារមានសំណុំលិខិតត្រឹមត្រូវ និងគ្រប់គ្រាន់តាមលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌសម្រាប់ស្មុំកូនអន្តរប្រទេសដោយសាច់ញាតិ ហើយស្មុំកូននេះពិតជាឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលស្មុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ ជូនរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេសសុំការពិនិត្យ និងផ្តល់អនុសាសន៍លើដំណើរការស្មុំកូន។

**ប្រការ ១៦ .–**

ក្រោយពីទទួលបានអនុសាសន៍ពីរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានអាជ្ញាធរកណ្តាលស្មុំកូនអន្តរប្រទេស អ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកស្មុំកូនអន្តរប្រទេស ឬ ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៃប្រទេសទទួលដាក់ពាក្យសុំកូនតាមរយៈរដ្ឋបាលស្មុំកូនអន្តប្រទេសទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីសុំដីកាសម្រេចស្មុំកូន។ រដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលាដំបូងរាជធានីភ្នំពេញដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និងអ្នកសុំព្រមទាំងអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងរយៈពេល៧ (ប្រាំពីរ) ថ្ងៃ នៃថ្ងៃធ្វើការ គិតពីកាលបរិច្ឆេទទទួលពាក្យសុំ។ ឯកសារចាំបាច់ទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និងមានការបញ្ជាក់ពីរដ្ឋបាលស្មុំកូនអន្តរប្រទេស។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេល ៦០ (ហុកសិប) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានអនុសាសន៍របស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។

**ប្រការ ១៧ .–**

អានុភាពនៃស្មុំកូនអន្តរប្រទេសដោយសាច់ញាតិ ត្រូវអនុវត្តតាមខ្លឹមសារជំពូកទី ៦ (អានុភាពនៃស្មុំកូន) មាត្រា ៤១ និងមាត្រា ៤២ នៃច្បាប់ ស្តីពីស្មុំកូនអន្តរប្រទេស។

កូនសុំអាចប្រើនាមត្រកូលឪពុកម្តាយចិញ្ចឹម ឬ នាមត្រកូលដើមមុនពេលស្មុំកូនក៏បាន។

**ប្រការ ១៨ .–**

ការជូនដំណឹងពីចំណាត់ការ និងនីតិវិធីបន្ទាប់ពីបញ្ចប់ដំណើរការស្មុំកូនអន្តរប្រទេសដោយសាច់ញាតិត្រូវអនុវត្តតាមខ្លឹមសារជំពូកទី ៧ (ការជូនដំណឹងពីចំណាត់ការ និងនីតិវិធីបន្ទាប់ពីបញ្ចប់ដំណើរការស្មុំកូនអន្តរប្រទេស) មាត្រា ៤៤ មាត្រា ៤៥ និងមាត្រា ៤៦ (កថាខណ្ឌទី ១ និងទី ២) នៃច្បាប់ ស្តីពីស្មុំកូនអន្តរប្រទេស។

**ប្រការ ១៩ .-**

នាយកខុទ្ទកាល័យរដ្ឋមន្ត្រី អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានរដ្ឋបាល និងបុគ្គលិក ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងផ្គត់ផ្គង់ ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ ប្រធានរដ្ឋបាលសុំកូនអន្តរប្រទេស ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត និងអង្គភាពពាក់ព័ន្ធមានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

**រដ្ឋមន្ត្រី**

**វង សូត**

**<u>ចម្លងជូន:</u>**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តមគាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-ក្រសួងមហាផ្ទៃ
-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
-ក្រសួងយុត្តិធម៌
-ក្រសួងពាក់ព័ន្ធ
-ដូចប្រការ ១៩
-រាជកិច្ច
-កាលប្បវត្តិ - ឯកសារ

# ឧបសម្ព័ន្ធទី៦

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**៣៕៚**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

លេខ ១៣៩ ស.អ.យ.

*រាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ [illegible] ឆ្នាំ ២០១៤*

# ប្រកាស
## ស្ដីពី
## ការណែនាំអនុវត្តនីតិវិធីសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការ នូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស

## រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០១ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញអនុសញ្ញា ស្ដីពីសិទ្ធិកុមារដែលក្រុមប្រឹក្សាជាតិជាន់ខ្ពស់បានចុះហត្ថលេខានៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩២ និងបានផ្ដល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០៣ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការអនុម័តយល់ព្រមឲ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃអនុសញ្ញាក្រុងឡាអេ ស្ដីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤ ចុះថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ២០០៩ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១០/០១៣ ចុះថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១០ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីនីតិវិធីនៃរឿងក្ដីរដ្ឋប្បវេណីដែលមិនមែនជាបណ្ដឹង
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើក្រមរដ្ឋប្បវេណី
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១១ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- បានឃើញប្រកាសលេខ ១៩៤ ស.អ.យ. ចុះថ្ងៃទី ០៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរកណ្ដាលសុំកូនអន្តរប្រទេសនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញប្រកាសលេខ ២៥០ ស.អ.យ. ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស
- បានឃើញប្រកាសរួមលេខ ៨៤៨ សហវ.ប្រក ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៣ ស្ដីពីការកំណត់ចំនួនប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានាសម្រាប់សុំកូនអន្តរប្រទេស
- បានឃើញការចាំបាច់របស់ក្រសួង



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២ ៦១ ០៣
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia . Fax/Phone: (855) 23 72 61 03

## សម្រេច

**ប្រការ ១ .–**

ប្រកាសនេះកំណត់អំពីគោលបំណង គោលដៅ វិសាលភាព គោលការណ៍ លក្ខខណ្ឌ សំណុំឯកសារ និងនីតិវិធីអនុវត្តសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស។

**ប្រការ ២ .–**

ប្រកាសនេះមានគោលបំណងធានាឧត្តមប្រយោជន៍ និងការការពារសិទ្ធិជាមូលដ្ឋានរបស់កុមារដែលត្រូវការនូវការថែទាំពិសេស និង កុមារមានតម្រូវការពិសេស ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ដោយផ្តល់ឲ្យកុមារនូវការរីកចម្រើនក្នុងមជ្ឈដ្ឋានគ្រួសារប្រកបដោយសុភមង្គល សេចក្តីស្រឡាញ់ និងការយោគយល់ ដើម្បីមានឱកាសចូលរួមយ៉ាងសកម្មក្នុងសង្គមដូចកុមារដទៃទៀតដែរ។

**ប្រការ ៣ .–**

ប្រកាសនេះមានគោលដៅកំណត់អំពី គោលការណ៍ លក្ខខណ្ឌ នីតិវិធី និងសំណុំឯកសាររបស់កុមារ និងអ្នកសុំ សម្រាប់អនុវត្តលើករណីសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស។

**ប្រការ ៤ .–**

ប្រកាសនេះមានវិសាលភាពលើការសុំកុមារសញ្ជាតិខ្មែរ ដែលត្រូវការនូវការថែទាំពិសេស និង កុមារមានតម្រូវការពិសេស មានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវបានអ្នកសុំដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងប្រទេសណាមួយផ្សេងទៀត សុំយកទៅចិញ្ចឹមជាកូនដោយបានទទួលស្គាល់តាមច្បាប់នៅប្រទេសនោះ។

**ប្រការ ៥ .–**

គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេសចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និង កុមារមានតម្រូវការពិសេស ត្រូវអនុវត្តតាមខ្លឹមសារជំពូកទី ២ (គោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស) មាត្រា ៥ នៃច្បាប់ ស្តីពីសុំកូនអន្តរប្រទេស។ គោលការណ៍ផ្សេងទៀតដែលមានចែងនៅក្នុងបទប្បញ្ញត្តិច្បាប់ដែលទាក់ទងនឹងសុំកូនពេញលេញត្រូវយកមកអនុវត្តផងដែរ លើកលែងតែមានចែងនៅក្នុងច្បាប់ ស្តីពីសុំកូនអន្តរប្រទេស និងនៅក្នុងប្រកាសនេះ។

**ប្រការ ៦ .–**

១. កុមារដែលត្រូវការនូវការថែទាំពិសេស សំដៅដល់កុមារ ពិការផ្នែកកាយសម្បទាធ្ងន់ធ្ងរ ឬ ពិការផ្នែកស្មារតី ឬ កុមារដែលមានជំងឺរ៉ាំរ៉ៃ។

២. កុមារមានតម្រូវការពិសេស សំដៅដល់៖

ក. កុមារដែលមានអាយុក្រោម ១៨ឆ្នាំ មានវិបត្តិផ្លូវអារម្មណ៍ និងវិបត្តិអាកប្បកិរិយា ឬ

ខ. កុមារដែលមានអាយុក្រោម ១៨ឆ្នាំ និងមានបងប្អូនបង្កើតយ៉ាងតិចម្នាក់ដែលមានអាយុក្រោម ៨ឆ្នាំ។ (ឧទាហរណ៍ កុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស គឺមាននៅក្នុងឧបសម្ព័ន្ធ ១ នៃប្រកាសនេះ)។

**ប្រការ ៧ .–**

កុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស ដែលជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ត្រូវបំពេញនូវលក្ខខណ្ឌទាំងអស់ដូចខាងក្រោម៖

១. កុមារសញ្ជាតិខ្មែរ ដែលមានលំនៅឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២. កុមារមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានទទួលពាក្យសុំកូន។

៣.កុមារដែល៖

ក. កំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬ

ខ. កំពុងរស់នៅក្រោមការទុកដាក់សមស្របផ្សេងទៀត ដែលត្រួតពិនិត្យដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

គ. កំពុងស្ថិតក្រោមការថែទាំពីអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬ កុមារដែលស្ថិតនៅក្រោមអំណាចមេបា ដែលត្រូវការជំនួយដោយសារមានស្ថានភាពលំបាក និងស្ថានភាពប្រឈមនឹងគ្រោះថ្នាក់។ (ឧទាហរណ៍ ចំពោះស្ថានភាពលំបាក និងស្ថានភាពប្រឈមនឹងគ្រោះថ្នាក់ គឺមាននៅក្នុងឧបសម្ព័ន្ធ ២ ក្នុងប្រកាសនេះ)

**ប្រការ ៨ .–**

កុមារជាកម្មវត្ថុនៃសុំកូនអន្តរប្រទេស ដែលត្រូវការនូវការថែទាំពិសេស និង កុមារមានតម្រូវការពិសេស ត្រូវមានសំណុំឯកសារផ្ទាល់ខ្លួនដូចខាងក្រោម៖

១. ប្រវត្តិរូបសង្ខេបរបស់កុមារ (មានបិទរូបថត ៤ ស.ម x ៦ ស.ម ថតថ្មីមិនលើសពីរយៈពេលបីខែមុនប្រើប្រាស់)។

២. សំបុត្រកំណើត ឬ សំបុត្របញ្ជាក់កំណើតរបស់កុមារ។

៣. លិខិតបញ្ជាក់សុខភាព ចេញដោយវេជ្ជបណ្ឌិតមានសមត្ថកិច្ចធ្វើការក្នុងមន្ទីរពេទ្យរដ្ឋ ឬ គ្លីនិកឯកជនផ្សេងទៀតដែលរដ្ឋទទួលស្គាល់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

៤. លិខិតយល់ព្រមរបស់ឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវអនុវត្តតាមខ្លឹមសារ ជំពូកទី ៤ (លក្ខខណ្ឌសម្រាប់សុំកូន) ផ្នែកទី ២ (ការយល់ព្រមលើសុំកូន) នៃច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស។

៥. ឯកសារពាក់ព័ន្ធផ្សេងទៀតដែលមានការចាំបាច់។

**ប្រការ ៩ .–**

អ្នកសុំ អាចសុំកុមារដែលត្រូវការនូវការថែទាំពិសេស និង កុមារមានតម្រូវការពិសេស ត្រូវមានលក្ខខណ្ឌដែលអនុវត្តតាមខ្លឹមសារ ជំពូកទី ៤ (លក្ខខណ្ឌសម្រាប់សុំកូន) ផ្នែកទី ៣ (អ្នកសុំ) មាត្រា ២១ (ចំណុច ១-២(គ) -៣-៤-៥-៦-៧-៨ និង ៩) នៃច្បាប់ ស្ដីពីសុំកូនអន្តរប្រទេស។

**ប្រការ ១០ .–**

សំណុំឯកសារផ្ទាល់ខ្លួនរបស់អ្នកសុំកូនអន្តរប្រទេស ចំពោះកុមារដែលត្រូវការនូវការថែទាំពិសេស និងកុមារមានតម្រូវការពិសេស មានដូចខាងក្រោម៖

១. ពាក្យសុំកូន (ដោយបញ្ជាក់អំពី បំណង និងហេតុផល ដែលចង់សុំកុមារទៅចិញ្ចឹម)។

២. លិខិតអនុញ្ញាតឲ្យសុំកូនចិញ្ចឹមចេញដោយអាជ្ញាធរកណ្ដាល ឬ អាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសរបស់អ្នកសុំដោយមានបញ្ជាក់ថា កូនសុំត្រូវបានអនុញ្ញាតឲ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសរបស់អ្នកសុំ នៅពេលកូនសុំបានសម្រេចជាផ្លូវការ។

៣.របាយការណ៍ស្ដីពីស្ថានភាពគ្រួសារ ដែលធ្វើដោយភ្នាក់ងារជំនាញលើការងារនេះ ហើយមានការបញ្ជាក់ទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់អ្នកសុំ ដោយបញ្ជាក់អំពី